អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-May-2017, 09:17
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:១៣នាទី**

**សវនាការលើកទី២៦៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រ៊ា រតនៈ

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោកស្រី អង់តា ហ្គីសសេ
*(Ms. Anta GUISSE)*

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក សំ សុគង់

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ស៊្រា រតនៈ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឡេា ជុនធី | ខ្មែរ |
| លោក រ៊ិចឌ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អៀម យេន (2-TCCP-985) | ខ្មែរ |
| លោក ថាន់ ធីម (2-TCCP-288) | ខ្មែរ |
| លោក បេង បឿន (2-TCCP-981) | ខ្មែរ |
| លោកស្រី យែម ខុន្នី (2-TCCP-983) | ខ្មែរ |

# ឧបសម្ព័ន្ធ


**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី អៀម យ៉េន** (2-TCCP-985)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៣

សួរដោយលោក គង់ សំអុន ផ្ដើមពី ....................ទំព័រ ៩

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ចាន់ ធីម** (2-TCCP-288)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២១

សួរដោយលោក ឡោ ជុនធី ផ្ដើមពី....................ទំព័រ ២២

សួរដោយលោក វាំងសង់ វ៉ាន់ ដេស្វាឯល ផ្ដើមពី....................ទំព័រ ៣៣

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក បេង បឿន** (2-TCCP-981)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៤៥

សួរដោយលោក ឡោ ជុនធី ផ្ដើមពី....................ទំព័រ ៤៦

សួរដោយ លោក វាំងសង់ វ៉ាន់ ដេស្វាឯល ផ្ដើមពី....................ទំព័រ ៥៤

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៥៨

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី យ៉ែម ខុន្នី** (2-TCCP-981)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៦៨

សួរដោយ លោក សំ សុគង់ ផ្ដើមពី ....................ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

[០៩:១៣:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការសវនាការ ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូប ហើយជាដំបូងនេះ គឺស្តាប់ -- បន្តស្តាប់សេចក្តីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក សុន អរុណ មេធាវីជាតិការពារក្តីឲ្យលោក នួន ជា បានជូនដំណឹងមកថាលោកនឹងអវត្តមានសម្រាប់សវនាការថ្ងៃនេះ និងថ្ងៃស្អែក ដោយមូលហេតុផ្ទាល់ខ្លួន។

[០៩:១៤:៤២]

ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ ហើយដើមបណ្តឹងដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានចំនួនបួនរូប។ ហើយលោកស្រីដើមបណ្តឹងបន្តបញ្ចប់ គឺដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន ហើយបន្ទាប់មកទៀត គឺដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-288 បន្ទាប់មកទៀត គឺ 2-TCCP-981 និង 2-TCCP-983។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ

នេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការបង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:១៦:១៦]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះវុំាវ៉ៃវិលមុខពេលអង្គុយយូរ និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:១៧:០៣]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ សូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលពាក់ព័ន្ធជាមួយនឹងសេចក្តីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន។

សូមអញ្ជើញ!

**លោក ស្រ៊ា រតនៈ៖**

សូមគោរពឧត្តមប្រធាន សូមគោរពសវនាការ។ តាមពិតពី -- ខ្ញុំបាទចង់ជម្រាបឯកឧត្តម

ប្រធានថា ពីម្សិលមិញខាងតំណាងសហព្រះរាជអាជ្ញាមានបំណងចង់សួរសំណួរមួយចំនួនទៅដើមបណ្តឹងរដ្ឋប្បវេណីនេះដែរ ប៉ុន្តែបន្ទាប់ពីមានការពិភាក្សាគ្នាទៅឃើញថា សំណួរទាំងនេះ គឺពុំចាំបាច់លើកឡើងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនេះទេ ហើយម្យ៉ាងទៀត ខាងតំណាងសហព្រះរាជអាជ្ញាសូមស្នើសុំយកពេលវេលានេះ ដើម្បីទៅប្រើប្រាស់ជាមួយនឹងសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតដែលមានលេខសម្គាល់ 2-TCCP-288 វិញ ព្រោះសាក្សីរូបនោះ មានសារៈសំខាន់សម្រាប់សហព្រះរាជអាជ្ញាជាងបាទ។

[០៩:១៨:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយចុះខាងក្រុមមេធាវីការពារក្តី តើមានសំណួរអ្វីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ ពីមេធាវីការពារក្តីលោក នួន ជា មុន!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំមានសំណួរពីរបីសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូចទាក់ទងទៅនឹងសក្ខីកម្មរបស់លោកស្រីដែលបានឆ្លើយកាលពីម្សិលមិញ។ កាលពីម្សិលមិញ ខ្ញុំឮលោកស្រីនិយាយថា លោកស្រីត្រូវបានគេចាប់ខ្លួនម្តងហើយម្តងទៀត។ លោកស្រីប្រើពាក្យនេះ តើលោកស្រីមានន័យថា ដូចម្តេចដែរ ដែលថាលោកស្រីត្រូវបានគេចាប់ខ្លួនម្តងហើយម្តងទៀតនោះ?

**លោកស្រី អៀម យេន៖**

**ឆ៖** ចាស កាលដែលពីម្សិលមិញ ខ្ញុំបានប្រើពាក្យថា "គេចាប់ខ្លួនម្តងហើយម្តងទៀត" ព្រោះអីលើកទី១ ខ្ញុំគេចវេះកងបានគេចាប់ខ្ញុំយកទៅហ្នឹង យកទៅធ្វើបាប។ លើកទី២ ខ្ញុំហ្នឹងបានទៅរើសអាចម៍គោ អាចម៍ជ្រូកហ្នឹងដោយសារហេវ ហើយឃ្លានពេកក៏បានទៅលួចដំឡូងគេ។ ហ្នឹងជាលើកទី២ គេចាប់ខ្ញុំជាលើកទី២ ហ្នឹង។

[០៩:២០:០២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅពេលដែលលោកស្រីនិយាយថា"ចាប់ខ្លួន"។ តើលោកស្រីចង់មានន័យថាម៉េច<>"ចាប់ខ្លួន"ហ្នឹង?

**ឆ៖** ខ្ញុំចង់និយាយថា ចាប់ខ្ញុំហ្នឹង ព្រោះអីខ្ញុំធ្វើការលើកទី១ហ្នឹង ខ្ញុំធ្វើការវា កុមារកម្លាំងតូច ធ្វើការដូចថា ទ្រាំទ្រមិនបានផង។ ម៉្លេះហើយ ខ្ញុំគេចវេះហ្នឹង ខ្ញុំរត់ចេញហ្នឹង មេកងហ្នឹងមកចាប់ខ្លួនខ្ញុំហ្នឹង មិនមែនថាចាប់ខ្លួនអី កុមារហ្នឹងបញ្ជូនទៅកន្លែងកងខ្ញុំវិញហ្នឹង ឲ្យទៅធ្វើការវិញ។ ហើយទៅធ្វើទារុណកម្មខ្ញុំពេលនោះ។ បន្ទាប់មកបានឲ្យខ្ញុំធ្វើការ។

**ស៖** ខ្ញុំនឹងសួរសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៃការធ្វើទារុណកម្ម។ ពីសំណួរខាងដើមរបស់ខ្ញុំ គឺតើលោកស្រីអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើលោកស្រីមានន័យថាម៉េច ពាក្យថា "ចាប់ខ្លួន"? តើលោកស្រីត្រូវបានគេនាំខ្លួនទៅ<ដូចជាប៉ុស្តិ៍ប៉ូលិស ដើម្បី>សួរចម្លើយ? <តើគេមានសួរចម្លើយលោកស្រីទេ?>ប្រសិនជាអ៊ីចឹង<មាន> តើគេចាប់ខ្លួនយកទៅកន្លែងណាដែរ? សូមជម្រាបជូនអង្គជំនុំជម្រះឲ្យបានលម្អិតបន្តិចត្រង់កន្លែងនេះ។

[០៩:២១:២៦]

**ឆ៖** ចាស ព្រោះនិយាយថាចាប់ខ្លួនហ្នឹង ខ្ញុំអត់សូវដឹង អត់សូវចេះអីទេ ប៉ុន្តែខ្ញុំប្រើពាក្យថា "ចាប់ខ្លួន" ហ្នឹង ដូចថាខ្ញុំគេចវេះកងអ៊ីចឹង គេយកខ្ញុំទៅកន្លែងកងហ្នឹង អត់មាននគរបាល អត់មានសន្តិសុខអីទេ។ យកខ្ញុំទៅកន្លែងធ្វើការហ្នឹង។

**ស៖** ខ្ញុំយល់ថា ពេលលោកស្រីរត់ចេញពីកង គេចាប់លោកស្រីយកទៅកងវិញ។ ប៉ុន្តែ ខ្ញុំនៅតែមិនច្បាស់ថា ហេតុអ្វីបានជាលោកស្រីប្រើពាក្យថា "ចាប់ខ្លួន"ដូច្នេះ?

**ឆ៖** ដោយប្រើពាក្យថា "ចាប់ខ្លួន" បើខ្ញុំនិយាយឲ្យត្រង់ទៅ បើចាប់ខ្ញុំមែន មានប្រធានកងមួយ ប្រធានក្រុមពីរ មកចាប់ខ្ញុំអូសខ្ញុំទៅអ៊ីចឹង យកទៅកន្លែងកងហ្នឹង យកទៅធ្វើបាប។ ចាប់ខ្ញុំអូសទាញខ្ញុំទៅអ៊ីចឹង។ អាហ្នឹងខ្ញុំពាក្យ -- ខ្ញុំប្រាប់ថា ចាប់ខ្លួន ព្រោះអីប្រើដៃយកមកចាប់ខ្ញុំ មកអូសទាញខ្ញុំយកទៅ។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសួរសំណួរខ្លះៗទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលលោកស្រីថាគេបាន<>ចាប់អូសលោកស្រី<នៅលើកទី២>។ ហើយនៅពេលមួយនោះ គឺថាគេកប់លោកស្រីត្រឹមក។ <លោកស្រីចាំបានទេថានរណាជា>អ្នក<>កប់លោកស្រីហ្នឹង?

**ឆ៖** ពេលចាប់ខ្ញុំយកទៅកប់ត្រឹមកហ្នឹង ប្រធានកងខ្ញុំឈ្មោះ បងរុំ ។ គាត់យកខ្ញុំហ្នឹងទៅកប់ខ្ញុំ

ហ្នឹងតែម្ដង។

**ស៖** តើនៅពេលនោះ លោកស្រីចាំទេ រ៉ុំ អាយុប៉ុន្មានឆ្នាំដែរ?

**ឆ៖** ចាស រឿងអាយុរឿងអី ខ្ញុំអត់បានដឹងអត់បានអី ព្រោះអីពេលនោះខ្ញុំដឹងតែធ្វើការ អត់ប៉ានសួរប្រធានកងថាអាយុថាអី បើខ្ញុំជាកុមារ ហើយអត់មាន -- គាត់មានសិទ្ធិធំជាងខ្ញុំ ខ្ញុំមិនដែលប៉ានមើលមុខគាត់ផងហ្នឹង គាត់ដឹងតែប្រើឲ្យធ្វើការ ធ្វើតែការ។

**ស៖** លោកស្រីដឹងទេថា រ៉ុំ មានសិទ្ធិអំណាចចាប់កប់លោកស្រីអ៊ីចឹងទេ? តើគាត់ត្រូវនិយាយជាមួយ<នរណា>ម្នាក់អីដែរឬទេ មុននឹងធ្វើអំពើហ្នឹងមកលើលោកស្រី? <លោកស្រីជួយអធិប្បាយឲ្យពិស្ដារបន្ដិចបានទេ?>

**ឆ៖** ចាស ពេលគាត់កប់គាត់អីខ្ញុំ ខ្ញុំអត់បានដឹងថា សុំអ្នកណាៗម្នាក់ទេ ព្រោះអីគាត់ជាមេកងជាប្រធានកង ខ្ញុំអត់បានដឹងរឿងសុំរឿងអីទេ។

[០៩:២៤:៥៥]

**ស៖** ហើយលោកស្រីដឹងថា រ៉ុំ កប់លោកស្រីត្រឹម-ក អ៊ីចឹងភ្លាមៗយ៉ាងម៉េចក្រោយពីចាប់ខ្លួនលោកស្រី ឬក៏ក្រោយពីចាប់ខ្លួនក្រោយអស់មួយរយៈពេលណាហើយបានទើបកប់លោកស្រី?

**ឆ៖** ចាស ពេលខ្ញុំគេចវេះកងមកហ្នឹង គាត់ចាប់ខ្ញុំយកមកដល់ គាត់កប់ខ្ញុំ។ ភ្លាមៗហ្នឹង រយៈពេលជា ពីរ ឬបីម៉ោង ទើបគាត់លើកខ្ញុំឡើងចេញពីរណ្ដៅ។

**ស៖** តើត្រឹមត្រូវទេ បើខ្ញុំនិយាយថា នេះគឺជាអំពើដែល<រ៉ុំ ជាមេកង>បានធ្វើឡើងភ្លាមៗមកលើរូបលោកស្រី<ក្រោយពី>លោកស្រី<រត់ចេញពីកង>នោះ?

**ឆ៖** ត្រឹមត្រូវហើយធ្វើអំពើភ្លាមៗមកលើខ្ញុំកុមារហ្នឹង ខ្ញុំយល់អ៊ីចឹងដែរហ្នឹង។

**ស៖** តើ រ៉ុំ ជាមនុស្សប្រភេទយ៉ាងម៉េចដែរ លោកស្រីអាចរៀបរាប់បន្ដិចបានទេ?

**ឆ៖** រឿងប្រភេទយ៉ាងណាៗ ក៏ខ្ញុំមិនដឹងដែរ។ ខ្ញុំដឹងថា រ៉ុំ ហ្នឹងជាប្រធានកងរបស់ខ្ញុំ។ ខ្ញុំមិនបានដឹងថាគាត់ជាប្រភេទអ្វីៗទេ។

**ស៖** លោកស្រីដឹងទេ តើ រ៉ុំ ជាសមាជិករបស់បក្សកុម្មុយនីស្ដកម្ពុជាដែរឬអត់ទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងថា រ៉ុំ ហ្នឹងជាអ្វីៗទេ ខ្ញុំដឹងតែថាជាប្រធានកងរបស់ខ្ញុំ។

**ស៖** លោកស្រីដឹងទេថា រ៉ុំ ហ្នឹងត្រូវគេដាក់ទណ្ឌកម្ម<វិញទេ ក្រោយពី>បានកប់លោកស្រី<អ៊ីចឹង>?

**ឆ៖** រឿងដាក់ទណ្ឌកម្ម ឬមិនដាក់ទណ្ឌកម្ម ខ្ញុំអត់បានដឹង ខ្ញុំអត់ដឹងដែរ។

**ស៖** លោកស្រីចាំទេ តើព្រឹត្តិការណ៍នេះកើតនៅវេលាម៉ោងប៉ុន្មានដែរ?

**ឆ៖** ចាស ព្រឹត្តិការណ៍នេះ កើតនៅវេលាប្រហែលជាម៉ោងបួន ម៉ោងប្រាំល្ងាចហ្នឹង។

**ស៖** តើលោកស្រីអាចនៅចាំខែ ឬឆ្នាំណាដែរទេ?

**ឆ៖** ចាស ពេលនោះ ខ្ញុំនៅតូច ដូចថា ខ្ញុំមិនសូវចាំថ្ងៃខែប៉ុន្មានទេ។

[០៩:២៨:៣៨]

**ស៖** តើលោកស្រីអាចនៅចាំទីកន្លែងពិតប្រាកដ ឈ្មោះទីកន្លែង ដែលគេកប់លោកស្រីហ្នឹង តើនៅក្នុងភូមិណា នៅក្នុងសហករណ៍ណាដែរឬទេ?

**ឆ៖** ពេលដែលគេកប់ខ្ញុំហ្នឹង ពេលនោះគេឲ្យខ្ញុំមកនៅភូមិអាងខ្នារ ប៉ុន្តែឃុំភូមិ ខ្ញុំដូចជាមិនចាំច្បាស់ដែរ ខ្ញុំអត់បានដឹង។

**ស៖** ប៉ុន្តែតើលោកស្រីចាំថា នៅក្នុងភូមិហ្នឹងនៅត្រង់កន្លែងណាដែរ កើតឡើងនៅកន្លែងណាដែរ រឿងហ្នឹង?

**ឆ៖** រឿងហ្នឹងកើតនៅកន្លែងកងកុមារខ្ញុំតែម្តង។

**ស៖** កន្លែងកងហ្នឹងៗ នៅឯណា?

**ឆ៖** ចាស កន្លែងកងហ្នឹង នៅភូមិអាងខ្នារហ្នឹងតែម្តង។

**ស៖** ខ្ញុំយល់<ហើយ>លោក<ស្រីដើមបណ្តឹងរដ្ឋប្បវេណី> ប៉ុន្តែខ្ញុំគ្រាន់តែសួរថា ឲ្យពិតប្រាកដទីតាំងដែលកើតរឿងរ៉ាវហ្នឹង នៅត្រង់កន្លែងណាដែរ?

**ឆ៖** បើតាមខ្ញុំនិយាយទៅ កើតរឿងរ៉ាវហ្នឹង នៅភូមិអាងខ្នារ ប៉ុន្តែមួយទៀត ពេលចងខ្ញុំ អាហ្នឹង នៅទំនប់តាគុយ។ ខ្ញុំវាមានពីរចំណុច។ កន្លែងទំនប់តាគុយហ្នឹង នៅកន្លែងកងកុមារដែរ គេហៅថា "ព្រៃគុយ" ខ្ញុំមិនបានដឹង ប៉ុន្តែគេទំនប់តាគុយ ខ្ញុំហៅអ៊ីចឹងដែរទៅ។ ខ្ញុំមិនដែលបានស្គាល់ភូមិច្បាស់លាស់ទេ ខ្ញុំហៅតាម -- ពេលហ្នឹងគេហៅអ៊ីចឹង ខ្ញុំហៅអ៊ីចឹងដែរទៅ។

[០៩:៣០:៥៣]

**ស៖** ខ្ញុំសាកព្យាយាមសួរម្តងទៀត <លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី>។ ខ្ញុំដឹងថា វាកើតនៅក្នុងភូមិហ្នឹង ក៏ប៉ុន្តែនៅក្នុងភូមិហ្នឹង ចង់សួរថា តើវាស្ថិតនៅត្រង់កន្លែងណា? នៅជិតវត្ត? នៅជិតទីកន្លែងណាមួយ<?>

**ឆ៖** ចាស ពេលហ្នឹង អត់មានវត្តមានអីផងហ្នឹង ខ្ញុំនៅកន្លែងកងកុមារ ដូចថាគេដាក់នៅកងកុមារ នៅកន្លែងតាគុយហ្នឹង គឺគេយកមកធ្វើនៅកន្លែងគេតែម្ដង។

**ស៖** បាទ មិនជាអ្វីទេ <លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី>។ ខ្ញុំមានពីរបីសំណួរចុងក្រោយ។ កាលពីម្សិលមិញ លោកស្រីបានឆ្លើយថា គេមិនអនុញ្ញាតឱ្យលោកស្រីទៅរៀនសូត្រនៅសាលាទេ។ អ្នកណានិយាយមកកាន់លោកស្រី ហើយថា មិនឱ្យលោកស្រីឯងទៅរៀនសូត្រអីទេ។ អ្នកណាអ្នកនិយាយ?

**ឆ៖** ចាស ពេលនិយាយថាមិនបានទៅរៀនសូត្រហ្នឹង អត់មានអ្នកណានិយាយថាពេលត្រូវបានទៅរៀនសូត្រហ្នឹង អត់មាននិយាយប្រាប់ខ្ញុំទេ។ ប៉ុន្តែខ្ញុំនឹកឃើញថា ខ្ញុំអត់មានបានរៀនសូត្រ ពីម្សិលមិញ ខ្ញុំនិយាយអ៊ីចឹង។

**ស៖** <>បើលោកស្រី<នៅ>ចាំ<បាន តើនរណា>ប្រាប់លោកស្រី ថា<>គេ<មិន>អនុញ្ញាតឱ្យ<លោកស្រី>ទៅរៀនសូត្រអីទេ?

[០៩:៣២:៤០]

**ឆ៖** ចាស អត់មានអ្នកណាប្រាប់ខ្ញុំទេ នេះមកពី ដូចថាខ្ញុំគិតឡើងខ្លួនឯងតែម្ដង ខ្ញុំថាខ្ញុំអត់មានបានរៀន បានសូត្រ។

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី យើងបានស្ដាប់សាក្សីមួយចំនួន យើងមានភស្តុតាងនៅក្នុងសំណុំរឿង ដែលថាកុមារៗអាចទៅរៀនសូត្របាន អាចរៀនលេខនពន្ធ អាចរៀនភាសាជាដើម ។ល។ អ៊ីចឹងហើយបានជាខ្ញុំសាកសួរ ថាហេតុអ្វីបានជាលោកស្រីមិនអាចមានឱកាសទៅរៀនសូត្របាន ចន្លោះពីឆ្នាំ១៩៧៥ ដល់៧៩?

**ឆ៖** ចាស មកពី គាត់ថាមិនបាន ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយជ៍ ដេស្សាឯល៖**

បាទ ជម្រាបសួរលោកប្រធាន។ សូមអរគុណ លោក លោកស្រីចៅក្រមទាំងអស់ ជាទីគោរព។ ខ្ញុំគិតថា មេធាវីការពារក្ដីនៅពេលនិយាយថា កូនក្មេងមានសិទ្ធិទៅរៀននោះ គឺថាប្រហែលជាបំផ្លើសបន្តិចហើយ<ទាក់ទិនទៅនឹងអ្វីដែលយើងធ្លាប់បាន>ស្ដាប់<ឮ>នៅក្នុងសាលសវនាការនេះ<។ ប្រាកដណាស់ យើង>មិនដែលនិយាយពីសាលានោះទេ<។ នៅពេលនោះ>គឺថាមានការរៀន បង្រៀននៅ

<តាមភូមិ>មួយចំនួន<តែប៉ុណ្ណោះ ដូច្នេះហើយយើងមិនអាចនិយាយជាទូទៅលើបញ្ហានេះឡើយ>។ អ៊ីចឹង មេធាវីគួរតែប្រយ័ត្នប្រយែងក្នុងការរៀបចំសំណួរសួរទៅសាក្សីរូបនេះ។ <សូមអរគុណ>។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំ<ប្រាកដថា>សក្ខីកម្មរបស់<សាក្សីម្នាក់> តាសាន។ <យើងក៏មាន>នៅក្នុងសំណុំរឿង គឺ<ផ្នែក>អប់រំ <ឬ>សៀវភៅ<សិក្សា ដូច្នេះខ្ញុំយល់ថាវាជាការត្រឹមត្រូវណាស់ដែលនិយាយថាមានកិច្ច> ខិតខំប្រឹងប្រែង<>ចង់ឲ្យកុមារ<ទទួលបាននូវការអប់រំ។ ពិតណាស់ការរៀនសូត្រមិនបានធ្វើឡើងក្នុង>សាលារៀន<ទេ ព្រោះថាស្រុកទេសស្ថិតក្នុងសង្គ្រាមស៊ីវិលពីមុនមក>។ អ៊ីចឹងបានខ្ញុំ<អាចនិយាយបានថាមានប្រព័ន្ធអប់រំ> បឋមសិក្សា <និង>មធ្យមសិក្សា<និងកម្រិតផ្សេងៗទៀត>។ <>ខ្ញុំ<គិតថាខ្ញុំអាចសួរសំណួរនេះទៅកាន់>ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ<បាន>។

[០៩:៣៥:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៦:៣១]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដំណាក់កាលនេះ<>វា<ទំនង>ជាលឿនពេក<ហើយ ក្នុងការសន្និដ្ឋានថាតើមានប្រព័ន្ធអប់រំដល់កម្រិតណានោះ។ ប៉ុន្តែបើគ្រាន់តែសួរថាតើគាត់បានទៅរៀន ឬគេអនុញ្ញាតឲ្យគាត់ទៅរៀនដែរឬទេនោះ យើងគិតថាលោកមេធាវីអាចបន្តតាំងសំណួររបស់ខ្លួនតទៅទៀតបាន>ដោយមិនត្រូវសង្ខេបអំពីភស្តុតាងដែលមានពីមុនៗនោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ការដែលខ្ញុំសរុបសេចក្តីមកនេះគឺ<គ្រាន់តែជាប្រតិកម្មតបទៅនឹងការជំទាស់របស់ខាងព្រះរាជអាជ្ញាតែប៉ុណ្ណោះ លោកស្រីចៅក្រម។> លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី កាលពីម្សិលមិញថាលោកស្រីមិនបានទៅរៀនសូត្រទេ <ខ្ញុំបានសួរទៅលោកស្រីថា "តើនរណាប្រាប់លោកស្រីថាលោកស្រីមិនអាចទៅរៀនបាន?">។ <ខ្ញុំមិនប្រាកដថាលោកស្រីបានឆ្លើយសំណួរនេះនៅឡើយទេ>។ លោកស្រី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<>គិតបន្តិច<មើល៍ ថាតើនរ>ណា<>បានប្រាប់លោកស្រីថា <គេ>មិនអនុញ្ញាតឲ្យទៅរៀនទៅសូត្របាននោះ?

**លោកស្រី អៀម យេន៖**

**ឆ៖** ចាស កាលពីម្សិលមិញនេះ ខ្ញុំនិយាយថា ខ្ញុំមិនអាចទៅរៀនសូត្របាន។ គ្មានអ្នកណាប្រាប់ខ្ញុំថាមិនអាចទៅរៀនសូត្របានទេ មកពីទីនោះអត់មានសាលារៀន ខ្ញុំអត់បានដឹងមានសាលារៀន ខ្ញុំដឹងតែធ្វើការ។

[០៩:៣៨:០៥]

**ស៖** លោកស្រីដឹងថា មានកុមារៗណាខ្លះបានទៅរៀនសូត្រដែរទេ នៅពេលនោះ?

**ឆ៖** ចាស ខ្ញុំអត់ដែលមានឃើញកុមារណាទៅរៀនសូត្រដែរ ព្រោះអីកងកុមារខ្ញុំហ្នឹងដឹងតែពីការ ដើររើសអាចម៍គោ ដើររើសដីដំបូក។

**ស៖** បាទ ប្រធានបទមួយទៀតគឺជាប្រធានបទចុងក្រោយរបស់ខ្ញុំហើយ។ លោកស្រី ពីម្សិលមិញលោកស្រីបាននិយាយថា លោកស្រីធ្វើការនៅពេលយប់។ នៅពេលលោកស្រីថា គេឲ្យលោកស្រីធ្វើការនៅពេលយប់ តើលោកស្រីចង់មានន័យថាម៉េចដែរ?

**ឆ៖** ចាស កាលពីម្សិលមិញនេះ ខ្ញុំអត់មានថាធ្វើការពេលយប់ទេ ខ្ញុំថាធ្វើការពេលថ្ងៃ។ ជួនកាលពេលយប់ផ្លាស់កង។

**ស៖** ខ្ញុំសូមទោសលោកស្រី ដោយសារតែខ្ញុំយល់ច្រឡំ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជូនវេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបញ្ជាក់។ ដំបូងខ្ញុំចង់សួរបញ្ជាក់ថា តើឪពុករបស់អ្នកស្រីឈ្មោះអីដែរ?

[០៩:៣៩:៤៨]

**លោកស្រី អៀម យេន៖**

**ឆ៖** ចាស ឪពុករបស់នាងខ្ញុំហ្នឹងគឺឈ្មោះ ម៉ម ប្រុស។

**ស៖** បាទ សូមអរគុណ។ នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ លោកស្រីដាក់ថា ឪពុករបស់លោកស្រីឈ្មោះ ចៅ ប្រុស អ៊ីចឹងការហៅថាឈ្មោះ ចៅ ប្រុស នេះ គឺអត់ត្រឹមត្រូវទេ អ៊ីចឹង មែនទេ?

**ឆ៖** ចាស ឪពុករបស់ខ្ញុំដាក់ឈ្មោះថា ចៅ ប្រុស ហ្នឹងព្រោះអីពេលនោះ គាត់រស់នៅស្រុកក្រោមតែម្ដាយខ្ញុំនៅស្រុកលើ តែគាត់ដាក់តាមស្រុកគេ ប៉ុន្តែឥឡូវបច្ចុប្បន្ន ខ្ញុំដាក់តាមបច្ចុប្បន្នហ្នឹងឈ្មោះ ម៉ម ប្រុស។

**ស៖** បាទ ចុះម្ដាយអ្នកស្រីឈ្មោះអីដែរ?

**ឆ៖** ចាស ម្ដាយរបស់ខ្ញុំពេលនោះ នៅទីនុំងក៏គេដាក់ឈ្មោះថា នាង យន ដែរ ប៉ុន្តែសព្វថ្ងៃនេះដាក់ឈ្មោះ អូប យន។

[០៩:៤១:២២]

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីនៅក្នុងឯកសារនេះថា មានសញ្ជាតិខ្មែរកម្ពុជាក្រោម។ តើអ្នកស្រីធ្លាប់មានទទួលសញ្ជាតិជាខ្មែរកម្ពុជាក្រោមពីមុនមកទេ?

**ឆ៖** ចាស ពេលនោះ ខ្ញុំក៏បានសួរឪពុកម្ដាយខ្ញុំថាខ្ញុំកើតនៅទីណា? គាត់ប្រាប់ខ្ញុំថា នៅខ្មែរកម្ពុជាក្រោម។

**ស៖** អ្នកស្រីស្គាល់ទីកន្លែងកំណើតរបស់លោកស្រីទេនៅខ្មែរកម្ពុជាក្រោម?

**ឆ៖** ចាស ខ្ញុំអាចស្គាល់ទីកំណើតរបស់នាងខ្ញុំបាន។

**ស៖** បាទ សូមអញ្ជើញឆ្លើយទៅ!

**ឆ៖** ចាស នាងខ្ញុំហ្នឹងបានកើតនៅភូមិរលាំង ឃុំចូវឡាំង ស្រុកស្វាយទង ខេត្តអាងយ៉ាង។

**ស៖** បាទ សូមអគុណ។ ចុះក្នុងអត្តសញ្ញាណបណ្ណរបស់អ្នកស្រី មានឯកសារ D22/2161 ដែលមានលេខ 100341819 -- សុំ ដោយសារមានការបកប្រែខុស ខ្ញុំសូមបញ្ជាក់ឡើងវិញ គឺលេខ D22/2161។ ទាក់ទងនឹងអត្តសញ្ញាណប័ណ្ណរបស់អ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី អៀម យេន ដោយនៅក្នុងអត្តសញ្ញាណប័ណ្ណនេះ បញ្ជាក់ថា អ្នកស្រីមានស្រុកកំណើតនៅទួលពង្រ ឃុំសោម ស្រុកគីរីវង់

ខេត្តតាកែវ។ ចុះអ្នកស្រីអាចពន្យល់បានដូចម្តេចទាក់ទងការខ្វែងគ្នានេះ?

[០៩:៤៤:០៥]

**ឆ៖** ចាស ខ្ញុំបាននិយាយមុនថា ពីមុនមកខ្ញុំថ្ងៃខែស្រុកកំណើតខ្ញុំដាក់នៅខ្មែរកម្ពុជាក្រោម ប៉ុន្តែបច្ចុប្បន្ននេះ ខ្ញុំរស់នៅខ្មែរលើយើងហ្នឹង បានខ្ញុំដាក់អត្តសញ្ញាណប័ណ្ណតាមធម្មតារាល់ថ្ងៃហ្នឹង។

**ស៖** អ្នកស្រីយល់ពីស្រុកកំណើតទេ ពីព្រោះស្រុកកំណើតជាទីកន្លែងដែលកើត ហើយវាមិនអាចមានពីរកន្លែងទេ។ តើអ្នកស្រីអាចបញ្ជាក់បានយ៉ាងដូចម្តេចដែរចំណុចនេះ?

**ឆ៖** ចាស ទីកន្លែងដែលកើតពេលនោះ ខ្ញុំកើតនៅទីនោះ ប៉ុន្តែបច្ចុប្បន្ននេះ ខ្ញុំរស់នៅកន្លែងនេះ ខ្ញុំដាក់កន្លែងនេះតែម្តង។

[០៩:៤៤:៥៧]

**ស៖** អ្នកស្រីសម្រេចដាក់ដោយខ្លួនឯង ឬក៏មានការកែប្រែណាមួយតាមផ្លូវច្បាប់?

**ឆ៖** ចាស បើតាមការគិតរបស់នាងខ្ញុំ ព្រោះអីខ្ញុំរស់នៅខ្មែរកម្ពុជាលើ ហើយស្តាប់គេទូទៅ ព្រោះអីកាលណាយើងនៅខ្មែរលើ អត្តសញ្ញាណប័ណ្ណយើងធ្វើលើ យើងត្រូវតែធ្វើតាមខ្មែរលើអ៊ីចឹង។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់តទៀត ទាក់ទងទៅនឹងការរស់នៅរបស់អ្នកស្រី ក្រោយឆ្នាំ១៩៧៥។ អ្នកស្រីរស់នៅកន្លែងណាដែរ នៅក្រោយរំដោះ១៧ មេសា ១៩៧៥?

**ឆ៖** ចាស ក្រោយឆ្នាំ១៩៧៥ហ្នឹង ខ្ញុំបានរស់នៅភូមិត្រពាំងធំ ក្នុងឆ្នាំ១៩៧៥ហ្នឹងខ្ញុំបានរស់នៅក្នុងភូមិត្រពាំងធំខាងជើង។

**ស៖** អ្នកស្រីមានរស់នៅក្នុងប្រទេសវៀតណាមទេ នៅឆ្នាំ១៩៧៥ហ្នឹង?

**ឆ៖** ចាស ក្នុងឆ្នាំ១៩៧៥ហ្នឹង ខ្ញុំអត់បាននៅវៀតណាមទេ ខ្ញុំមកនៅភូមិត្រពាំងធំខាងជើងនេះហើយ។

[០៩:៤៦:៤៤]

**ស៖** លោកស្រីរស់នៅក្នុងភូមិត្រពាំងធំហ្នឹង រហូតដល់ឆ្នាំណាខែណាដែរ?

**ឆ៖** ចាស រស់នៅក្នុងភូមិត្រពាំងធំហ្នឹង មិនបាននឹងនរមួយកន្លែងទេ ព្រោះអីមានការផ្លាស់ប្តូរពីឪពុកម្តាយអ៊ីចឹង រហូតដល់ឆ្នាំ១៩៧៩បែកហ្នឹងតែម្តង។

**ស៖** ខ្ញុំចង់អានជូនអ្នកស្រីនូវសក្ខីកម្មរបស់អ្នកស្រី ដែលមានលេខ E3/4930, ERN ជាភាសាខ្មែរ 00579111, ជាភាសាអង់គ្លេស 00923153។ ខ្ញុំសូមដកស្រង់៖ "នៅពាក់កណ្តាលឆ្នាំ១៩៧៦

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេលដែលខ្មែរក្រហមមានគោលនយោបាយដោះដូរប្រជាជនវៀតណាមក្នុង និងខ្មែរ ជាមួយនឹងប្រទេសវៀតណាម គ្រួសាររបស់នាងខ្ញុំចំនួនប្រាំមួយនាក់ និងខ្មែររាប់រយគ្រួសារផ្សេងទៀតនៅកម្ពុជាក្រោមត្រូវបានទាហានវៀតណាមចាប់បញ្ជូនមកឲ្យទាហានខ្មែរក្រហម នៅច្រកព្រំដែនភ្នំខិន”។ សុំបិទការដកស្រង់។ អ្នកស្រីបានចាំថា អ្នកស្រីបានផ្ដល់សក្ខីកម្មបែបនេះទេ?

**ឆ៖** ចាស ពេលនោះខ្ញុំបានដឹងថា ពេលនោះខ្ញុំនែផ្ដល់សក្ខីកម្មដែរ ប៉ុន្តែខ្ញុំអត់បានដឹងថា ចងចាំវាមិនច្បាស់ថា ដូចដោះដូរអ៊ីចឹងទេ។

**ស៖** បញ្ហាត្រង់ថា តើអ្នកស្រីធ្លាប់បាននៅប្រទេសវៀតណាមក្នុងចន្លោះឆ្នាំ៧៥-៧៦ នោះ ឬមួយក៏អ្នកស្រីមិនដែលបាននៅក្នុងប្រទេសវៀតណាមទេ នៅក្នុងពេលនោះ? បើអ៊ីចឹង ពេលអ្នកស្រីឆ្លើយមុននេះ ថាអ្នកស្រីអត់បាននៅប្រទេសវៀតណាមទេ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា សក្ខីកម្មដែលខ្ញុំបានអានជូនអម្បាញ់មិញនេះ គឺមិនត្រឹមត្រូវទេ។ តើអ៊ីចឹងមែនទេ?

[០៩:៤៩:៥២]

**ឆ៖** ខ្ញុំដូចជាស្ដាប់មិនទាន់បានពាក្យហ្នឹង។

**ស៖** បាទ បញ្ហាគឺថា វាមានសក្ខីកម្មពីរផ្ទុយគ្នាក្នុងពេលតែមួយគឺក្នុងឆ្នាំ៧៥, ៧៦។ អ្នកស្រីថាអ្នកស្រីនៅភូមិត្រពាំងធំ។ ក៏ប៉ុន្តែមានសក្ខីកម្មមួយទៀតនោះ អ្នកស្រីថា អ្នកស្រីនៅប្រទេសវៀតណាម ហើយអ្នកស្រីចូលស្រុកខ្មែរនៅពាក់កណ្ដាល៧៦ នៅពេលដែលមានការដោះដូរប្រជាជនវៀតណាម ហើយនិងខ្មែរ។ អ៊ីចឹងខ្ញុំចង់ឲ្យអ្នកស្រីបញ្ជាក់ថាមួយណាត្រឹមត្រូវ? អ្នកស្រីឆ្លើយអម្បាញ់មិញនេះថាអ្នកស្រីនៅប្រទេសកម្ពុជាទេនៅក្រោយឆ្នាំ៧៥។ អ៊ីចឹងមានន័យថា អ្នកស្រីមិនអាចនៅប្រទេសកម្ពុជាផងនៅប្រទេសវៀតណាមផងក្នុងពេលតែមួយទេ។ អ៊ីចឹងអ្នកស្រីអាចសម្រេចបញ្ជាក់មើលថាតើមួយណាជាសក្ខីកម្មត្រឹមត្រូវរបស់អ្នកស្រី?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយថា នៅក្រោយឆ្នាំ១៩៧៥ហ្នឹង ខ្ញុំអត់បាននៅវៀតណាមមែនពិត ប៉ុន្តែនេះជាការភ័ន្តច្រឡំរបស់ខ្ញុំទេ។ ខ្ញុំបាននៅត្រពាំងធំខាងជើងហ្នឹងមែនពិត។

**ស៖** បាទសូមអរគុណ។ ទាក់ទងចំណុចមួយទៀត អម្បាញ់មិញនេះខ្ញុំបានស្ដាប់ឮអ្នកស្រីនិយាយអំពីទំនប់តាគុយ បាទ។ ហើយនៅក្នុងសក្ខីកម្មរបស់អ្នកស្រីដដែល ដែលមានលេខ D22/2161 ត្រង់ ERN ជាភាសាខ្មែរ 00546430, ភាសាអង់គ្លេស 01069536 លោកស្រីបានរៀបរាប់ថា ខ្ញុំសូមដកស្រង់៖ “នៅឆ្នាំ១៩៧៨ ពួកប្ដូរ (អត់ដឹងថាពួកណាទេ) ប្ដូរខ្ញុំឲ្យទៅនៅទំនប់តាស៊ុយ រហូតដល់ថ្ងៃ

រំដោះ"។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា តើទំនប់តាគុយ ឬទំនប់តាស៊ុយ? អ្នកស្រីជាទំនប់មួយណាដែលអ្នកស្រីបានធ្វើការឬក៏ទៅរស់នៅនោះ?

**ឆ៖** ចាស ពេលនោះ ខ្ញុំនៅទំនប់តាស៊ុយ ព្រោះអីគេហៅ "ពោធិ៍រីស៊ុយ ឬទំនប់តាស៊ុយ"។ ព្រោះអីខ្ញុំមិនបានចាំច្បាស់ដែរ។ ព្រោះអីខ្ញុំមិនដឹងថា គេហៅពិតប្រាកដមួយណា។ តែខ្ញុំហៅថា ទំនប់តាស៊ុយ ទំនប់តាគុយ អ៊ីចឹងដែរទៅ។

**ស៖** អ្នកស្រីអាចបញ្ជាក់ឲ្យច្បាស់ទេថា គេហៅតែឈ្មោះណាមួយ ឬក៏គេហៅឈ្មោះទាំងពីរ?

[០៩:៥៣:១៣]

**ឆ៖** ចាស បើតាមពាក្យនិយាយថា ច្រើនជាងនោះ គឺជា "ទំនប់តាស៊ុយ"។

**ស៖** បាទ សូមអរគុណ។ មួយទៀតទាក់ទងទៅនឹងក្រុមការងាររបស់អ្នកស្រី អ្នកស្រីបានឆ្លើយជាមួយនឹងមេធាវីរបស់អ្នកស្រីពីម្សិលមិញថាអ្នកស្រីនៅក្នុងកងចល័ត។ ខ្ញុំចង់បញ្ជាក់ថាតើអ្នកស្រីនៅក្នុងកងចល័តអ៊ីចឹងមែន ឬមួយក៏នៅក្នុងកងកុមារ? ពីព្រោះនៅក្នុងឯកសារដែលអ្នកស្រីបានបញ្ជាក់ពីមុននោះ នៅក្នុងឯកសារដែលខ្ញុំអានមុនអម្បាញ់មិញនេះ លោកស្រីបញ្ជាក់ថាលោកស្រីនៅកងកុមារ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា ជាកងចល័ត ឬកងកុមារ។

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ថា កងចល័ត កងកុមារនេះ មួយកងកុមារ មួយកងចល័ត ប៉ុន្តែកងកុមារខ្ញុំហ្នឹង គេបង្ខិតបង្ខំដូចជាកងចល័តដែរ។

**ស៖** អម្បាញ់មិញ អ្នកស្រីបានស្គាល់ប្រធានកងចល័តរបស់អ្នកស្រីឈ្មោះ រុំ តើអ្នកស្រីនៅក្នុង -- (សូមទោស) កងកុមាររបស់អ្នកស្រីឈ្មោះ រុំ។ អ៊ីចឹងអ្នកស្រីមានដែលផ្លាស់ប្តូរកងកុមារ ពីកងមួយទៅកងមួយទៀតទេ? ហើយមានអ្នកណាជាមេកងរបស់អ្នកស្រីបើសិនជាមាន?

**ឆ៖** ចាស ខ្ញុំអាចផ្លាស់ប្តូរកងពីមួយកន្លែងទៅមួយកន្លែងបាន ប៉ុន្តែប្រធានកងខ្ញុំនៅតែដដែល ហើយផ្លាស់នោះក៏មិនឆ្ងាយពីគ្នាដែរ នៅក្នុងភូមិ គ្រាន់ថា មួយភូមិនេះភូមិនោះ នៅជិតៗហ្នឹងទេ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីស្គាល់ឈ្មោះ ថៅ នី ទេ?

**ឆ៖** ចាស ថៅ នី ស្គាល់។

**ស៖** អ្នកស្រីធ្លាប់ស្គាល់គាត់ពីពេលណាដែរ?

**ឆ៖** ចាស ខ្ញុំមិនបានចាំថ្ងៃខែផង ព្រោះអី ខ្ញុំអត់សូវចេះអក្សរផង ខ្ញុំ។

**ស៖** អ្នកស្រីមានទំនាក់ទំនងអ្វីជាមួយនឹងការដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹង

ឈ្មោះ ចៅ នី ហ្នឹងដែរទេ?

[០៩:៥៦:៤១]

**ឆ៖** ចាស ខ្ញុំបានទំនាក់ទំនងដាក់ពាក្យបណ្ដឹងជាមួយគាត់មែនពិត។

**ស៖** អ្នកស្រីអាចពន្យល់បានទេថា ចៅ នី បានជួយការងារអ្វីខ្លះដល់អ្នកស្រីក្នុងការរៀបចំពាក្យបណ្ដឹងនេះ?

**ឆ៖** ចាស--

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមើលឃើញថា យើងហួសវិសាលភាពនៃការថ្លែងទុក្ខសោកហើយនិងអង្គហេតុហើយ។ ឥឡូវនេះ <ពេលវេលារបស់គាត់ដែលអង្គជំនុំជម្រះផ្ដល់ឲ្យគាត់នោះក៏អស់ដែរ>។ មើលទៅឃើញថា ខាងមេធាវីការពារក្ដីហាក់ដូចជា<ដក់>អារម្មណ៍ទៅនឹងលោក ចៅ នី ហ្នឹងតែម្ដង។ ខ្ញុំ<ពុំមានបញ្ហាអ្វីចំពោះការ>ចោទសំណួរ<របស់គាត់នោះទេ ប៉ុន្តែប្រសិនបើគាត់សួរសំណួរ>ដដែលៗ<>អ៊ីចឹង <ខ្ញុំគិតថា>ដូចជាមានបញ្ហាហើយលោកប្រធាន។

[០៩:៥៧:៥៤]

**លោក គង់ សំអុន៖**

ខ្ញុំបានលើកពីចំណុច ចៅ នី នេះ ជាច្រើនលើកជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ ជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណីដែលមានទំនាក់ទំនងទៅនឹងខ្មែរកម្ពុជាក្រោម។ បញ្ហាគឺថាវាមានភាពមិនប្រក្រតីនៅក្នុងការរៀបចំឯកសារ។ អានេះហើយដែលឯកសារនីមួយៗនេះ មានឈ្មោះ ចៅ នី ជាសាក្សីផង។ អ៊ីចឹងភាពជឿទុកចិត្តបាននៃឯកសារនេះវាចំណោទធំណាស់ សម្រាប់យកមកពិចារណាថាតើតុលាការគួរជឿទៅលើសក្ខីកម្មដែលបានរៀបចំទាំងឡាយពាក់ព័ន្ធនឹងឈ្មោះ ចៅ នី ដែរឬទេ? នេះហើយជាបញ្ហាដែលយើងកំពុងតែព្យាយាមស្វែងរកនូវការពិត នូវភាពដែលអាចជឿទុកចិត្តបាននៃឯកសារមានជាប់ពាក់ព័ន្ធនឹងឈ្មោះ ចៅ នី នេះ។ ហើយដូច្នេះបានជាយើងខ្ញុំតែងលើកតាំងសំណួរនេះឡើង។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[០៩:៥៨:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យខ្ញុំធ្វើអន្តរាគមន៍នៅក្នុងបញ្ហានេះ។ ប្រហែលជាខ្ញុំអាចយល់ច្រឡំ<ហើយសុំជួយកែតម្រូវខ្ញុំផងបើដូច្នោះមែន។> <វា>ដូចជាលើកទី៣ហើយ ដែលដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ខ្លួនជាខ្មែរក្រោម ក៏ប៉ុន្តែតាមការពិត<គាត់>កើតនៅក្នុងទឹកដីកម្ពុជានេះទេ។ ឥឡូវនេះ ខ្ញុំយល់ថាវាលឿនបន្តិចហើយ ក្នុងការធ្វើសេចក្តីសន្និដ្ឋានជាបឋមទៅលើបញ្ហា។ ក៏ប៉ុន្តែខ្ញុំយល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីដែល អះអាងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថាជាខ្មែរក្រោម តាមពិត<គាត់>មិនមែនជាខ្មែរក្រោមទេ។ ខ្ញុំគិតថា ប្រហែលជាវាពេលវេលាមួយដែលសមស្របហើយ ដែលអង្គជំនុំជម្រះគួរសួរទៅ<មេធាវីនៃ>ដើមបណ្តឹងរដ្ឋប្បវេណីថា វាមានបញ្ហាអ្វីកំពុងតែកើតឡើងនៅត្រង់នេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបន្ថែមលើការកត់សម្គាល់លើសហភាតារបស់ខ្ញុំ។ ខ្ញុំសូមឆ្លើយទៅនឹងការជំទាស់របស់សហភាតារបស់ខ្ញុំ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ <ប្រាកដណាស់ ខ្លួនខ្ញុំផ្ទាល់ក៏បានធ្វើបែបនេះដែរក្នុងពេលសួរដេញដោលសាក្សីម្នាក់ ដែល>ទម្រង់<សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី>គឺថា មានឈ្មោះ ចៅ នី ដែរ។ នៅពេលដែលយើង<>ប្រៀបធៀប<ជាមួយទម្រង់ព័ត៌មានជនរងគ្រោះនៅពេលស្តាប់>ចម្លើយនៅសវនាការនេះ<គឺថាមានភាពខុសគ្នា ពាក់ព័ន្ធនឹង ថាជាខ្មែរ>ក្រោម <ឬក៏មិនមែននោះ>។ <ខ្ញុំមិនគិតថាអ្វីដែលខាងយើងខ្ញុំសួរហួសហែនេះមិនខាតពេលឥតប្រយោជន៍ទេ។ ផ្ទុយទៅវិញខ្ញុំយល់ឃើញថានេះជាធាតុផ្សំមួយដែលគប្បីពិនិត្យឲ្យបានច្បាស់ពីតម្លៃរបស់ភស្តុតាង ឬភាពទុកចិត្តបានជាទូទៅនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី>។ <ដូច្នេះហើយបានជាយើងចំណាយពេលវេលាលើបញ្ហានេះ ដោយសារមានឈ្មោះ> ចៅ នី នេះ<>នៅលើទម្រង់បែបបទ<ដែលយើងមាន>ទាំងអស់<>។

[១០:០១:០១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

លោកប្រធានខ្ញុំសូមបន្ថែម។ អ៊ីចឹងត្រូវហើយមានឈ្មោះ ថៅ នី ហ្នឹងនៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ<។ នេះជារឿងពិត ហើយក៏គ្មានអ្វីត្រូវលាក់បាំងឡើយ> ព្រោះឈ្មោះនេះបញ្ជាក់ហើយថា គាត់ជាសាក្សីនៅពេល<បំពេញ>ទម្រង់បែបបទទាំងអស់នេះដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង <ដូច្នេះជាមូលដ្ឋាននៅក្នុងទម្រង់ទាំងនេះ ជនរងគ្រោះបានផ្ដល់ឈ្មោះគាត់ជាសាក្សីគ្រប់ៗគ្នា>។ <>ការិយាល័យសហចៅក្រមស៊ើបអង្កេត<បានសម្រេចចិត្ត>ទទួលយក<ពួកគេជាដើមបណ្ដឹងរដ្ឋប្បវេណី។ សេចក្ដីសម្រេចនេះធ្វើឡើង>នៅចុងឆ្នាំ២០១០។ ហើយកាលនោះក៏មេធាវីការពារក្ដីនោះមានលទ្ធភាពអាចប្ដឹងឧទ្ធរណ៍បានទៅលើរាល់ការទទួលនៃពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយបើឥឡូវនេះអង្គជំនុំជម្រះគិតថា<សួរសំណួរ>ពាក់ព័ន្ធ<នឹងឈ្មោះ> ថៅ នី នេះ <បាន> ខ្ញុំមិនមានការជំទាស់អីទេ<>។

**កញ្ញា អង់តា ហ្គីសសេ៖**

<សូមអនុញ្ញាតលោកប្រធាន> ខ្ញុំសូមបញ្ជាក់បន្តិច។ បញ្ហាហ្នឹងគឺថា មិនមែនថាត្រូវយើងជំទាស់លើភាពទទួលយកបាននៃឯកសារនោះទេ <ប៉ុន្តែយើងមានឯកសារនៅពេលនោះមិនទាន់មានឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ។ នៅពេលដែលគាត់>មក<ផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ> គឺគាត់ឆ្លើយខុសពីអ្វីដែល<គាត់បានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំនិយាយថា "យើងមានឯកសារ" គឺថាខ្ញុំសំដៅលើលក្ខណៈទូទៅ ព្រោះ>យើង<>មិនមានវត្តមាននៅពេលដែលដំណាក់ស៊ើបអង្កេតនោះទេ។ ក៏ប៉ុន្តែ<រហូតដល់បានស្ដាប់សក្ខីកម្ម>ពេលសវនាការ<ថ្ងៃ>នេះ<ទើប> បានយើងឃើញថាមានភាពខុស។ <ទាល់តែនៅចំពោះមុខអង្គជំនុំជម្រះទើបយើងអាចសួរដេញដោលទៅទើបដឹង។ ដូច្នេះសូមមេត្តាកុំរិះគន់ថាម៉េចក៏មិន>ប្ដឹង<ទៅ។ យើងមិនអាចប្ដឹងបានទេព្រោះកាលណោះវាស្ថិតនៅក្នុង>ដំណាក់កាលស៊ើបអង្កេត<នៅឡើយតែប៉ុណ្ណោះ>។

[១០:០២:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៤:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូម<ឲ្យ>បំភ្លឺចំណុចមួយចំនួន។ លោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ៍ តើ ថៅ នី នេះគាត់ដើរតួនាទីអ្វីដែរ ក្នុងការជួយដល់ជនរងគ្រោះ<ខណៈដែលគេរៀបចំសំណុំបែបបទដើម្បីដាក់>ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកចៅក្រម ខ្ញុំមិនអាចឆ្លើយបានទេនៅពេលនេះ ព្រោះថាខ្ញុំជាមនុស្សថ្មីនៅទីនេះដែរហើយខ្ញុំ<ផ្ទាល់>មិនស្គាល់ លោក ថៅ នី នោះទេ។ ក៏ប៉ុន្តែខ្ញុំអាចព្យាយាមរកព័ត៌មាន ហើយនិងផ្តល់ដំណឹងជូនតុលាការបាន<នៅពេលរសៀលនេះប្រសិនបើខ្ញុំរកបាន>។ <ទាក់ទងទៅនឹងអ្វីដែល ថៅ នី ចូលរួម គឺមិនខុសគ្នាពីអង្គការ>អន្តរការី<។ ព្រោះ>ភាគច្រើននៃដើមបណ្តឹងរដ្ឋប្បវេណី<ទទួលបានការ>ជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ឬក៏អង្គការអន្តរការី<នេះឯង>។ អ៊ីចឹង<គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ>នៅពេលដែលមានឈ្មោះ<បុគ្គលម្នាក់ ឬឈ្មោះអង្គការមិនមែនរដ្ឋាភិបាល>ណាមួយ<ក្នុងប្រព័ន្ធនោះទេ។ម្យ៉ាងវិញទៀតនៅពេលនោះ តុលាការពុំមានគម្រោងថវិកាគ្រប់គ្រាន់សម្រាប់ធានាឲ្យបាននូវការចុះផ្សព្វផ្សាយទេ ដូច្នេះមានតែអង្គការមិនមែនរដ្ឋាភិបាលនោះឯងដែលដើរតួក្នុងការចុះជួបជនរងគ្រោះដើម្បីឲ្យគេបំពេញបែបបទហើយក្លាយដើមបណ្តឹងរដ្ឋប្បវេណី>។

បើសិនជាអង្គចំនុំជម្រះចង់ដឹងថា តើមានអង្គការអន្តរការីណា ឬក៏បុគ្គលណានៅក្នុងអង្គការទាំងអស់នេះដែលមានតួនាទីណាមួយក្នុងការប្រមូល<ព័ត៌មានដើម្បីដាក់>ពាក្យសុំតាំងដើមបណ្តឹងរដ្ឋប្បវេណីនេះ យើងនឹងឆ្លើយតបទៅនឹងសំណើរបស់តុលាការ។ ហើយបើរសៀលនេះ យើងអាចទទួលព័ត៌មានបានគ្រប់គ្រាន់ យើងនឹងផ្តល់ដំណឹងជូនតុលាការ។

[១០:០៦:៣០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បើសិនជាខ្ញុំមិនច្រឡំទេ លោក ថៅ នី នេះបានមកផ្តល់សក្ខីកម្មនៅទីនេះហើយ។ គាត់បានផ្តល់សក្ខីកម្មក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ ហើយបើខ្ញុំមិនច្រឡំទេ គាត់ជាសមាជិក<សកម្មម្នាក់>នៃសមាគមមួយដែលការពារផលប្រយោជន៍របស់ខ្មែរកម្ពុជាក្រោម។ អ៊ីចឹងៗ ខ្ញុំនឹងចង់បានការបញ្ជាក់ពីលោកស្រីមេធាវីនៅពេលក្រោយ<។ យើងក៏ចង់បញ្ជាក់ផងដែរថាធាតុផ្សំ> មាននៅក្នុងសំណុំរឿងហើយ ហើយភាគីទាំងអស់ក៏អាច<រកវាបានផង>ដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<សូមឲ្យកត់ត្រាក្នុងប្រតិចារឹកផងថា>យើងមិនដែល<>ជំទាស់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ថៅ នី នោះទេ។ <>

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀតលោកមេធាវី!

[១០:០៧:៣៩]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ អ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី សំណួរចុងក្រោយរបស់ខ្ញុំមុនពេលដែលយើងពិភាក្សាគ្នាអំមិញនេះ គឺទាក់ទងទៅនឹងការជួយជ្រោមជ្រែងរបស់ ថៅ នី ដល់លោកស្រីក្នុងការរៀបចំពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ ខ្ញុំចង់សួរថាតើលោក ថៅ នី បានជួយ ឬក៏បានប្រឹក្សាយោបល់អ្វីខ្លះដល់លោកស្រី នៅក្នុងពេលដែលមានការរៀបចំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះ?

**លោកស្រី អៀម យេន៖**

**ឆ៖** ចាស ពេលដែលខ្ញុំហើយលោក ថៅ នី បានជួបគ្នានោះ អត់មានថា ផ្ដល់អ្វីឲ្យនាងខ្ញុំទេ ព្រោះអីគាត់បាននិយាយថា ដូចថាមានថាដាក់ពាក្យអីអីចេះមួយអីចេះពីរ ពាក្យអីចឹងទៅ គាត់ក៏មិនដែលផ្ដល់អីឲ្យខ្ញុំដែរ។ ហើយខ្ញុំហ្នឹងក៏ឮសួរថាដាក់ពាក្យបណ្ដឹងអីចឹង ខ្ញុំហ្នឹងក៏ចង់ដាក់ពាក្យតាមហ្នឹងដែរ ខ្ញុំប្រាប់គាត់ថាខ្ញុំចុះឈ្មោះអីចឹងទៅ ដាក់ពាក្យអីចឹងទៅ ព្រោះអីពេលនោះខ្ញុំមានការឈឺចាប់នៅកងកុមារចាស។

[១០:០៨:៥៤]

**ស៖** បាទ សូមអរគុណ។ អ្នកណាអ្នកទៅរកអ្នកស្រី? ថៅ នី នេះមកទាក់ទងអ្នកស្រីដោយផ្ទាល់ ឬមួយមានបញ្ហាអីផ្សេង?

**ឆ៖** ចាស ពេលនោះអត់មានអ្នកណាទេ ខ្ញុំជួបគាត់តែម្ដង អីចឹងម្ដង។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់បញ្ជាក់ថា ធ្វើម៉េចបានមានការទំនាក់ទំនងគ្នា ស្គាល់គ្នាថា អ្នកស្រីត្រូវរៀបចំពាក្យបណ្ដឹង? ថៅ នី គាត់មកណែនាំលោកស្រី ឬក៏អ្នកស្រីទៅជួប ថៅ នី?

**ឆ៖** ចាស ពេលនោះលោក ថៅ នី ហ្នឹងគាត់បាននិយាយណែនាំអីចឹងដែរថា បើចង់ដាក់ពាក្យដាក់អីចឹង ដូចថាយើងមានការឈឺចាប់។ ហើយខ្ញុំហ្នឹងក៏ ពេលគាត់ជួបគាត់និយាយអីចឹងទៅ ខ្ញុំហ្នឹងក៏ថា ខ្ញុំចង់ដាក់ពាក្យអីចឹង។

**ស៖** បាទ ទាក់ទងនឹងព័ត៌មានដែលអ្នកស្រីបានផ្តល់នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់អ្នកស្រី តើអ្នកស្រីបានព័ត៌មានទាំងអស់នោះចេញពីខ្លួនឯង ឬមានការចូលរួមរៀបចំផ្តល់យោបល់ពីលោក ថៅ នី ដែរ?

[១០:១០:៣២]

**ឆ៖** ចាសខ្ញុំដូចជាក្តាប់មិនបាន។ ប្រហែលជាគាត់និយាយពីរឿងថាខ្ញុំចង់ដាក់ពាក្យពេលខ្ញុំមានការឈឺចាប់នៅក្នុងជំនាន់នោះ ឬមួយគាត់ចង់សួរខ្ញុំថា មានអ្នកណែនាំឲ្យខ្ញុំហ្នឹងនិយាយអ៊ីចឹង ហើយក៏មិនមែន ខ្ញុំចង់សួរអ៊ីចឹង ខ្ញុំស្តាប់មិនបាន។

**ស៖** បាទ សំណួររបស់ខ្ញុំគឺថា ព័ត៌មានដែលមាននៅក្នុងទម្រង់ឯកសារអំពីជនរងគ្រោះរបស់អ្នកស្រីនេះ ខ្ញុំចង់ដឹងថាតើអ្នកស្រីជាអ្នកផ្តល់ព័ត៌មានទាំងអស់ ឬក៏មានការណែនាំផ្នែកណាមួយពីលោក ថៅ នី ក្នុងការផ្តល់ព័ត៌មាន ក្នុងការរៀបចំតាក់តែងជាពាក្យបណ្តឹងហ្នឹង ជាទម្រង់ហ្នឹងឡើង?

**ឆ៖** ចាស នៅពេលនោះ ព័ត៌មានទាំងប៉ុន្មានហ្នឹង ខ្ញុំជាអ្នកនឹកឃើញ គិតឃើញខ្លួនឯងទេ អត់មាន ថៅ នី តាក់តែងទេ។

**ស៖** បាទ អ៊ីចឹងអ្នកស្រីអាចពន្យល់បានទេ ហេតុអីបានជាមានព័ត៌មានខុសៗពីអ្វីដែលអ្នកស្រីបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** ចាស ព្រោះមានព័ត៌មានខុសហ្នឹងបានខ្ញុំថា ខ្ញុំចាំមិនបានពេលនោះ ខ្ញុំវាងភ្លេចភ្លាំង ខ្ញុំចាំមិនបានដែរ។ ចាំបានពេលណាដែលខ្ញុំចាំបាន ដូចខ្ញុំប្រាប់លោកអ៊ីចឹង។

[១០:១២:១១]

**ស៖** អ្នកស្រីមានអ្នកផ្សេងទៀតណែនាំទេ ក្រៅពី ថៅ នី?

**ឆ៖** ចាស បើតាមនេះ អត់មានអ្នកផ្សេងណាណែនាំទេ ខ្ញុំជួបតែ ថៅ នី ពេលគាត់បានទៅប្រាប់ខ្ញុំថាដាក់ពាក្យ ដាក់អី ខ្ញុំអត់មានជួបអ្នកណាផ្សេងទៀតទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោកស្រី អៀម យេន។ សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

01086622



ដល់ពេលនេះបានដល់ទីបញ្ចប់ហើយ ហើយលោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីវិលត្រឡប់ប្រកបដោយសុវត្ថិភាព។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និង អ្នកជំនាញក្នុងការជូនលោកស្រី អៀម យេន វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអរគុណចំពោះបុគ្គលិកអង្គការ ធី.ភី.អូ។

ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់និងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅសវនាការបន្ទាប់នេះ អង្គជំនុំជម្រះនឹងស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-288 ហើយមួយទៀតក៏សូមបញ្ជាក់ថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមផ្តល់ព័ត៌មានឲ្យបានច្បាស់លាស់អំពីករណីពាក់ព័ន្ធទៅនឹង ចៅ នី នេះ នៅរសៀលនេះ អង្គជំនុំជម្រះចង់ដឹងពីបញ្ហានេះ សូមជ្រាប។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-288 រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនា នៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សូមរំឭកជម្រាបជូនដល់ភាគីជ្រាបថា នៅក្នុងការសួរដេញដោល សួរនាំពាក់ព័ន្ធជាមួយនឹងបញ្ហាស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដើមបណ្តឹងរដ្ឋប្បវេណី ចំនួនដែលនៅសេស

សល់នេះ សូមផ្ដល់ការតាំងសំណួរ ពាក់ព័ន្ធទៅនឹងស្ថានភាពព្យសនកម្ម និងទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។

ហើយប្រសិនបើមានភាពពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលលៀនចេញដោយសារការការឆ្លើយបំភ្លឺពាក់ព័ន្ធជាមួយនឹងព្យសនកម្ម និងស្ថានភាពនៃទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺសុំឲ្យ -- អាចសួរពាក់ព័ន្ធទៅផ្នែកដែលលៀនចេញហ្នឹងប៉ុណ្ណោះ។ ហើយក៏ឲ្យកំហិតផងដែរ នូវកំហិតកំណត់ឲ្យបានអប្បបរមា ដោយសារមូលហេតុ -- បញ្ហាពាក់ព័ន្ធនឹងសំណួរអំពីទម្រង់នៃបណ្ដឹង ដោយសារមូលហេតុបណ្ដឹងទាំងអស់នេះត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយ។ គ្មានហេតុផលអ្វីដែលអង្គជំនុំជម្រះយកមកពិចារណាដើម្បីកាត់ចេញនូវដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ ចេញពីបញ្ជីនៃដើមបណ្ដឹងរួម បណ្ដឹងបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះឡើយ។ ព្រោះនៅក្នុងវិធានបានចែងច្បាស់លាស់ ហើយខាងអង្គ -- សហព្រះរាជ -- សហចៅក្រមស៊ើបអង្កេត ក៏ដូចជាខាងអង្គបុរេជំនុំជម្រះ បានសម្រេចលើបញ្ហានេះរួចហើយ ជាហើយចូលស្ថាពររួចហើយ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី! តើលោកឈ្មោះអី?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ អរគុណ។ ខ្ញុំបាទឈ្មោះ ថាន់ ធីម។

**ស៖** លោក ថាន់ ធីម តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** បាទ ខ្ញុំបាទ កើតនៅថ្ងៃទី០៤ ខែមេសា ១៩៤៥។

**ស៖** ហើយលោករស់នៅទីកន្លែងណាសព្វថ្ងៃនេះ?

**ឆ៖** --

**ស៖** កុំៗអាលទាន់ឆ្លើយតប។

[១០:៣៦:០២]

**ឆ៖** បាទ សព្វថ្ងៃនេះ ខ្ញុំបាទរស់នៅភូមិទួលពង្រ ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** បាទ ខ្ញុំបាទជាកសិករធ្វើស្រែ។

**ស៖** ឪពុករបស់លោក គាត់ឈ្មោះអី?

**ឆ៖** បាទ ឪពុករបស់ខ្ញុំបាទ ឈ្មោះ ម៉ែន ថាន់។

**ស៖** ចុះម្ដាយរបស់លោក គាត់ឈ្មោះអី?

**ឆ៖** បាទ ម្ដាយរបស់ខ្ញុំបាទឈ្មោះ ប្រេស អាត់ ។

**ស៖** ប្រពន្ធរបស់លោក គាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាទឈ្មោះ ហិន ថូន។ មានកូនប្រាំមួយនាក់។

**ស៖** អរគុណលោក ថាន់ ធីម ។ ហើយក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកដើម្បីថ្លែងរៀបរាប់ដល់ -- ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលមានចំពោះលោក។ ជាអាទិ៍ ដូចជាខាងផ្លូវចិត្ត ផ្លូវកាយ ឬក៏សម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលកើតឡើងពិតប្រាកដរហូតដល់សព្វថ្ងៃនេះ។ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងនេះ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់លើជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលប៉ះពាល់ចំពោះលោកក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ សូមជ្រាប។

ហើយដោយសារមានការកែសម្រួលនូវបែបនីតិវិធីក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីរៀបតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី អំពីស្ថានភាពព្យសនកម្មនិងទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១០:៣៨:៤៣]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមគោរពលោក ថាន់ ធីម ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី។ នៅពេលនេះ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា និងជាមេធាវីរបស់លោកពូផងដែរ។

ជាបន្ទាប់មកនេះ ខ្ញុំសូមជម្រាបសួរសំណួរមួយចំនួនដែលពាក់ព័ន្ធនឹងការឈឺចាប់របស់លោកពូ។ ដំបូងថា តើនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកពូនៅកន្លែងណាដែរ?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ នៅថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំបាទនៅជំរំជនភៀសខ្លួន អូរបែកក្អម ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ចុះនៅថ្ងៃនុ៎ងដែរ មានព្រឹត្តិការណ៍អីកើតឡើង បន្ទាប់មកហ្នឹង?

**ឆ៖** បន្ទាប់ពីពួក ប៉ុល ពត បានទទួលជ័យជម្នះនៅថ្ងៃនោះ គេជម្លៀសខ្ញុំបាទទៅៗនៅដល់ភូមិស្វាយវល្លិ៍ ភូមិកំពែង ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** អរគុណ។ ថាតើនៅពេលដែលលោកពូបានទៅដល់ភូមិស្វាយវល្លិ៍នោះ គេបានចាត់ខាងក្រុមគ្រួសារ ឬមួយលោកពូហ្នឹងទៅនៅទីនោះហើយៗ គេឲ្យធ្វើការងារអ្វីដែរ?

**ឆ៖** បាទ បន្ទាប់ដែលគេជម្លៀសខ្ញុំទៅដល់ភូមិស្វាយវល្លិហ្នឹង គេឲ្យខ្ញុំហ្នឹងនៅខាងកសិករខាងធ្វើស្រែ ឲ្យខ្ញុំរែកដីដំបូក ឲ្យខ្ញុំធាក់រហាត់ទឹក ក្នុងដីមួយហិកតា គេឲ្យពួកខ្ញុំធ្វើតែគោបីនឹមទេ ឲ្យធ្វើឲ្យហើយទាំងភ្លួរនិងរាស់ ធ្វើម៉េចឲ្យបានដីគេស្ទូងបាទ។

**ស៖** បាទ អរគុណ។ ចុះបន្ទាប់មកទៀតនៅក្នុងឆ្នាំ១៩៧៦ តើបានធ្វើការងារនៅក្នុងខេត្ត ឃុំណាដែរបាទ?

**ឆ៖** បាទ នៅក្នុងឆ្នាំ១៩៧៦ហ្នឹង គេជម្លៀសខ្ញុំមកនៅភូមិជីម្រាក់ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវដដែល។ គេឲ្យខ្ញុំធ្វើស្រែដដែល ភ្លួរស្រែ ភ្លួរអីចឹង មួយហិកតា ធ្វើបីនឹមហ្នឹងបាទ រែកដីដំបូករហាត់ទឹកអី ធាក់រហាត់ទឹកអីហ្នឹង។

**ស៖** បាទ អរគុណ។ អ៊ីចឹងមកដល់ឆ្នាំ១៩៧៨ តើលោកពូបានផ្លាស់ទៅធ្វើការងារនៅក្នុងកងណា ហើយមានព្រឹត្តិការណ៍អ្វីខ្លះកើតឡើងនៅក្នុងឆ្នាំនោះបាទ?

[១០:៤៣:១៦]

**ឆ៖** អ៊ីចឹង នៅឆ្នាំ១៩៧៧ គេជម្លៀសខ្ញុំមួយកន្លែងទៀត មកនៅភូមិត្រពាំងត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ ពេលនោះគេឲ្យខ្ញុំហ្នឹងនៅកងរទេះដឹកជញ្ជូនបាទ ហើយដល់រួចទៅមានថ្ងៃមួយនោះខ្ញុំ គេឲ្យក្រុមខ្ញុំហ្នឹងទៅដឹកឈើនៅភូមិបោសតាផង់បាទ ឈើហុប។ ដល់មកពីហ្នឹងវិញម៉ោងប្រហែលជាប្រាំពីរ ប្រាំបីយប់ហ្នឹង គេក៏ឲ្យខ្ញុំដាក់ឈើហុបឈើអីនៅមួយកន្លែងអ៊ីចឹងទៅ ហើយខ្ញុំក៏បររទេះមកកន្លែងកងហ្នឹងវិញ។ ដល់មកដល់ហ្នឹងកន្លែងកងហ្នឹង ហូបបបរហូបអីហើយអ៊ីចឹងទៅក៏

ឡើងទៅបម្រុងនឹងសម្រាន្ត មិនទាន់ទម្លាក់ខ្នងហ្នឹងដល់រនាបផង ប្រធានកងហ្នឹងឈ្មោះគាត់ តាប៉ុន បាទ ប្រធានកងរទេះហ្នឹង គាត់ហៅខ្ញុំបាទហ្នឹងថា "បងធីម មកជូនខ្ញុំទៅប្រជុំមួយភ្លែត"។ ហើយខ្ញុំ ក្នុងចិត្តខ្ញុំនឹកថា ពួកមូលដ្ឋានគេមិនដែលហៅ១៧ហ្នឹងទៅប្រជុំទេ។ ខ្ញុំបាទហ្នឹងក៏ចុះពីលើផ្ទះ កន្លែងកងគេហ្នឹងលើផ្ទះ -- ផ្ទះហ្នឹងនៅលើ ខ្ញុំក៏ចុះមក។ ដល់ចុះមកអ៊ីចឹង គេថា តោះដើរមុខ -- គាត់នាំមុខខ្ញុំ។ ថា "មកជូនខ្ញុំទៅប្រជុំភ្លែត"។ ដល់អ៊ីចឹងទៅ គាត់នាំខ្ញុំទៅកន្លែងឈ្លប។ ទៅដល់កន្លែងឈ្លបហ្នឹង ឈ្លបហ្នឹងគេចេញមក បញ្ចូលបួននាក់ទៅប្រាំនាក់ បាទ។ ចេញមកចាប់ឱបខ្ញុំបាទជាប់ ចាប់ឱបខ្ញុំបាទអ៊ីចឹងហើយគេយកខ្សែគោហ្នឹងយកមកចងខ្ញុំបាទហ្នឹង ចងស្លាបសេកហ្នឹងទៅក្រោយបីចំណាង បាទ បីចំណាង។ បីចំណងអ៊ីចឹងទៅ ដល់រួចទៅ បន្ទាប់មក ខ្ញុំនឹកថាខ្ញុំស្លាប់ហើយពេលហ្នឹង គ្មានរស់ទេ ព្រោះស្លាប់ដោយអត់មានទោសកំហុសអីសោះ។ បាទ ដល់រួចទៅគេវ៉ៃខ្ញុំហ្នឹង ម្នាក់ចូលអ៊ីចឹង វ៉ៃដួលត្រលប់ត្រលិនអ៊ីចឹងទៅ គេសួរចម្លើយ "អ្ហែង!នៅភ្នំពេញ នៅធ្វើស្អី? អ្ហែង ឆ្លើយប្រាប់គេឲ្យត្រង់មក"។ ពួកប៉ុល ពត វានិយាយមកយើងអ៊ីចឹង វាថា អត់មានក្រមសីលធម៌អីទេ នៅក្នុងខ្លួនវាហ្នឹង វាសុទ្ធ"អ្ហែង" អ៊ីចឹងហ្នង។ "អ្ហែង នៅក្រុងភ្នំពេញ អ្ហែង ធ្វើអី? អ្ហែង ធ្វើទាហាន ឬមួយក៏ធ្វើអី?"។ ខ្ញុំបាទឆ្លើយប្រាប់គេថា "មិត្តអើយ ខ្ញុំអត់មានធ្វើអីទេ អត់មានធ្វើទាហានទេ។ ខ្ញុំជាកម្មករ។ ខ្ញុំជាអ្នករកស៊ី កាប់ខស កាប់អីលក់។ ខ្ញុំនៅនឹងជំរំហ្នឹង ក៏ខ្ញុំអត់មានធ្វើអីដែរ ខ្ញុំជាកម្មករទេ"។ ដល់អ៊ីចឹងទៅ គេក៏ -- ម្នាក់វ៉ៃអស់ចិត្ត ម្នាក់ចូលមកវ៉ៃទៀត សួរចម្លើយខ្ញុំនៅតែដដែលៗ។ គេថា "អ្ហែងឆ្លើយប្រាប់អញឲ្យត្រង់មក បើអ្ហែង ឆ្លើយប្រាប់អញត្រង់ អញលែងអ្ហែងទៅឥឡូវ"។ ហើយខ្ញុំមិនដឹងស្អី លាតត្រដាងប្រាប់គេឲ្យត្រង់។ ខ្ញុំថា ខ្ញុំជាកម្មករជាអ្នកកាប់ខសកាប់អី លក់អ៊ីចឹងទៅចិញ្ចឹមជីវិតកូនប្រពន្ធហ្នឹង។ ហើយដល់រួចអ៊ីចឹងទៅ គេវ៉ៃអស់ចិត្តគេសួរចម្លើយអស់ចិត្ត បានគេដឹកខ្ញុំបាទតាមរទេះសេះមកនៅម្តុំអង្គរកា។ ម្តុំអង្គរកាហ្នឹង នៅនឹងផ្សារអង្គរកាហ្នឹងតែម្តង ប៉ុន្តែផ្សារអង្គរកាហ្នឹងប្រហែលជាកន្លែងស្រុកគេហើយ ព្រោះកន្លែងស្រុកគេ។ ដល់អ៊ីចឹងគេធាក់ខ្ញុំបាទធ្លាក់ពីលើរទេះសេះអ៊ីចឹងមក។ គេថា គេប្រាប់ម្នាក់ទៀតនៅអង្គរកាហ្នឹង ឈ្មោះគាត់តារស់។ ឈ្មោះ តារស់ៗហ្នឹង គាត់រាងស្រមូមបន្តិច ហើយគាត់ -- ហើយតារស់ ហ្នឹង គាត់ទាញកាំភ្លើងអាការមកពីក្នុងបន្ទប់មក គាត់ថា "តោះដើរទៅលិចទៅ! ដើរកាត់វាលស្រែហ្នឹង ទៅលិចទៅ!" ដល់ខ្ញុំបាទដើរមុខអ៊ីចឹងទៅ ហើយគាត់ហ្នឹងបណ្តើរខ្ញុំតាមក្រោយ ពួកតារស់ហ្នឹង តែម្នាក់ឯងទេ។ ក្នុងចិត្តខ្ញុំនឹកថាបើគាត់សម្លាប់ខ្ញុំ បាញ់មួយគ្រាប់ស្លាប់ អាហ្នឹងខ្ញុំបិទភ្នែកជិតហើយ ខ្ញុំថាអស់ចិត្តហើយ។ ប៉ុន្តែដើរកាត់ស្រែអ៊ីចឹងទៅលិចៗផ្សារអង្គរកាហ្នឹង ស្រាប់មានចង្កៀងផ្លុងៗនៅកន្លែងហ្នឹង នៅកន្លែងនេះ

ហ្នឹង។ ខ្ញុំថាប្រហែលជាកន្លែងរណ្ដៅគេនៅចាំជីកអីសម្លាប់ខ្ញុំនៅកន្លែងហើយ មិនស្រួល។ ដល់ពេលចូលទៅដល់ជិតទៅ បានឃើញមានជារោងមួយ មន្ទីរគុកគេហ្នឹង។ គេសង់ពីឈើ ជញ្ជាំងក្ដារ រនាបក្ដារ។

[១០:៤៩:២៧]

អ៊ីចឹងទៅ ដល់រួចទៅ គេញាត់ខ្ញុំ គេប្រធានឈ្លប -- ប្រធានគុកគេនៅហ្នឹង ឈ្មោះ តាម៉េងៗ ហើយគាត់ចាក់សោចាក់អីទ្វារទៅ បានរុញខ្ញុំចូលទៅក្នុងហ្នឹង ហើយមនុស្សឡើងឲ្យអិលដូចអ៊ីចឹង បាទ មនុស្សនៅជាប់ហ្នឹង។ ដល់រួចទៅគាត់ -- គេក៏ដុតភ្លើងបំភ្លឺអ៊ីចឹងទៅ គេយកអាខ្នោះកងជើងហ្នឹង មកឲ្យខ្ញុំពីរបាទ មកឲ្យខ្ញុំពីរ។ កងជើងគេដាក់ខ្នោះខ្ញុំហ្នឹង។ កងដែកហ្នឹងគេមានចោះរន្ធសងខាង។ អ៊ីចឹងគេដាក់ -- គេយកមកឲ្យពីរអ៊ីចឹងគេមានចាក់សោររនុកនៅឯក្រៅ ហើយគេហូតដែករនុកហ្នឹងចេញមកបាន -- ដល់រួចទៅបានគេយកកងហ្នឹងមកឲ្យខ្ញុំ។ យកមកឲ្យខ្ញុំៗ ជាប់ដៃចំណងទៅក្រោយបីចំណងរឹងក្រញង់ហើយ ខ្ញុំមានដាក់អីកើត គេអ្នកដាក់ឲ្យៗ។ ដល់រួចទៅគេស៊កដែករនុកមកពីក្រៅអ៊ីចឹងមកចូលក្នុងហ្នឹងវិញទៅបាទ។ ជាប់ជើង ជាប់ខ្នោះ ចូលក្នុងខ្នោះហើយបានគេស្រាយចំណងដៃហ្នឹងឲ្យខ្ញុំ។ គ្រាន់តែស្រាយហើយ ដៃហ្នឹងគ្មានដឹងដៃដឹងអីទេ ហើម -- ចុះដៃបីចំណងស្ពាបសេកទៅក្រោយមិនធម្មតា។ បានថា ខ្ញុំវាតូចចិត្តដែរ ខ្ញុំវាអត់មានរឿងទោសកំហុសអីសោះ យកខ្ញុំទៅធ្វើទារុណកម្មបាទ។ យកខ្ញុំទៅធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរយ៉ាងនេះ។ បើមានទោសកំហុសអី ខ្ញុំអត់ខ្លាចទេ ខ្ញុំអត់ខ្លាចនឹងទទួល ប៉ុន្តែខ្ញុំអត់មានទោសកំហុសអីសោះ។ ហើយគេបានដាក់ខ្ញុំនៅកន្លែងហ្នឹងទាំងយប់ទាំងថ្ងៃៗហ្នឹង អត់ឲ្យចេញទៅណាទេ ប្រហែលជា៣ខែ។ ៣ខែហ្នឹងបាន ដល់ពួកគេជាប់មុនៗគេជាប់តែខ្នោះជើងមួយ ជើងម្ខាង ខ្ញុំហ្នឹងជើងទាំងពីរ ដេកបានតែផ្ងារអ៊ីចឹងរហូត រើខ្លួនមិនរួច ពិបាក។

[១០:៥២:២៤]

**ស៖** បាទ សូមអរគុណ។ ថាតើលោកពូបានលើកឡើងអម្បាញ់មិញថា មានឈ្លប មានប្រធានកងឈ្មោះ ប៉ុន។ ថាតើពេលដែលគេចាប់ហ្នឹងមានខាងកងឈ្លបហ្នឹងឈ្មោះអីខ្លះដែរ? បើបានស្គាល់អាចជម្រាបអង្គជំនុំជម្រះបានបាទ។

**ឆ៖** បាទ ប្រធានឈ្លបហ្នឹងឈ្មោះគាត់ តាសេ ឈ្មោះ សេ។ សេ ហ្នឹងគាត់នៅក្មេងដែរទេ ហើយកូនឈ្លបប្អូននាក់ទៀតនុ៎ង ខ្ញុំអត់ស្គាល់ឈ្មោះទេ ខ្ញុំអត់ស្គាល់ទេ។

**ស៖** បាទ អរគុណ។ ចុះលោកពូថាពេលដែលគេចាប់ហើយ គេចង ហើយគេយកមកវ៉ៃ។ តើគេយកស្អីដែរទៅវ៉ៃលោកពូហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ គេវ៉ៃខ្ញុំបាទនឹងដំបងពីងពង់ ឫស្សីពីងពង់យើង ឫស្សីតាន់ ប៉ុនភ្លៅដៃហ្នឹង សំពងតែម្តង។ អាហ្នឹងគេវ៉ៃសួរចម្លើយ វ៉ៃនឹងឫស្សីពីងពង់។

**ស៖** បាទ អរគុណ។ តើនៅពេលដែលគេវ៉ៃនោះ លោកពូថា វ៉ៃពីម្នាក់ទៅម្នាក់។ បានន័យថាគេវ៉ៃផ្លាស់ប្តូរគ្នារហូតទៅដល់លោកពូហ្នឹង យ៉ាងម៉េចនៅពេលនោះ?

**ឆ៖** បាទ គេវ៉ៃផ្លាស់ប្តូរគ្នា ព្រោះថាគ្នាគេប៉ុន្មាននាក់ហ្នឹងគេ -- អាមួយវ៉ៃហត់អ៊ីចឹងទៅ មួយចូលវ៉ៃទៀត មួយវ៉ៃហត់ ចូលវ៉ៃ ទាល់តែខ្ញុំហ្នឹងសន្លប់ទៅបានដឹងខ្លួនឡើងវិញ បានគេដឹក អ៊ីចឹងទៅ *(ឮមិនច្បាស់)* កងរទេះសេះ ដឹកទៅផ្សារអង្គរកាដាក់គុកហ្នឹង។

[១០:៥៤:៣៩]

**ស៖** បាទ ចុះលោកពូម៉េចដឹងថាគេបញ្ជូនទៅអង្គរកាហ្នឹង? ម៉េចស្គាល់ថាកន្លែងហ្នឹងជាអង្គរកា?

**ឆ៖** បាទ ខ្ញុំទៅដំបូងហ្នឹង ខ្ញុំមិនដឹងថាកន្លែងហ្នឹងជាអង្គរកាអីទេ ប៉ុន្តែដល់ទៅនៅជាប់គុកហើយហ្នឹង ដល់ពេលខ្ញុំចេញធ្វើគ្រប់៣ខែហ្នឹង ខ្ញុំឆ្លើយមិនទាន់អស់ ប៉ុន្តែឥឡូវលោកមេធាវីសួរហ្នឹងក៏ខ្ញុំឆ្លើយតាមហ្នឹងទៅ ព្រោះថាមុនដំបូងមិនស្គាល់ថាកន្លែងហ្នឹងជាមន្ទីរស្រុកគេ ហើយកន្លែងហ្នឹងជាផ្សារអង្គរកាអីទេ។ ដល់ចេញធ្វើការហ្នឹង គេឲ្យខ្ញុំបាទហ្នឹងមកជីកស្រះនៅពីមុខផ្សារអង្គរការហ្នឹងបានខ្ញុំបាទដឹងបាទ។ ឮគេនិយាយអ៊ីចឹង គេនិយាយថាផ្សារអង្គរកា។

**ស៖** បាទ អរគុណ។ លោកពូថានៅពេលទៅដល់អង្គរកាហ្នឹង ស្គាល់ឈ្មោះ ម៉េង – ថាម៉េងហ្នឹងជាប្រធាននៅទីនោះ។ ចុះនៅក្នុងហ្នឹងមានស្គាល់នរណាផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំទៅដល់អាកន្លែងគុកគេហ្នឹង ស្គាល់ហ្នឹង ដល់នៅរយៈពេល៣ខែនៅក្នុងគុកហ្នឹងទាំងយប់ទាំងថ្ងៃហ្នឹង ខ្ញុំអត់ស្គាល់នរណាជានរណាទេ ដល់បានចេញធ្វើការទៅបានស្គាល់ៗថាប្រធានគេឈ្មោះ ម៉េង, បន្ទាប់មកឈ្មោះ ឈឿង, បន្ទាប់មកទៀតឈ្មោះ តានូវ។ បាទបីនាក់ហ្នឹង។

**ស៖** បាទ អរគុណ។ ថាតើនៅទីនោះ នៅពេលដែលគេបញ្ជូនលោកពូទៅអង្គរកានោះ គេបានដាក់ខ្នោះជើងទាំងពីរ ឬមួយឬដាក់ខ្នោះតែមួយ ហើយបន្ទាប់មកទៀត គេឲ្យរបបអាហារយ៉ាងដូចម្តេចថាតើក្នុងខណៈពេលនោះ មានព្រឹត្តិការណ៍អីកើតឡើងទេ? គេបានវ៉ៃសួរចម្លើយទៀត ឬមួយអត់?

[១០:៥៧:៤៧]

**ឆ៖** បាទ ទៅដល់នោះគេអត់មានវ៉ៃសួរចម្លើយអីទៀតទេបាទ គេឲ្យខ្ញុំហ្នឹងចូលទៅគុកគេហ្នឹងតែម្តង គេដាក់ខ្នោះជាប់នៅហ្នឹងទៅ អត់មានសួរចម្លើយទៀតទេបាទ។ ហើយរបបអាហារ របបហូបអី

ហ្នឹង គេ ខ្ញុំឃើញគេដួសឲ្យខ្ញុំហ្នឹងបាយពីរបីគ្រាប់ហ្នឹង គេបបរបាយកកគេហូបសល់ហ្នឹង បាយកកគេហូបសល់ហ្នឹង គេបបរអាបាយកកហ្នឹង អាបាយកកងហ្នឹងមានរីកដូចគ្រាប់អង្ករឯណា អត់មានរីកទេ។

**ស៖** បាទ អរគុណ។ ចុះនៅពេលដែលដាក់ខ្នោះជើងទាំងពីរហ្នឹង ដាក់រហូតទៅប៉ុន្មានខែទៅ ហើយមានការឈឺយ៉ាងណា ហើយវាអាចក្លាយទៅជាដំបៅ ឬមួយក្លាយទៅជាអីដែលអត់ទេនៅពេលដែលជាប់ខ្នោះហ្នឹង?

**ឆ៖** បាទ អរគុណណាស់លោកមេធាវី។ ខ្ញុំបាទជាប់គុកហ្នឹងវារហូតដល់បុកដែកខ្នោះហ្នឹង ចុះគេដាក់អ្នកមុនហ្នឹង – អ្នកមុនគេឲ្យចេញទៅធ្វើការ ខ្ញុំហ្នឹងគេអត់ទាន់ឲ្យចេញទៅធ្វើការទេ អ៊ីចឹងដល់រួចទៅគេដកខ្នោះ។ ពេលព្រលឹមអ៊ីចឹង គេៗហូតដែករនុកហ្នឹងបាទ គេហូតដែករនុកហ្នឹងចេញទៅបញ្ចេញអ្នកមុនហ្នឹងទៅធ្វើការ នៅតែខ្ញុំម្នាក់ឯងគត់។ ដល់គេបញ្ចូលមកវិញ គេមិនបុកដែកខ្នោះហ្នឹងមកវិញ បុកទៅវាខុសរន្ធហ្នឹង ខ្ញុំតម្រង់មិនទាន់ត្រូវជើងឈាមល្អាច រហូតដល់ដំបៅរលួសរលួយជើងទៅទៀត អត់មានថ្នាំអីព្យាបាលទេ។ បាទ លោកមេធាវី ខ្ញុំជម្រាបអ៊ីចឹង អត់មានថ្នាំសង្កូវព្យាបាលទេជំនាន់នោះ។ ឈាមជើងល្អាច និយាយពីជើងទៅជាដំបៅ ឥឡូវហ្នឹងបើមិនជឿខ្ញុំ ខ្ញុំលាត់ឲ្យមើលស្នាមទាល់តែឥឡូវ គន្លាក់ជើងអស់រលីងហើយ។ ហើយខ្ញុំ វា -- ជើងហ្នឹងអង្គុយយូរអ៊ីចឹងហើយស្រិលហើមអ៊ីចឹងហ្នង។

[១១:០០:៥១]

**ស៖** បាទ អរគុណ។ នៅពេលដែលជាប់ខ្នោះនោះ លោកពូបានលើកឡើងថា គេអត់បានយកចិត្តទុកដាក់អីទេ ហើយបុកមកប៉ះទៀត។ ចុះការដែលឈឺចាប់នៅក្នុងខណៈពេលដែលជាប់ហ្នឹង លោកពូអាចរៀបរាប់បានទេ ថាតើការឈឺចាប់ហ្នឹងវាដល់កម្រិតណា អាចប្រៀបផ្ទឹមទៅនឹងអ្វីបាន ដែរឬក៏អត់?

**ឆ៖** ការឈឺចាប់របស់ខ្ញុំហ្នឹងមិនអាចមានអ្វីមកប្រៀបផ្ទឹមបានទេបាទ។ ខ្ញុំនឹកថា ខ្ញុំនឹងមិនបានរស់មានថ្ងៃនេះទេ ខ្ញុំនឹកក្នុងចិត្តខ្ញុំ។ ព្រោះថាឈឺចាប់អាផ្នែកផ្លូវកាយហ្នឹងវាឈឺហើយ ផ្លូវចិត្តហ្នឹងក៏វាពិបាកណាស់ទៅទៀត។ បត់ដៃ បត់ជើងអីហ្នឹងមិនងាយទេ ខ្ញុំថា ខ្ញុំតាំងពីខ្ញុំកើតមកខ្ញុំមិនដែលជួបប្រទះទេ ទើបមកក្នុងជំនាន់៣ឆ្នាំហ្នឹង ខ្ញុំជួបប្រទះធ្ងន់ធ្ងរយ៉ាងនេះ។ បត់ដៃ បត់ជើងអី គេមាន យើងដេកទល់ជើងគ្នាអ៊ីចឹង។ បាទ គ្រែគេនោះពីរល្វែង មួយល្វែងខាងស្រីៗទៅ មួយល្វែងទៀតខាងបុរសៗ ហើយ

ប្រឡោះកណ្ដាលហ្នឹងគេដាក់ខាបមួយ។ ខាបមិនមែនមួយ ខាបប្រហែលជាពីរបី។ ហើយខ្ញុំជាប់ជើងពីរពិបាកណាស់។ ពិបាករឿងបត់ជើងបត់ដៃហ្នឹង។ ទាល់រក គេអ្នកជាប់ជើងមួយ ទាញមកឲ្យជិត ខ្ញុំចាប់ខាបហ្នឹងដាក់មកក្រោយហ្នឹង បានជុះបត់ជើងបានបាទ។ ហ្នឹងការឈឺចាប់របស់ខ្ញុំទាំងផ្លូវកាយ ទាំងចិត្តគ្មាន មិនអាច គ្មានអីមកប្រៀបផ្ទឹមបានទេ ខ្ញុំថា ខ្ញុំស្លាប់ហើយ អត់នៅទេ។ ហើយមួយនោះ ដាច់ពោះបាយស្លាប់នៅជាប់គ្នានឹងខ្ញុំហ្នឹង មិនខ្ចីយកចេញទៀត ប្រហែលជា ២យប់៣ថ្ងៃបានយកចេញ។ បាទ វាដាច់ជាតិបាយ ជាតិនេះអីចឹង ជាតិបបរ ដូចថាគ្នាឃ្លានមាំពេក ឈ្មោះវា អាប៉ាត់ៗ អាហ្នឹង នៅជាប់គ្នាហ្នឹងខ្ញុំតែម្ដង។ ហើយខ្ញុំពិចារណារូបខ្ញុំ ថាខ្ញុំក៏ដូចជាគេអីចឹងដែរមើលទៅ។

[១១:០៣:៤៤]

**ស៖** បាទ អរគុណ។ ចុះថាតើនៅស្ថានភាពនៅក្នុងគុកហ្នឹងការជាប់ហ្នឹង លោកពូបានន័យថាចូលទៅឃើញថា មានអ្នកដែលជាប់ដទៃៗនៅពេញនៅហ្នឹង ឬមួយមានប្រហែលប៉ុន្មាននាក់ ហើយមានស្ត្រីមានកុមារ ឬមួយអ្នកផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ នៅក្នុងគុកហ្នឹងវាមានទាំងស្ត្រី ដូចខ្ញុំបាននិយាយហើយ ខ្ញុំថាមួយល្វែងអីចឹងទៅស្ត្រីខ្ញុំដេកទល់ជើងគ្នានឹងស្រីៗអីចឹងទៅ ហើយមួយប្រឡោះនេះ ខាងនេះបុរស ហើយអីចឹងបុរសហ្នឹងប្រហែលជាចូល១០នាក់ដែរ ហើយស្ត្រីហ្នឹងប្រហែលជាខ្ទង់ជាង១០នាក់ដែរ។ ហើយនារីមួយទៀត ស្ត្រីមួយទៀតនោះ គាត់មានទាំងកូនបំបៅឲ្យបៅដោះ ហើយជើងជាប់ខ្នោះទៀត ហើយមិនដឹងហេតុអី ខ្ញុំក៏មិនដឹងមូលហេតុដែរ ស្ត្រីហ្នឹង ម្នាក់ហ្នឹង ឃើញកូនតូចនៅបៅដោះ។ ហើយគាត់ក៏ចូល -- យកគាត់ទៅដាក់គុកដែរ មិនដឹងមូលហេតុអី ខ្ញុំក៏មិនដឹងដែរ។ នៅបៅ -- កូនតូចនៅបៅដោះ។

[១១:០៥:២៥]

**ស៖** បាទ អរគុណ។ ចុះនៅពេលដែលគេចាប់មកដាក់នៅគុកនៅហ្នឹង តើខាងក្រុមគ្រួសារ ឬមួយក្រុមគ្រួសារលោកពូហ្នឹងបានដឹងរឿងហ្នឹងដែរអត់? ហើយគាត់មានទំនាក់ទំនងយ៉ាងម៉េចជាមួយលោកពូដែរឬទេ?

**ឆ៖** បាទ ក្រុមគ្រួសាររបស់ខ្ញុំបាទហ្នឹង អត់មានដឹងទេ។ សូម្បីតែជិតខាងហ្នឹងក៏អត់មានដឹងថាខ្ញុំហ្នឹងជាប់គុកដែរ។ គេឃើញខ្ញុំបាត់ខ្លួនហ្នឹង គេថាខ្ញុំហ្នឹងស្លាប់ហើយ។ ប៉ុនខ្ញុំវាចៃដន្យអីចេះទេ បានជួបប្អូន ប្អូនស្រីម្នាក់ វាដើរ ដូចថាគេហៅទៅធ្វើប្រឡាយទួលគ្រួស ដល់រួចទៅ វាឃើញខ្ញុំនៅរែកដីហ្នឹងក្បែរផ្លូវហ្នឹង គេឲ្យខ្ញុំហ្នឹងជីកស្រះ ជីកដីធ្វើជាស្រះទឹក។ មួយថ្ងៃហ្នឹងគេឲ្យខ្ញុំរែកឲ្យបាន៣ម៉ែត្រគូបបាទ

៣ម៉ែត្រគូប។ វាស្គាល់ដោយសារថា ប្អូនហ្នឹងវាឃើញខ្ញុំនៅរែកដីនុំង ជីកស្រះនៅនឹងជីកផ្លូវហ្នឹង វាឃើញ វាប្រាប់ បានប្រាប់ដែរ តែវាអត់មានទំនាក់ទំនងអីបានទេ អត់តែទាល់តែសោះបាទ។

**សៈ** តើនៅក្នុងសម័យនោះ លោកពូកមានបាត់បង់ក្រុមគ្រួសារ ឬមួយការបាត់បង់ ដូចជាទ្រព្យសម្បត្តិ ឬមួយជាអ្វីដែលលោកពូថា វាជាការធ្វើឲ្យការខាតបង់ទាំងស្មារតី ទាំងសម្ភារៈ?

**ឆៈ** បាទ ការខាតបង់ហ្នឹងវាមានហើយ ដូចថាមានជាទ្រព្យសម្បត្តិ វាគ្មានស្អីផងកាលនុំងនោះ។ វា ចុះមានអ្នកណាគេឲ្យយើងយកអីចេញពីក្រុងភ្នំពេញហ្នឹងទៅ វាអត់មានផង។ ហើយទ្រព្យសម្បត្តិហ្នឹង គេប្រមូលយកអស់ហើយ អត់មាននេះទេ ខ្ញុំនៅជាប់គុកហ្នឹង នៅតែអាវខោមួយចង្កេះផ្អេះនឹងខ្លួនហ្នឹង។ ទ្រព្យសម្បត្តិគេប្រមូលទាំងពីយើងយកមកដល់ ចូលដល់កន្លែងគេនោះ បាទ។

[១១:០៨:៣៩]

**សៈ** បាទ អរគុណ។ ជាចុងក្រោយ ថាតើពូមានការថ្លែងអ្វីជាចុងក្រោយ? ហើយអាចមានជាសំណូមពរទៅអង្គជំនុំជម្រះបាន នៅចុងក្រោយនេះបាទ។

**ឆៈ** បាទ ជាចុងក្រោយនេះ ខ្ញុំបាទសុំមានសំណួរពីរទៅដល់លោក -- អស់លោកទាំងពីរ ដែលដឹកនាំនៅសម័យនោះ។ ខ្ញុំសួរថាតើលោក--

**សៈ** សូមទោសលោកពូ--

**ឆៈ** មិនទាន់។

**សៈ** លោកពូអាចមានសំណូមពរ ឬមួយអី គឺតាមរយៈលោកប្រធានអង្គជំនុំជម្រះបានបាទ។

**ឆៈ** បាទសំណូមពររបស់ខ្ញុំ ខ្ញុំបាទសូមឲ្យខាងអស់លោក លោកស្រី ខាងតុលាការហ្នឹងជួយរកយុត្តិធម៌ឲ្យខ្ញុំផង ព្រោះថា ខ្ញុំអំពីរឿងទី១ ខ្ញុំវារាងកាយហ្នឹងក៏វាបានបាត់បង់ ដូចថាខូចខាត ដូចថាវាចំនួនហើយ វាធ្វើការអីក៏មិនបាននេះដែរ។ សំណូមពររបស់ខ្ញុំ គ្រាន់តែថាឲ្យជួយរកយុត្តិធម៌ឲ្យខ្ញុំតែប៉ុណ្ណឹងបានហើយ ខ្ញុំអស់ចិត្តហើយបាទ។

**សៈ** បាទ អម្បាញ់មិញ លោកពូអត់ទាន់បានឆ្លើយនឹងសំណួរខ្ញុំមួយ ថាតើក្រុមគ្រួសារលោកពូបានបាត់បង់នៅក្នុងសម័យនោះដែរឬអត់បាទ?

**ឆៈ** បាទ ក្រុមគ្រួសាររបស់ខ្ញុំនៅទើសសព្វថ្ងៃហ្នឹង អត់មានបាត់បង់ទៅណាផង។ ដល់តែពេលដែលផ្ទះឃ្លាំងគ្រាប់ត្រពាំងធំហ្នឹង គេរត់ជាពិរាអីចឹងទៅ បានគេលែងខ្ញុំឲ្យនៅក្នុងការឃុំគ្រងរបស់គេហ្នឹង គេមើលគ្រប់គ្រងអីចឹងទៅ។ ដល់វៀតណាមចូល បុកចូលដល់ហ្នឹងបានគេលែងឲ្យតាម។

គ្រួសារអត់បាត់បង់ទៅណាទេបាទ គ្រួសារខ្ញុំនៅរស់ដល់សព្វថ្ងៃហ្នឹង។

[១១:១១:៣១]

**ស៖** បាទ អរគុណ។ អម្បាញ់មិញ ខ្ញុំបានជម្រាបលោកពូហើយថាលោកពូអាចលើកសំណួរ តែសំណួរអាចជូនទៅអង្គជំនុំជម្រះ ហើយផ្ទេរទៅខាងៗជនជាប់ចោទបានបាទ។ ហ្នឹងប្រសិនបើលោកពូមានបំណងបាទ។

**លោក ថាន់ ធីម៖**

**ធ៖** បាទ ខ្ញុំបាទសូមសួរសំណួរពីរចំណុច។ សំណួរទី១ ថា សួរថា តើលោកទាំងពីរហ្នឹងទទួលស្គាល់ថា មានគុក ឬមន្ទីរសន្តិសុខនៅៗកន្លែងអង្គរកាហ្នឹងដែរឬទេ? បាទ នេះសំណួរទី១។ ខ្ញុំបាទជាប់គុកនៅទីនោះមែន អត់មាននិយាយក្លែងបន្លំអីទេ គឺជាក់ស្ដែងអ៊ីចឹងតែម្ដងបាទ។ ហើយសំណួរទី២ តើអស់លោកយល់ព្រមទទួលខុសត្រូវ និងបកស្រាយពីអំពើឧក្រិដ្ឋកម្មបានដែរឬទេ? សំណួររបស់ខ្ញុំមានតែពីរសំណួរហ្នឹងទេ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១១:១៣:២៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះជម្រាបលោក ថាន់ ធីម ថា នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយជនជាប់ចោទទាំងពីរនាក់បានឆ្លើយរក្សាជំហររបស់ខ្លួន បន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលព័ត៌មានជាក់ច្បាស់ពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីឲ្យជនជាប់ចោទ។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និងមេធាវីការពារក្ដីជនជាប់ទទួលខុសត្រូវក្នុងការជូនដំណឹងមកដល់អង្គជំនុំជម្រះឲ្យទាន់ពេលវេលានិងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទបានសម្រេចលះបង់សិទ្ធិនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ ដែលសួរដេញដោយចៅក្រម ឬដោយភាគីពាក់ព័ន្ធ។ តែរហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបមកជាការយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅឡើយ

ទេ។ សូមលោក ថាន់ ធីម ជ្រាប។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរ -- សាកសួរពាក់ព័ន្ធជាមួយនឹងស្ថានភាពព្យសនកម្ម និងទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១១:១៥:០៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ជាព័ត៌មានយើងមានសំណួរជាច្រើនពាក់ព័ន្ធនឹងប្រធានបទពីរដើម្បីសួរទៅដើមបណ្តឹងរដ្ឋប្បវេណី។ ទី១ គឺការឃុំខ្លួនគាត់នៅអង្គរកា និងទី២ ការបញ្ជូនគាត់ពីស្រុកគីរីវង់ទៅស្រុកត្រាំកក់។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបញ្ហាបកប្រែភាសាមានបញ្ហា។

ទៅណាហើយលោក អ៊ុច អរុណ?

បាទ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ ខ្ញុំនិយាយថា ខ្ញុំមិនសំណួរជាច្រើនដើម្បីចោទសួរទៅដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងប្រធានបទពីរ គឺទី១ ការឃុំខ្លួន--

**ប្រធានអង្គជំនុំ៖**

គឺ ផ្លាស់ឥឡូវអត់ឮសោះ!

*(មានបញ្ហាបច្ចេកទេស)*

[១១:១៧:០០]

លោកសហព្រះរាជអាជ្ញារងអន្តរជាតិដូរៗមីក្រូហ្វូន ប្រើមីក្រូហ្វូនខាងព្រះរាជអាជ្ញារងជាតិវិញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានជម្រាបថាផ្ទុយពីភាគីផ្សេងទៀត គឺថា--

**ប្រធានអង្គជំនុំ៖**

បាទ នៅៗតែដដែលទេ។

*(មានបញ្ហាបច្ចេកទេស)*

[១១:១៩:០០]

**លោក វ៉ាំងសង់ វ៉ាយម៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសង្ឃឹមថាដើរហើយ។ ខ្ញុំនិយាយថាខុសពីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗដែលយើងបានសួរខ្លីៗ ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម នេះយើងត្រូវការពេលច្រើនដើម្បីសួរព្រោះថាយើងមានសំណួរច្រើន ជាពិសេសពាក់ព័ន្ធនឹងប្រធានបទពីរ។ ទី១ គឺការឃុំខ្លួនគាត់នៅគុកអង្គរកា និងទី២ គឺការបញ្ជូនគាត់ពីស្រុកគីរីវង់ទៅស្រុកត្រាំកក់។ ដូច្នេះ ខ្ញុំគិតថាខ្ញុំនឹងសួរមិនអាចចប់មុនម៉ោងដប់មួយកន្លះនេះទេ។ <ដូច្នេះខ្ញុំនឹងមានមតិចំពោះចម្លើយមុនៗដែលបានរៀបរាប់ហើយ និងជាបឋម> ខ្ញុំនឹងនិយាយអំពីគុកអង្គរកា--

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

[១១:១៩:៥៥]

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាខ្ញុំយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា ដោយសារនេះគឺជាសាក្សីមួយដ៏សំខាន់ដែលអាចរៀបរាប់រឿងរ៉ាវជាច្រើន តាមរយៈបទពិសោធន៍របស់គាត់ជូនអង្គជំនុំជម្រះ។ ហើយខ្ញុំមិនមានការជំទាស់អ្វីទៅនឹងគោលបំណងនៃការតាំងសំណួរពីសំណាក់សហព្រះរាជអាជ្ញានោះទេ។ យើងទាំងអស់គ្នានៅក្នុងបន្ទប់សវនាការនេះ ហាក់បីដូចជាងាកចេញពីការតាំងសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹង<ព្យសនកម្មរបស់>ជនរងគ្រោះ។ <ហើយខ្ញុំក៏មានក្តីសោមនស្សក្នុងការចាត់ទុក>ដើមបណ្តឹងរដ្ឋប្បវេណី<រូបនេះដែល>បានផ្តល់សក្ខីកម្មគួរឲ្យចាប់អារម្មណ៍<ជាសាក្សីផងដែរ>។ នេះគឺជា<ទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំ តែយើង>មិននិយាយអំពីផលប៉ះពាល់របស់<សំណាង>ជនរងគ្រោះទេ ប៉ុន្តែ<ជាសាក្សីដែលបានផ្តល់>សក្ខីកម្មដ៏គួរឲ្យចាប់អារម្មណ៍<តែប៉ុណ្ណោះ> ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។ យើងបានរំឭកហើយ ពីនីតិវិធីក្នុងការដេញ

ដោលព្រោះពេលវេលាមានកំណត់។ យើងថ្ងៃនេះ និងថ្ងៃស្អែកទេ នៅប្រាំមួយនាក់ទៀត។ សូមជ្រាប។

[១១:២១:៤៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល**

**ស៖** សំណួរទីមួយលោកដើមបណ្តឹងរដ្ឋប្បវេណី អម្បាញ់មិញនេះ ខ្ញុំអត់បានស្តាប់ឮចម្លើយរបស់លោកពាក់ព័ន្ធនឹងប្រធានបទនេះទេ។ នៅពេលដែលលោកនៅត្រពាំងធំខាងជើង នៅពេលដែល គេចាប់ខ្លួនលោកហ្នឹង តើគេចោទលោកពីបទអីដែរ? ហេតុអីបានជាគេចាប់ខ្លួនលោក?

**លោក ថាន់ ធីម៖**

**ឆ៖** គេចាប់ខ្លួនហ្នឹងខ្ញុំដោយសារថា កូនស្រីខ្ញុំមីច្បងនោះ វាកង ជាមួយនឹងនាង អៀម យេន ដែលឡើងធ្វើសក្ខីកម្មមុនខ្ញុំនេះ។ វាកង វាដើរលួចកាច់អំពៅ កាច់អីគេអ៊ីចឹងទៅ ដល់រួចទៅគេចាប់វ៉ៃ វាឲ្យឆ្លើយថា ខ្ញុំនឹងធ្វើទាហានពាក់ស័ក្តិ២ នៅភ្នំពេញហ្នឹងបានគេឲ្យរួច។ ហើយក្មេងវាចេះតែឆ្លើយទៅ។ វាមិនដឹងឪទៅងាប់ឯណា គេចាប់ឪយកទៅវ៉ៃចោលវាមិនដឹងឯណា។ បាទ ដោយសារកូនហ្នឹង។

**ស៖** សូមអរគុណចំពោះចម្លើយនេះ។ ខ្ញុំចង់បានការបញ្ជាក់អំពីលោក ពាក់ព័ន្ធទៅនឹងពេលដែលគេចាប់<>និងឃុំខ្លួនលោក។ លោកបានថាបញ្ជាក់ថា គេឃុំខ្លួនលោកអស់រយៈពេល៣ខែ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោករស់នៅក្នុង<>គុកអង្គរកាហ្នឹង រហូតដល់ពេលវៀត-ណាមវ៉ៃចូលមែនទេ?

[១១:២៣:២២]

**ឆ៖** ដល់វៀតណាមវ៉ៃចូលមកហ្នឹង គិតទៅដល់រួចទៅ ផ្ទុះឃ្លាំងគ្រាប់នៅត្រពាំងធំខាងជើងហ្នឹងទៀត ក៏ខ្ញុំមិនទាន់បានរួចផង។

**ស៖** <បាទ >អ៊ីចឹងពេលនោះហើយ<ទើប>លោកអាចរត់គេចបាន<>។ តើលោកច្បាស់ទេថាលោកពិតជាជាប់ឃុំ៣ខែមែន ឬក៏លោកជាប់ឃុំហ្នឹងយូរជាងហ្នឹង <ឬក៏លោកជាប់នៅទីនោះរយៈពេលខ្លីជាងហ្នឹងទេ>?

**ឆ៖** ខ្ញុំជាប់ឃុំហ្នឹងគិតទៅវាមិនមែន៣ខែទេ។ ខ្ញុំនិយាយ៣ខែហ្នឹង ខ្ញុំនិយាយថាខ្ញុំនៅក្នុងគុកហ្នឹងទាំងយប់ទាំងថ្ងៃ វារយៈពេល៣ខែ។ អ៊ីចឹងអ្នកជាប់គុកគេអត់ឲ្យនៅទំនេរទេ គឺគេបញ្ចេញឲ្យទៅធ្វើ

ការ គេអត់មានទុកឲ្យនៅដេកស្រួលទេបាទ។ ខ្ញុំសូមឆ្លើយអ៊ីចឹង ថាអ្នកជាប់គុក ខ្ញុំហ្នឹងជាប់នៅក្នុងគុក ៣ខែ។ ដល់គ្រប់រយៈពេល៣ខែហ្នឹង បានលោក ម៉េង ហ្នឹងហៅខ្ញុំសួរម្តងទៀត។ សួរៗ ដេញដោលតាំងពីដំបូងថា ៧០ នៅឯណា? ៧២ នៅឯណា? ៧៣ នៅឯណា? ៧៤-៧៥ នៅឯណា? ហើយខ្ញុំឆ្លើយតាមដំណើរហ្នឹងអ៊ីចឹងទៅបានគេឲ្យខ្ញុំចេញធ្វើការបាទ។ មិនមែនជាប់៣ខែហ្នឹងបានរួចទេ គឺជាប់រហូតដល់វៀតណាមបុកឡើង តាំងពីឆ្នាំ៧៨ បាទ ជាប់ឆ្នាំ៧៨ រហូតដល់វៀតណាមបុកឡើង។

**ស៖** អ៊ីចឹង បើគិតទៅលោកជាប់ប៉ុន្មានដែរ? <ខ្ញុំគិតថាគេឲ្យ>លោកធ្វើការនៅពេលថ្ងៃ <ហើយពេលយប់គេយកមកឃុំវិញ>ផងអីផងនោះ សរុបទៅលោកជាប់<>ប៉ុន្មានខែដែរ?

[១១:២៥:៥៥]

**ឆ៖** ខ្ញុំបូកសរុបទៅ គឺថាខ្ញុំនិយាយថាជាប់នៅឆ្នាំ៧៨ហ្នឹងតែម្តង។ ជាប់នៅឆ្នាំ៧៨ហ្នឹង អ៊ីចឹងនៅក្នុងគុកហ្នឹងរយៈពេល៣ខែៗ បានគ្រប់៣ខែហ្នឹងបានគេ ពួកមុនៗជាប់មុនៗ គេចេញទៅធ្វើការ។ ចេញទៅធ្វើពេលថ្ងៃអ៊ីចឹង ពេលយប់គេបញ្ចូលមកវិញ។ ហើយខ្ញុំពេលដែលគេចេញទៅធ្វើការពេលព្រឹកហ្នឹងឈ្មោះ ម៉េង ហ្នឹង ហៅខ្ញុំសួរចម្លើយ។ សួរចម្លើយអ៊ីចឹងទៅ បានខ្ញុំឆ្លើយប្រាប់គេតាមដំណាក់ៗអ៊ីចឹងទៅ បានដល់រួចទៅ គេឲ្យខ្ញុំហ្នឹងចេញធ្វើការដែរ។ ចេញធ្វើការមុនដំបូងហ្នឹង -- លោកមេធាវី ខ្ញុំជ្រាបត្រង់ គឺថាចេញមុនដំបូងហ្នឹង គេឲ្យខ្ញុំរែកទឹកហ្នឹងស្រោចដំណាំជិតៗហ្នឹង បាទ។ រែកទឹកស្រោចដំណាំជិតៗហ្នឹង ហើយយើងនៅក្នុងគុកហ្នឹង និយាយពីដើរ ជើងដើរដីហ្នឹង និយាយពីក្តៅសឹងឆេះជើងដើរមិនបានទេ ព្រោះសាច់វាខ្ចី បាទ។ ឈឺមាំណាស់ ឈឺខ្លាំងមែនទែន ប៉ុន្តែហេតុតែចង់រស់ ចេះខំរែកទឹកហ្នឹងស្រោចដំណាំនៅអាជិតៗអាគុកគេហ្នឹង។ គេមានស្រះទឹកមួយនៅជិងទ្នុំង ហើយខ្ញុំហ្នឹងក៏រែកទឹកហ្នឹងស្រោចដំណាំហ្នឹងជិតៗហ្នឹងបាទ។

**ស៖** ដើម្បីបញ្ចប់ពាក់ព័ន្ធនឹងរយៈកាលនេះ តើលោកអាចជម្រាបបានទេថាលោក<នៅ>ធ្វើការ<ពេលថ្ងៃ ហើយពេលយប់គេឃុំ>នៅក្នុងគុកអង្គរកាហ្នឹងអស់ជាច្រើនខែ<>។ តើអ៊ីចឹងទេ?

**ឆ៖** បាទ ពេលយប់គេដាក់ខ្នោះជើងវិញដដែលបាទ អត់មានថាលែងយើងទេ គឺពេលថ្ងៃអ៊ីចឹងចេញធ្វើការ ពេលយប់គេយកមក គេបញ្ចូលខ្នោះយើងវិញដដែល។

[១១:២៨:២៣]

**ស៖** សូមអរគុណ។ ខ្ញុំនិយាយអំពីរបៀបដែលគេនាំលោកទៅអង្គរកា។ លោកៗថា លោកទៅដល់ផ្សារអង្គរកា ហើយគេប្រគល់លោកទៅឲ្យឈ្មោះ រស់ ហើយនៅក្នុងឯកសារ E3/5034 ទំព័រ២

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01086637



លោកនិយាយថា <រស់> គឺជា<ប្រធានកង>ឈ្លប<>។ តើលោកដឹងឈ្មោះគាត់ និងដឹងពីមុខងាររបស់គាត់ហ្នឹង ដោយរបៀបណាដែរ?

**ឆ៖** គាត់ហ្នឹងមិនដឹងជាប្រធានឈ្លបស្រុក ឬមួយក៏កងទ័ពទេ ប៉ុនខ្ញុំឃើញគាត់ហ្នឹងយកអាវុធមួយដើម អាវុធអាកា៤៧ហ្នឹង មកបណ្ដើរខ្ញុំហ្នឹង យកដាក់ចូលក្នុងគុកហ្នឹង។ ឃើញយកអាវុធមួយដើម។

**ស៖** <តើ>គាត់<ផ្ទាល់>ជាអ្នកប្រាប់<ឈ្មោះរបស់គាត់ដល់លោក> ឬ<លោកដឹងឈ្មោះគាត់ពីអ្នកផ្សេង>?

**ឆ៖** ព្រោះមុនដំបូង ខ្ញុំដូចថាឈ្មោះហ្នឹង មិនទាន់ស្គាល់គាត់ហ្នឹងថា តារស់ ទេ។ ប៉ុន្តែដល់ខ្ញុំនៅក្នុងគុកហ្នឹងបានចេញធ្វើការពេលថ្ងៃអ៊ីចឹង ពេលយប់មកជាប់គុកវិញ។ ដល់រួចទៅបានខ្ញុំដឹង មានគេប្រាប់ខ្ញុំ។

**ស៖** សូមអរគុណ។ តើឈ្មោះ រស់ ហ្នឹង<ឬ>ជាអ្នកនាំលោកទៅដល់អង្គរកា ឬក៏មានអ្នកផ្សេងទៀតជាអ្នកនាំលោកទៅ<>?

**ឆ៖** អ្នកដែលនាំខ្ញុំចេញពីឃុំត្រពាំងធំហ្នឹង ចេញពីកន្លែងភូមិខ្ញុំនៅហ្នឹង អាហ្នឹងឈ្មោះ សេ មិនមែនឈ្មោះ រស់ ទេបាទ។ ក៏ប៉ុន្តែគេយកមកៗពីភូមិមក គេយកមកប្រគល់ឲ្យ តារស់ ហ្នឹង។ ឈ្មោះ សេ ហ្នឹងជាឈ្លបឃុំ ហើយឈ្មោះ រស់ ហ្នឹងមិនដឹងគាត់ត្រូវជាឈ្លបស្រុក ឬមួយម៉េចក៏ខ្ញុំមិនបានដឹងដែរ ប៉ុន្តែឃើញគាត់យកអាវុធអាកាមួយដើម នាំខ្ញុំចូលក្នុងគុកហ្នឹង។

[១១:៣១:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារង អរគុណដើមបណ្ដឹងរដ្ឋប្បវេណី ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងដែលគាត់អង្គុយថ្លែងរៀបរាប់អំពីទុក្ខសោកវេទនានិងព្យសនកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយនិងសាមសិបនាទី។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវវនាការ។ ហើយនៅក្នុងសវនាការនៅរសៀលនេះ អង្គជំនុំជម្រះសូមរំឭកជម្រាបជូនភាគីថា សូមឲ្យដំណើរការក្នុងការសាកសួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីនេះឲ្យបានយឺតៗ ដោយសារមូលហេតុខ្វះធនធានអ្នកបកប្រែភាសា។ អ៊ីចឹងការបកប្រែភាសាហ្នឹង គឺវាមានការ *វីឡេ* ច្រើនដំណាក់ មិនមែនផ្ទាល់ដូចសព្វដងទេ ដោយសារខ្វះធនធានផ្នែកខាងបកប្រែភាសាបារាំង និង/ឬ អង់គ្លេស។

បាទ សូមអញ្ជើញ លោកស្រីមេធាវី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានព័ត៌មានថាអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងលោក ថៅ នី។ ខ្ញុំត្រៀមខ្លួននឹងផ្ដល់ព័ត៌មានសំយោគ គឺមានអង្គការអន្តរការី១៤ ដែលទទួលបន្ទុកជួយដល់ជនរងគ្រោះក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ សមាគមមួយនោះ គឺឈ្មោះថា “សមាគមសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម”។ សមាគមនេះបានជួយ<>ជនរងគ្រោះ<ចំនួន>១៩១នាក់ ដើម្បីដាក់ពាក្យតាំងខ្លួន<ជាដើមបណ្ដឹងរដ្ឋប្បវេណី>នៅទូទាំងប្រទេស។ លោក ថៅ នី គាត់ធ្វើការឲ្យសមាគមនេះ។

[១៣:៣២:៥០]

ខ្ញុំសូមដកស្រង់អំពី<តួនាទី>របស់គាត់ជាភាសាអង់គ្លេស។ នេះជាអ្វីដែលខ្ញុំទទួលបាននៅពេលសម្រាកថ្ងៃត្រង់។ <គាត់ជាសមាជិកក្រុម “បុគ្គលិកអប់រំផ្សព្វផ្សាយ និងទទួលបណ្ដឹង” ក្នុង>ឆ្នាំ

២០០៨<និងឆ្នាំ>២០០៩ <ហើយបន្ទាប់ពីពាក់កណ្តាល>ឆ្នាំ២០១០យើងមិន<ទទួល>បាន<ព័ត៌មាន> ច្បាស់<លាស់ទេ>ទេ។ ក៏ប៉ុន្តែ<មុន>ពាក់កណ្តាលឆ្នាំ២០១០ គាត់បានកាន់តួនាទី<>នេះ សម្រាប់ខេត្ត តាកែវ"។ អ៊ីចឹងហើយបានជាគាត់បានចូលរួមជួយដល់ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់ ពាក្យសុំតាំងខ្លួននេះ នៅក្នុងខេត្តតាកែវនេះឯង។ ហើយយើងមានពាក្យសុំតាំងខ្លួន២៣ នៅក្នុងខេត្តតាកែវ ដែលត្រូវបានធ្វើតាមរយៈសមាគមនេះ រួមទាំងពាក្យសុំរបស់លោក ថៅ នី ខ្លួនឯងផ្ទាល់ក៏ផងៗដែរ។ ហើយឈ្មោះ ថៅ នី នេះមាន<សរសេរនៅ>ក្នុងពាក្យសុំ<ចំនួន>២២<ពី>ខេត្តតាកែវ។ មូលហេតុ ដែលឈ្មោះគាត់មាននៅក្នុងទម្រង់បែបបទដាក់ពាក្យសុំតាំងខ្លួនហ្នឹង ដោយសារតែៗអង្គភាពគាំពារជន រងគ្រោះហ្នឹង រៀបចំបែបហ្នឹងឯង គឺថាត្រូវតែមានសាក្សី<ម្នាក់> ដើម្បីចុះហត្ថលេខាទៅលើទម្រង់ បែបបទព័ត៌មានហ្នឹង អមជាមួយនឹងជនរងគ្រោះផ្ទាល់។ នេះជាព័ត៌មានពាក់ព័ន្ធទៅនឹងលោក ថៅ នី។

បន្ទាប់មកទៀត មានព័ត៌មានបន្ថែមមួយចំនួនទៀតដែលយើងអាចឃើញមាននៅក្នុងសំណុំរឿង ហើយព័ត៌មានបន្ថែមនេះ ត្រូវបានដាក់នៅក្នុងផ្នែកទី២ នៃឆ្នាំ២០១០។ ដូច្នេះ ព័ត៌មានបន្ថែមទាំងអស់ ពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវស្តាប់ចម្លើយនៅថ្ងៃនេះ។ ហើយដែលនៅខេត្តតាកែវ ហ្នឹង គឺអង្គភាពជនរងគ្រោះដែលជាអ្នកទទួលបន្ទុកក្នុងការប្រមូលព័ត៌មាននោះដោយខ្លួនឯងនៅពេល នោះ។ ខ្ញុំសូមបញ្ជាក់ផងដែរថា នៅពេលនោះផ្នែករបស់យើងមិនទទួលខុសត្រូវ គឺថាមិនមានតួនាទីអី នៅក្នុងដំណើរការនេះទេ។ នេះជាព័ត៌មានដែលខ្ញុំអាចទទួលបាននៅពេលសម្រាកអម្បាញ់មិញនេះ។ ប្រសិនបើអង្គជំនុំជម្រះគិតថាព័ត៌មាននេះមិនគ្រប់គ្រាន់ ខ្ញុំអាចនឹងរកព័ត៌មានបន្ថែមទៀត។

[១៣:៣៥:២៦]

<រួមសេចក្តីមក> ខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះថា <វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ យើងខ្ញុំថា>ដើមបណ្តឹងរដ្ឋប្បវេណីទាំងប្រាំបីនេះ ត្រូវតែស្តាប់ឲ្យចប់នៅថ្ងៃនេះ និងនៅថ្ងៃស្អែក<។> <ដោយសារមានការពន្យារពេល>ឥឡូវនេះយើងដូចជាយឺតពេលទៅ<>ហើយ<។>ដូច្នេះក្រៅពីលោក ថាន់ ធីម នេះសូមឲ្យដើមបណ្តឹង<ម្នាក់>ទៀតត្រូវសុំឲ្យបានចប់នៅថ្ងៃនេះ ដើម្បីធ្វើយ៉ាងម៉េចឲ្យនៅថ្ងៃ ស្អែកហ្នឹងយើងអាចសួរដើមបណ្តឹងបួននាក់បន្ថែមទៀត។ <ទោះជាយ៉ាងដូចម្តេចក្តី យើងត្រូវប្រាកដថា ដើមបណ្តឹងរដ្ឋប្បវេណី>ដែលមកភ្នំពេញតាំងពីម្សិលម៉្ងៃអាច<មានឱកាសនិយាយ>ឲ្យបានចប់នៅត្រឹម ថ្ងៃស្អែក។

ចំពោះការឆ្លើយតបទៅនឹងមេធាវី កូប៉េ ចំពោះយើង គឺមិនមែនជាសវនាការសាមញ្ញទេ វាជា

សវនាការមួយដើម្បីឲ្យជនរងគ្រោះគាត់អាចថ្លែងអំពីទុក្ខសោក និងព្យសនកម្មដែលគាត់ទទួលរង។ ដូច្នេះ សំណើរបស់យើងហ្នឹង គឺថាសុំធ្វើយ៉ាងម៉េចឲ្យ<ដើមបណ្ដឹងទាំងប្រាំបីនាក់នេះបានថ្លែងនៅចំពោះមុខអង្គជំនុំជម្រះទៅតាមកាលវិភាគដែលខាងយើងខ្ញុំបានដាក់ជូនរួចហើយ>។ <សូមអរគុណលោកប្រធាន>។

**ប្រធានអង្គជំនុំ៖**

ដោយចាប់ផ្ដើមពីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងបន្ថយពេល។ បន្ថយការសួរសំណួរ បង្រួមការសួរសំណួររបស់ខ្លួនមកនៅតែ៣០នាទីបានហើយ។ បើភាគីខាងនោះកាត់បន្ថយ ភាគីពាក់ព័ន្ធក៏ថយតាមនោះដែរ។

បាទ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៣៧:១៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមសួរទៅកាន់ចំណុចសំខាន់ៗឲ្យបានឆាប់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** មុនពេលសម្រាកអាហារថ្ងៃត្រង់ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកថានៅពេលដែលលោកទៅដល់អង្គរកា គឺមានមនុស្សប្រុសប្រហែលជា១០នាក់ និងស្រី១០នាក់នៅទីនោះ។ នៅក្នុងឯក-សារដែលយើងមាននៅក្នុងសំណុំរឿងគឺ E3/5035 លោកនិយាយអំពីអ្នកទោសជាង១០០នាក់ ហើយនៅក្នុងកំណត់ហេតុ<នៃការស្ដាបចម្លើយ>នៅចំពោះមុខចៅក្រមស៊ើបអង្កេតដែលមានលេខ E319/12.3.8 នៅចម្លើយទី៧៧ លោកនិយាយថាមានអ្នកទោស<ចំនួន>៧០នាក់។ តើលោកអាចជម្រាបបានទេថា ចំនួនអ្នកទោសនៅអង្គរកាហ្នឹងមានផ្លាស់ប្ដូរទេ មានកើនឡើង ឬក៏ថយ<នៅពេលណាមួយទេ>?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ អ្នកទោសនៅអង្គរកាហ្នឹង ដល់រួចទៅវាអ៊ីចេះ ដល់រួចទៅចូលនៅនុ៎ងបានមួយប្រាវៗហ្នឹង គឺថាដល់រួចគេបញ្ចេញទៅទៀត។ គេចងបញ្ចេញ ខ្ញុំនៅតែលបមើលនៅក្នុងគុកហ្នឹង។ គុកហ្នឹងវាជញ្ជាំងក្ដារ អ៊ីចឹងទៅ តានូវ ហ្នឹងគាត់អ្នកបិតត្រចៀកត្នោតៗ គាត់បិតអ៊ីចឹងទៅគាត់បញ្ចេញម្នាក់ទៅចង

ជាប់ បញ្ចេញម្នាក់ទៀតចងជាប់។ បញ្ចេញរហូតយកទៅៗសំដៅភ្នំដំរីរមៀលទៅ មិនដឹងយកទៅណា ឬទៅណាខ្ញុំអត់បានដឹងដែរ។ ព្រោះខ្ញុំនៅក្នុងគុក។ បាទ គាត់បញ្ចេញអ៊ីចឹង បានថាវាអ្នកទោសចេះតែថយៗអ៊ីចឹងទៅណ៎ា។

**ស៖** <មុននេះ>លោកនិយាយថា ម៉េង បានសួរចម្លើយលោក<នៅពេលមួយ>។ តើគេមានកន្លែងជាក់លាក់ណាមួយដើម្បីសួរចម្លើយទេក្រៅពីផ្ទះឃុំឃាំងនុ៎ង?

[១៣:៣៩:៤២]

**ឆ៖** បាទ លោក ម៉េង ហ្នឹង គេសួរចម្លើយហ្នឹង ពេលដែលអ្នកទោសមុនៗហ្នឹងគេចេញទៅធ្វើការអស់។ ហើយអ៊ីចឹងនៅតែខ្ញុំម្នាក់ឯងហ្នឹង គេចាក់រនុកខ្នោះនៅខាងក្រៅហ្នឹង ហើយគេហូតរនុកហ្នឹងចេញបានធ្លាក់កងពីជើងខ្ញុំ។ បាទ ហើយដល់រួចទៅគេហៅមកកន្លែងរោងដែលគេស្នាក់នៅការពារពួកខ្ញុំហ្នឹង។ គេហៅមកសួរចម្លើយនៅកន្លែងហ្នឹង គេមិនមែនសួរនៅក្នុងមន្ទីរឃុំឃាំងទេ គឺគេហៅមកសួរស្ងាត់នៅកន្លែង -- រោងគេ នៅជិតហ្នឹងដែរបាទ។

**ស៖** សូមអរគុណ។ តើលោកមានបាននិយាយជាមួយអ្នកទោសផ្សេងទៀតទេដើម្បីឲ្យដឹងថា<ពីមូល>ហេតុ<ដែល>អ្នកទោសទាំងអស់ហ្នឹងត្រូវបានគេចាប់ និងយកមកឃុំនៅ<ក្នុងគុកអង្គរកាហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បាននិយាយជាមួយអ្នកក្រៅទេ និយាយជាមួយអ្នកដែលស្គាល់គ្នាហ្នឹង។ ដូចលោកគ្រូមួយនោះ ខ្ញុំស្គាល់ឈ្មោះគាត់លោកគ្រូ កាន់។ ហើយអាចារ្យម្នាក់នោះឈ្មោះគាត់អាចារ្យមឹក បាទ គាត់និយាយថា គាត់ហ្នឹង គេតាមដានគាត់រាល់តែថ្ងៃអ៊ីចឹង គេថាតែឯងហ្នឹងធ្វើស៊ើនៅភ្នំពេញហ្នឹង? ហើយគាត់ថាគាត់ធ្វើគ្រូបង្រៀនបាទ គេនៅតែតាមដានអ៊ីចឹងទៅអី អាចារ្យមឹក ហ្នឹងគាត់មិនដឹងមានទោសកំហុសអីទេ ខ្ញុំអត់បានសួរគាត់ដែរ។ ហើយដល់រួចទៅបានមួយថ្ងៃ ពីរថ្ងៃគាត់ -- គេបញ្ចេញយកទៅទៀតទៅ មិនដឹងយកទៅឯណាមកអីណើ ខ្ញុំអត់បានដឹងដែរ។

**ស៖** លោកបានឆ្លើយថា អ្នកយាម ឬកម្មាភិបាលអង្គរកាហ្នឹងនាំ<នាំអ្នកទោស>ទៅភ្នំដំរីរមៀល ហើយខ្ញុំគិតថានៅពេលដែលលោកឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត លោកគិតថាគេនាំទៅហ្នឹង គឺយកទៅសម្លាប់ចោល។ អ៊ីចឹងតើលោកមានភស្តុតាង ឬក៏មានព័ត៌មានអ្វីបានជាលោកហ៊ាននិយាយថាគេនាំ<>យកទៅសម្លាប់ចោល<>?

[១៣:៤២:២៤]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ខ្ញុំៗ បាទលបមើលតាមប្រហោងជញ្ជាំងក្តារវាវែរអត់ជិតទេ អត់មាននីវ មានអីទេ វាមានប្រហោង ហើយខ្ញុំលបមើលពីក្នុងគុកហ្នឹងទៅឃើញដូចថាគេចងជាប់អ៊ីចឹងទៅ គេបញ្ចេញម្តងមួយៗ អ៊ីចឹងទៅ ហើយដល់ចងជាប់យកចេញមួយទៀត ហើយមិនដឹងយកទៅឯណាមកឯណា? វាយក វាមានតែទៅសំដៅភ្នំដំរីរមៀលនោះឯង ខ្ញុំនៅក្នុងមន្ទីរឃុំឃាំង ខ្ញុំមិនអាចមាន ដូចថាភស្តុតាងអីឲ្យបានជាក់ស្តែងទេ ព្រោះខ្ញុំនៅជាប់ក្នុងខ្នោះបាទ វាអត់មានភស្តុតាងអីជាក់ស្តែងទេ ពីព្រោះខ្ញុំនៅជាប់ខ្នោះ ខ្ញុំគ្រាន់តែបានឃើញ ខ្ញុំលបមើល។

**ស៖** ពាក់ព័ន្ធទៅនឹង<បុគ្គលម្នាក់>ដែលលោកបាននិយាយអម្បាញ់មិញនេះ គឺគ្រូកាន់ នេះ។ អ៊ីចឹងតើលោកស្គាល់<ឈ្មោះពិតប្រាកដ និង>អាយុគាត់ទេ <ឬលោក>ស្គាល់ឈ្មោះ<ប្រពន្ធ>របស់គាត់ទេ<>?

**ឆ៖** បាទ ខ្ញុំនិយាយអំមិញថាលោកគ្រូ កាន់ ហ្នឹង ខ្ញុំស្គាល់ពិតប្រាកដ ព្រោះគ្រូហ្នឹងគាត់ធ្លាប់បង្រៀនខ្ញុំបាទ។ អ៊ីចឹងអាយុគាត់ហ្នឹងប្រហែលជាខ្ទង់៧០ ជាងបាទ។

**ស៖** អ៊ីចឹងតើលោកធ្លាប់<ឮ>ឈ្មោះ<>ពៅ កាន់ <ប្រពន្ធគាត់ឈ្មោះ> ពិន យឹម មកពីឃុំសោម ស្រុកគីរីវង់<ដែរឬទេ>?

**ឆ៖** បាទ ខ្ញុំបាទអត់ធ្លាប់ឮទេ ឈ្មោះ ពៅ កាន់ ហ្នឹងអត់ដែល។

**ស៖** នៅពេលដែលលោក<ជាប់>ឃុំនៅអង្គរកា លោកមានស្គាល់ឈ្មោះ ណុន ទេ គាត់ជាប្រជាជនមកពីស្រុក១០៩ ហើយគាត់ទៅរស់នៅឃុំត្រពាំងធំខាងជើង?

**ឆ៖** ឈ្មោះ ណុន ក៏ខ្ញុំអត់បានស្គាល់បាទ មិនដឹងជានៅភូមិណាអី កន្លែងណាព្រោះវានៅភូមិខុសគ្នា គ្រាន់តែឃុំជាមួយគ្នា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

នៅក្នុងសំណុំរឿងមានឯកសារ E3/4093 ខ្ញុំនឹងមិនបង្ហាញជូនដើមបណ្តឹងរដ្ឋប្បវេណីភ្លាមទេ ប៉ុន្តែខ្ញុំសួរសំណួរបឋមមួយចំនួនសិន<នៅជុំវិញប្រធានបទនេះ> ប្រសិនបើលោក<មេធាវីមិនជំទាស់ទេនោះ>។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

[១៣:៤៥:៤០]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំសូមលើកជូននូវសំណើមួយ។ ខ្ញុំសូមស្នើថា យើងគួរតែឈប់សំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី <ហើយគិតថាគួរតែអញ្ជើញគាត់>ត្រឡប់មក<ទីនេះម្ដងទៀត>នៅពេលណាមួយដើម្បីផ្ដល់សក្ខីកម្មឲ្យបានពេញលេញ<វិញ។> ខ្ញុំជឿជាក់ថា<គាត់គឺជា>សាក្សីដែលមានការពាក់ព័ន្ធគឺថា<ចម្លើយគាត់មានភាពទាក់ទងគ្នា> ហើយខ្ញុំក៏ចង់សួរ<គាត់ជាច្រើនសំណួរផង>ដែរ<។ ពិចារណាលើ>ការកត់សម្គាល់ពីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះសាលាដំបូង ថាតើឥឡូវនេះយើងគួរតែផ្ដោតទៅលើ<ព្យសនកម្មរបស់>បណ្ដឹង<ហើយហៅគាត់>ឲ្យ<មកផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីបាន>ដែរឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ ជាក់ច្បាស់ណាស់ យើងបានរំឭកហើយ។ រំឭករួចហើយថា ឲ្យសួរសំណួរពាក់ព័ន្ធជាមួយនឹងស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ លើកលែងតែអាផលប៉ះពាល់ទៅនឹងអង្គហេតុហ្នឹងវាជាប់គ្នា។ ឥឡូវហ្នឹងបញ្ហាពេលវេលា។ អំមិញ បានរំឭកហើយពេលវេលាហ្នឹងគឺពេលវេលាខ្លីណាស់។ បើគិតពីពេលនេះទៅប្រាំមួយនាក់នេះទំនងមិនចប់ទេ ទាំងថ្ងៃស្អែក។ អំមិញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំបន្ថែមទៀត។ ហើយបើសិនជាឲ្យសួរអូសបន្លាយទៅលើអង្គហេតុនោះ វាទំនងជាគាត់ហ្នឹងត្រូវបានកោះហៅក្នុងនាមមកផ្ដល់សក្ខីកម្ម មិនមែនក្នុងឋានៈមកថ្លែងសេចក្ដីទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះទេ។ យើងបានរំឭកតាំងពីព្រឹកមក។

[១៣:៤៧:៣៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានមុនពេល<អង្គជំនុំជម្រះពិភាក្សាគ្នា> ខ្ញុំចង់សួរ<គាត់ពីការលំបាកដែលគាត់បានទទួលរងនៅឯគុក>អង្គរកា <វាជាមូលដ្ឋានមួយ>ដែលខ្ញុំព្យាយាមបង្ហាញនូវភាពជឿជាក់របស់<សាក្សីរូបនេះ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សួរដេញដោលគាត់>ជាមួយនឹងភស្ដុតាងមួយចំនួនដែលយើងបាន<ឮពីសក្ខីកម្មនានានៅទីនេះ> ថាគាត់ស្គាល់អ្នកដែលជាប់ទោសមួយចំនួន<ដែលជាប់នៅក្នុងគុកនោះដែរឬទេ។> ខ្ញុំគិតថា<សំណួររបស់ខ្ញុំពិតជា>មានភាពសមស្របហើយលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៩:៥៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ អំមិញលោកបានស្នើសុំថា ឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សាជាថ្មីម្តងទៀត ដើម្បីស្តាប់សក្ខីកម្ម ព្រោះគាត់មានដឹងរឿងហេតុច្រើន។ ឥឡូវ លោកមានអ្វីបន្ថែមទៀតដែរឬទេ ដើម្បីឲ្យច្បាស់លាស់ជជែកបញ្ហានេះឲ្យច្បាស់ដាច់ស្រេចតែម្តង សឹមឈានទៅដល់បញ្ហាបន្ទាប់ទៀត ខំវិលវល់នៅនឹងឯង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថានេះជាសំណើរបស់ខ្ញុំពិតហើយ។ ព្រោះសាក្សីនេះជាសាក្សីដែលមានពាក់ព័ន្ធ គួរតែកោះត្រឡប់មកវិញនៅពេលក្រោយ នៅពេលណាមួយ ដើម្បីផ្តល់លទ្ធភាពសួរសំណួរទៅគាត់<ឲ្យបានពិស្តារជាងនេះ>។ ខ្ញុំយល់ស្រប ហើយនេះជាសំណើរបស់យើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីលោក ខៀវ សំផន មានមតិយោបល់អ្វីទេលើសំណើនេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

យើងខ្ញុំមិនមានសំណើដើម្បីឲ្យកោះហៅមកវិញទេ លោកប្រធាន។ ក៏ប៉ុន្តែបើសិនព្រះរាជអាជ្ញាគាត់ចង់ប្រើជាសាក្សីអង្គហេតុ<ជាជាងគ្រាន់តែជាអ្នកមកផ្តល់សក្ខីកម្មលើព្យសនកម្មគាត់ទេ> គឺយើងក៏<យល់ថាគាត់ទទួលបានការអនុញ្ញាតឲ្យសួរដេញដោល>ពាក់ព័ន្ធទៅនឹងអង្គហេតុ ដូច<សាក្សីអង្គ-ហេតុនានា>ដែរ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន ដូចដែលលោកប្រធានបានជ្រាបហើយ ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺស្ថិតនៅក្នុងបញ្ជី<សាក្សី>បម្រុងរបស់សហព្រះរាជអាជ្ញាតាំងពីខែមិថុនា ឆ្នាំ២០១៤ មកម្ល៉េះ។ ដូច្នេះ យើងឆ្លៀតឱកាសនេះដើម្បីសួរសំណួរបន្ថែម ព្រោះថាគាត់ជាមនុស្សតែមួយគត់ បើតាមខ្ញុំដឹងនោះ ក្នុងចំណោមជនរងគ្រោះនៅក្នុងអង្គរកាដែលបានរស់រានមានជីវិត ហើយនិងមកផ្តល់សក្ខីកម្ម។ ខ្ញុំគិតថាដូចជាមិនចាំបាច់កោះហៅគាត់មកវិញទៀតទេ ពីព្រោះថា<យ៉ាងយូរបំផុត១០ ទៅ ១៥នាទីទៀតតែប៉ុណ្ណោះ>ខ្ញុំ<>បញ្ចប់សំណួរ<របស់ខ្ញុំហើយ>។ ដូច្នេះ ខ្ញុំគិតថាយើងអាចបន្តទៅទៀតបាន ដោយការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចម្លើយរបស់គាត់ គឺ<ជា>ការឈឺចាប់របស់គាត់<ដែលបានហែលឆ្លងកាត់>ហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញខាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងម៉េចដែរ?

[១៣:៥២:៥៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

យើងមិនឯកភាពតាមសំណើរបស់មេធាវី នួន ជា ក្នុងការកោះហៅមកវិញនោះទេ លោកប្រធាន។ ឥឡូវនេះ គឺអង្គជំនុំជម្រះជាអ្នកសម្រេច។ យើងៗមានគោលដៅរបស់យើង គឺយើងធ្វើយ៉ាងម៉េចឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើងទាំងអស់ហ្នឹង គឺអាចសួរបានទៅតាមពេលវេលាកំណត់។ យើងបានព្យាយាមប្រឹងប្រែងដើម្បីរៀបចំរបៀបវារៈរបស់យើងដើម្បីធ្វើយ៉ាងម៉េចឲ្យដើមបណ្តឹងរដ្ឋប្បវេណីពីរត្រូវបានស្តាប់កាលពីម្សិលមិញ<>អ៊ីចឹង អាទិភាពរបស់យើ<>។ <>ថាឥឡូវ<ខ្ញុំដឹងថាទាំងព្រះរាជអាជ្ញា និងមេធាវីការពារក្តីក៏មានអាទិភាពរបស់ខ្លួនដែរ។ ដូច្នេះហើយ>អង្គជំនុំជម្រះជាអ្នកសម្រេចទៅពាក់ព័ន្ធទៅនឹងសំណើ<ផ្សេងៗរបស់ភាគី>។ ក៏ប៉ុន្តែគោលជំហររបស់យើងគឺថាធ្វើយ៉ាងម៉េចឲ្យអ្នកទាំងប្រាំបីនេះ អាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងទុក្ខសោករបស់គាត់ឲ្យចប់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមសួរទៅ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិវិញថា អំមិញនេះ លោកត្រូវការពេលវេលា១៥នាទីទៀត ហើយតាំងពីពេលព្រឹកមករហូតដល់ពេលនេះ ហើយថែម១៥នាទីទៀត លោកគណនាមើល ថាតើលោកប្រើពេលវេលាប៉ុន្មាន? ចុះភាគីដទៃទៀត គេនឹងទាមទារប្រើដូចលោកដែរ។ ព្រោះបូករួមជានឹងដើមបណ្តឹងរដ្ឋប្បវេណីផង គឺវាត្រូវ គេទាមទារប្រហាក់ប្រហែលគ្នា។ លោកពិចារណាដែរឬទេ លើបញ្ហាដែលលោកគិតថា នឹងមានពេលវេលា១៥សំណួរ -- អ៎! ១៥នាទី សួរក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទៀត បន្ថែមពីលើពេលវេលាដែលបានប្រើប្រាស់រួចហើយនេះ?

[១៣:៥៤:៤៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំព្យាយាមនិយាយអំពីការអនុវត្តជាក់ស្តែងនៅទីនេះ។ ប្រហែលមិនអាចស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីឲ្យពេញលេញ ទាក់ទងទៅនឹង<សិទ្ធិរបស់>ភាគីដទៃដែលត្រូវតាំងសំណួរចំពោះគាត់ ហើយ<ម្យ៉ាងទៀតយើងត្រូវស្តាប់>ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតដែល<>មានវត្តមានរហូត

ដល់ថ្ងៃសុក្រ។ <ដូច្នេះ>យើង<ត្រូវ>រៀបចំ ចាត់ចែងទៅតាមការអនុវត្តជាក់ស្តែង។ ទាក់ទងទៅនឹងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញនោះ ដែលថាអាចមានព័ត៌មានពាក់ព័ន្ធទៅនឹងអង្គហេតុនៅដំណាក់កាលជំនុំជម្រះពេលក្រោយ។ តើមានការជំទាស់ទៅនឹងសំណើសុំនេះទេ? បើមិនមានការជំទាស់ គឺថាយើងនឹងបន្តទៅមុខទៀត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមិនជំទាស់ទេ បន្ទាប់មកពីពិភាក្សាជាមួយមេធាវីដើមបណ្តឹងនោះ គឺថាយើងអត់ជំទាស់ទេ ប្រសិនបើអង្គជំនុំជម្រះយល់ថា<>នេះជាភាពចាំបាច់នោះ<>។

[១៣:៥៥:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៦:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះបន្ទាប់ពីស្តាប់សំណើសុំរបស់មេធាវីការពារក្តី នួន ជា និងមតិយោបល់របស់ភាគីពាក់ព័ន្ធ ហើយនិងបានពិនិត្យពិភាក្សាក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសម្រេចបញ្ឈប់ការស្តាប់សេចក្តីរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ក្នុងនាមអ្នករៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដោយលើកពេលទៅ -- គាត់ទៅស្តាប់នៅពេលក្រោយនៅពេលណាមួយសមស្រប ដោយអញ្ជើញគាត់មកឲ្យផ្តល់សក្ខីកម្មលើសក្ខីកម្មអង្គហេតុ ដែលពេលនោះគាត់អាចប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងសំណួរសួរអំពីអង្គហេតុផង ហើយនិងអំពីស្ថានភាពទុក្ខសោកវេទនា ព្យសនកម្មនិងសំណើសុំផ្សេងៗរបស់គាត់ក្នុងនាមគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះផង។

បាទ អរគុណលោក ថាន់ ធឹម ឥឡូវនេះអង្គជំនុំជម្រះបញ្ឈប់ការស្តាប់ការសាកសួររបស់លោកពាក់ព័ន្ធជាមួយនឹងសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យត្រឹមនេះ ដោយអង្គជំនុំជម្រះនឹងពិនិត្យនូវពេលវេលាសមស្របខាងមុខនេះ ពេលវេលាណាមួយកោះអញ្ជើញលោកឲ្យមកចូលរួមផ្តល់សក្ខីកម្មលើអង្គហេតុពាក់ព័ន្ធជាមួយនឹងអ្វីដែលលោកបានដឹងក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងរឿងក្តីនេះ។ ហើយលោកអាចត្រឡប់ទៅបានហើយៗ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹង

បុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ថាន់ ធីម វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ដោយឡែកបុគ្គលិក ធី.ភី.អូ អាចអង្គុយនៅកន្លែងនោះដដែលចុះ រង់ចាំអង្គជំនុំជម្រះបន្តធ្វើការ -- សវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-881 ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-881 មកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនា និងព្យសនកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:០០:៤១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ សួស្តីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកឈ្មោះអី?

*(មានបញ្ហាបច្ចេកទេស)*

បាទ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក បេង បឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ បេង បឿន។

**ស៖** អរគុណ តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំបាទកើតថ្ងៃទី១២ ខែ១២ ឆ្នាំ១៩៤៤ អាយុពិត គឺឆ្នាំ១៩៣៩។

**ស៖** អរគុណ ហើយចុះទីលំនៅរបស់លោកបច្ចុប្បន្ននេះ នៅទីកន្លែងណា?

**ឆ៖** បច្ចុប្បន្ន ខ្ញុំបាទនៅភូមិ៤ ឃុំដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

**ស៖** បាទ អរគុណ ហើយបច្ចុប្បន្ននេះ លោកប្រកបមុខរបរធ្វើអ្វី?

**ឆ៖** ខ្ញុំបាទសព្វថ្ងៃ ជាគ្រូបឋមសិក្សាចូលនិវត្តន៍។

**ស៖** បាទ អរគុណ ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ម្តាយបង្កើតរបស់លោក គាត់ឈ្មោះអី?

[១៤:០២:៤៩]

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ បេង – ទ្រី បេង។ ម្តាយឈ្មោះ វ៉ា ប៊ិន។

**ស៖** ប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ តេង អេង តែបានអនិច្ចកម្មទៅហើយ មានកូនបីនាក់។ ខ្ញុំមានប្រពន្ធក្រោយមួយទៀត កូនបានមួយនាក់ឈ្មោះ ហៃ ហ្សាឌះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោក ហឿន ក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់វេទិកាឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានចំពោះលោក ដែលជាអាទិ៍ ដូចជាការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់អំពីបទឧក្រិដ្ឋ និងបានកើតឡើងពិតប្រាកដ រហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅរឿងក្ដីនេះ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋត្រូវចោទប្រកាន់ ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោក ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ គឺចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១០៧៥ *(ស៊ីក)* រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

បាទ នេះជាសិទ្ធិដែលអង្គជំនុំជម្រះផ្ដល់ទៅលោក ប៉ុន្តែតាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំសួរសាកសួរពាក់ព័ន្ធជាមួយនឹងព្យសនកម្ម អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីសាកសួរពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មទាំងឡាយ ដែលកើតមានចំពោះដើមបណ្ដឹងរដ្ឋប្បវេណី បេង ហឿន ។

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៤:០៤:៥២]

**លោក ឡោ ជុនធី៖**

បាទ អរគុណ។ សូមគោរពលោកប្រធាន ហើយសូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរលោក បេង ហឿន នៅពេលនេះ គឺខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងជាមេធាវីមកពីអង្គការជំនុំផ្នែកច្បាប់នៃកម្ពុជា សូមជម្រាបសួរលោកអ៊ំ បេង ហឿន នៅពេលនេះ អំពីផលប៉ះពាល់ ព្យសនកម្មអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណុច

ចាប់ផ្តើម គឺខ្ញុំបាទ សូមសួរទៅលើថាតើនៅក្នុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ លោកអ៊ំនៅកន្លែងណាដែរ?

**លោក បេង បឿន៖**

**ឆ៖** ឆ្នាំ១៩៧៥ ខ្ញុំបាទ នៅទីក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ តើនៅក្នុងថ្ងៃ១៧ មេសានោះ លោកអ៊ំនៅផ្ទះនៅក្រុងភ្នំពេញ តើនៅពេលនោះមានជួបព្រឹត្តិការណ៍អីដែរឬទេ នៅក្នុងពេលដែលអ៊ំនៅក្នុងទីក្រុងភ្នំពេញ?

[១៤:០៦:៤៧]

**ឆ៖** ពេលនោះ ខ្ញុំបាននៅក្នុងគេហៅថា ការិយាល័យទី៥ ហ្នឹងគេឲ្យខ្ញុំមកនៅខាងកាសែតកងទ័ព ហើយនិងធ្វើជាសៀវភៅទស្សនាវដ្តីកងទ័ព។ ពេលនោះខ្ញុំបានថ្ងៃទី១៧ មេសា ហ្នឹង ខ្ញុំបាទជួបលោក ម៉ី ស៊ីចន មកកន្លែងការិយាល័យ គេកន្លែងវិទ្យុទាហាន កងខាងទ័ព ក៏បានជួបប៉ុណ្ណឹង។ ហើយគាត់ក៏បានសួរខ្ញុំអំពីសោបន្ទប់សម្រាប់វិទ្យុជាតិផ្សាយហ្នឹង។ ខ្ញុំក៏ថា មិនដឹងទេតេជគុណ។ គាត់ក៏ដកកាំភ្លើងបាញ់ក្បាលអ្នែងឥឡូវ ហើយខ្ញុំក៏ភ័យពេក ក៏១ចាប់ មានកងទ័ពខ្មែរក្រហមពីរនាក់គាត់ចាប់ដៃជាប់ គាត់បម្រុងដកកាំភ្លើងបាញ់ ក៏ខ្ញុំរួចពេលហ្នឹងទៅ។ ងាកមើលទៅខាងឡានឃើញស្ត្រីម្នាក់ជួតក្បាលកន្សែងស្លូត្រ គងជើងលើដៃចង្កូត ហើយក៏ខ្មែរក្រហមពីរនាក់នុំងគ្រាលោក ម៉ី ស៊ីចន ឡើងឡានទៅវិញទៅ។ នៅពេលនោះ គាត់ទៅសំដៅវិទ្យុជាតិវត្តភ្នំ។ ខ្ញុំបាទ ឮសូរលោក ម៉ី ស៊ីចន ហ្នឹងតែពីរបីម៉ាត់ទេ។ លោក ម៉ី ស៊ីចន បានស្រែកអំពាវនាវទៅតាមបណ្តាខេត្តឲ្យកងទ័ពយើងដាក់អាវុធចុះ ដើម្បីមិត្តយើងចូលមកចរចា និងសន្តិភាព។ ពេលនោះលោក ម៉ី ស៊ីចន និយាយបានប៉ុណ្ណឹងក៏បាត់សំឡេង។ ឮសំឡេងក្រោយមកទៀតថា "អញមកដោយចុងអាវុធ មិនមែនមកចរចា និងសន្តិភាពទេ"។ ខ្ញុំបានឮប៉ុណ្ណឹងក៏ញាក់សាច់ នាំកូននាំចៅប្រមូលអីវ៉ាន់ តែពេលនោះខ្ញុំមិនទាន់ចេញទេ។

**ស៖** បាទ អរគុណ។ លោកអ៊ំថា មិនទាន់ចេញ តើចេញពីភ្នំពេញនៅថ្ងៃប៉ុន្មានបាទ?

**ឆ៖** បាទ ខ្ញុំបាទចេញពីភ្នំពេញនៅថ្ងៃទី១៨ វេលាម៉ោងដប់ តែចេញមកដើរបណ្តើរចាំមើលផ្លូវបណ្តើរដែលកងទ័ពរុញឲ្យចេញមកតែបីថ្ងៃ ដើម្បីរៀបទីក្រុង។ ដើរបណ្តើរ គិតបណ្តើរ ចេះតែដើរតិចៗមិនបានបង្ខំទេ។

**ស៖** បាទ អរគុណ។ ចុះលោកអ៊ំពេលដែលធ្វើដំណើរទៅដល់ហៅថា ស្ទឹងកំពង់ត្រាំនោះ តើលោកអ៊ំមានបានជួបព្រឹត្តិការណ៍អីនៅពេលធ្វើដំណើរហ្នឹងទៀតទេបាទ?

[១៤:១០:០៤]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំបាទចេញពីភ្នំពេញទៅអស់រយៈច្រើនថ្ងៃទៅដល់ស្ទឹងកំពង់ត្រាំ កងទ័ពបានឲ្យឈប់មុននឹងឆ្លងស្ពានទឹក ឆ្លងស្ទឹងទៅព្រោះស្ពានវាបាក់។ គេបានចែកអង្ករមួយកំប៉ុងក្នុងម្នាក់ឲ្យដាំបាយហូបឆ្លងត្រើយម្ខាងទៅដល់ម្ខាងដាំបាយហូបរួចមិនទាន់ផង គេដេញឲ្យទៅមុខនឹងជួបអង្គការខាងមុខ។

**ស៖** បាទ អរគុណ។ តើនៅពេលដែលគេដេញឲ្យទៅជួបអង្គការ ឬមួយពេលនោះ តើមានខាងកងទ័ពខ្មែរក្រហមនោះគាត់សួរអំពីប្រវត្តិរូប ថាតើអ្នកណាធ្វើអីខ្លះ ឬមួយអ្នកមានបណ្ណាសក្តិ ឬមួយអ្នកអី គេនឹងឲ្យទៅធ្វើការងារវិញ តើមានដែរអត់បាទ?

**ឆ៖** បាទ ពេលនោះខ្ញុំធ្វើដំណើរទៅដល់វត្ត ហៅថាវត្តទួលក្រួស ខ្ញុំបាទទៅជួបឪពុកមា ក៏បានជួបជុំជាមួយនឹងគាត់ ហើយខ្មែរក្រហមក៏គេដើរមកសួរថា អ្នកណាធ្វើអ្វី គេនឹងនាំទៅធ្វើការនោះវិញនៅទីក្រុងភ្នំពេញ។ ពេលនោះឪពុកមាខ្ញុំកេះខ្ញុំហើយកេះទៀត ខ្ញុំចង់តែឆ្លើយ ក៏ប៉ុន្តែទប់អារម្មណ៍បានក៏មិនឆ្លើយទៅវិញ។ ហើយក្រៅពីនោះ ក៏ខ្ញុំបានឃើញគេនាំ មិនដឹងជាធ្វើការអ្វីទេ នាំហើយសើចដាក់ខ្ញុំបានត្រឡប់ទៅ -- បាននិយាយប្រាប់ខ្ញុំថា ខ្ញុំត្រឡប់ទៅធ្វើការវិញហើយ អង្គការនាំខ្ញុំទៅធ្វើការខាងភ្នំពេញវិញហើយ ហើយបានស្រែកប្រាប់ខ្ញុំ ហើយលោកដែលស្គាល់ៗថាដូចលាគ្នា ថាបានទៅធ្វើការនៅកន្លែងវិញហើយ។ ម្នាក់ក្រោយទៀតបានសើច ហើយញញឹមៗថាបានទៅអ៊ីចឹងដែរ។ ខ្ញុំបានជួបបានតែប៉ុណ្ណឹង ហើយក៏ខ្មែរក្រហមរុញទៅមុខទៀត។

[១៤:១២:២៦]

**ស៖** បាទ អរគុណ។ ចុះមកដល់ពាក់កណ្តាលឆ្នាំ១៩៧៦ តើលោកអ៊ំបានអញ្ជើញទៅដល់កន្លែងណាទៀតបាទ?

**ឆ៖** ខ្ញុំបាទ បន្ទាប់ពីនោះមក បានចូលមកកន្លែងផ្ទះឪពុកមានៅហៅថាវត្តស្វាយចាស់ ស្រុកគងពិសី ខ្ញុំរស់នៅបាន៣យប់៣ថ្ងៃជាមួយនឹងគ្រួសារ។ ឪពុកមា បានរយៈ៣ថ្ងៃនោះ ឪពុកមាបានកេះប្រាប់ថា ឲ្យក្មួយឯងចេញឲ្យផុតក្នុងព្រឹកហ្នឹង ឲ្យទាន់ពេលពីព្រលឹម ពីព្រោះផែនការកូនប្រសារគាត់ជាប្រធានភូមិមេខ្មែរក្រហមប្រចាំភូមិនោះ។ ដូច្នេះ គាត់ប្រាប់ថាឲ្យចេញទៅក្មួយ ឈ្មោះ អាអេង ហ្នឹងវាទៅប្រជុំដើម្បីយកគ្រួសារក្មួយឯងទៅសម្លាប់ចោលហើយ ខ្ញុំក៏នាំគ្រួសារចេញពីព្រលឹមដូចគាត់ប្រាប់មែន។

**ស៖** បាទ អរគុណ។ ចុះនៅពេលដែលទៅដល់កន្លែងស្នាក់នៅជាអចិន្ត្រៃយ៍នោះ តើគេបញ្ជូនលោកអ៊ំហ្នឹងទៅធ្វើអីតទៀតបាទ?

**ឆ៖** បាទ ពេលនោះ ខ្ញុំទៅដល់ហៅថាភូមិថ្មកែវ ឃុំញ៉ៃងញ៉ង ស្រុកត្រាំកក់ ខ្ញុំបានរស់ទៅដល់ហើយ ជួបឪពុកម្ដាយក្មេកដែលគាត់ជាអ្នកមូលដ្ឋាន ក៏គាត់ទទួលខ្ញុំ រាក់ទាក់ខ្ញុំ គាត់ប្រាប់ថា "កូនឯងមានអ្វីលាក់ឲ្យអស់"។ ក៏មួយសន្ទុះមកទើបមានប្រធានភូមិ និងឈ្លបភូមិគេមកឆែករក ថាមាននាឡិកាលីដួឬទេ? ខ្ញុំថាគ្មានទេ ហើយមានខ្សែមាសខ្សែប្រាក់ឬទេ? ខ្ញុំថាក៏គ្មានដែរ មានខោអាវយោធា ទាហានអីក៏គ្មានដែរ។ ហើយពេលនោះគេបំបែកយកទៅ ហៅថានៅភូមិមួយនៅរួមគ្នាទាំងអស់ ទាំងភូមិ ទាំងចិន ទាំងយួន ទាំងខ្មែរ ហៅថាភូមិត្រាំកក់ហ្នឹង។

[១៤:១៥:០៣]

**ស៖** អរគុណ។ ចុះនៅពេលដែលលោកអ៊ំទៅធ្វើការនៅស្រែប្រាំង ពេលដែលទៅធ្វើការនៅស្រែប្រាំងហ្នឹង តើអ៊ំបានជួបព្រឹត្តិការណ៍អីបន្តទៀតទេ?

**ឆ៖** ពេលដែលខ្ញុំបាទទៅស្រែប្រាំង គេយករូបខ្ញុំទៅដាក់ក្នុងកងចល័តមួយទៅធ្វើស្រែប្រាំងនោះ ឲ្យដកឲ្យស្ទូង ឲ្យជាន់រហាត់ទឹកដាក់ស្រែដាក់ស្រូវជាមួយនឹងប្អូនថ្លៃដែលជួបមុខគ្នារាល់ថ្ងៃ ហើយដេកនៅរស់នៅតែផ្ទះជាមួយគ្នា។ ពេលនោះមិនដឹងជាបាត់ប្អូនទៅណាខ្ញុំក៏យំអាណិតប្អូន នឹកប្អូនពេកព្រោះស្រឡាញ់ប្អូន បាត់ពេលនោះខ្ញុំខ្លោចផ្សាក្នុងចិត្តណាស់។ ខ្ញុំនឹកថា មានថ្ងៃណាមួយនឹងបាត់រូបខ្ញុំទៅទៀតមិនខាន។

**ស៖** បាទ អរគុណ។ តើរឿងបាត់ហ្នឹង លោកអ៊ំអាចជម្រាបអង្គជំនុំជម្រះឲ្យបានច្បាស់បន្តិចទេថាតើបាត់ហ្នឹងវាមកពីរឿងហេតុអីបានបាត់ហ្នឹង? បាត់ប្អូនថ្លៃហ្នឹងណា?

**ឆ៖** បាទ ការបាត់នោះមកពីមេកងគាត់ចេះតែសួរដេញដោល ហើយនិយាយលេងៗ ក៏ប្អូនខ្ញុំវាចេះតែថា ខ្ញុំក៏ចេះដែរបើកឡាន ខ្ញុំក៏ចេះដែរបើកកប៉ាល់ហោះ ខ្ញុំក៏ដែររើដាក់ទីឡូ ចេះសព្វគ្រប់ពេក ដល់ប៉ុន្មានថ្ងៃប្រហែលជា បីបួនថ្ងៃក្រោយមកស្រាប់តែ បាត់សូន្យឈឹងតែម្តង។ ព្រោះអីវាចេះសព្វគ្រប់ពេកតាមខ្ញុំឮគេខ្សឹបប្រាប់មក អ្នកជិតខាងដែលស្រឡាញ់រាប់អានខ្ញុំ គេថា ឲ្យតែអួតចេះអ្វី គឺវាមិនឲ្យចេះលើវាទាំងអស់។ ដូច្នេះ បានជាបាត់ប្អូនខ្ញុំពេលហ្នឹងទៅ។

[១៤:១៨:០១]

**ស៖** បាទ អរគុណ។ ចុះនៅពេលដែលលោកអ៊ំបានត្រឡប់ពីស្រែប្រាំងមកវិញ មកភូមិណាពេលដែលមកដល់ភូមិ អ៊ំបានជួបប្រទះនឹងរឿងហេតុការណ៍អីបន្ទាប់ទៀតហ្នឹង?

**ឆ៖** ពេលដែលមកពីស្រែប្រាំងហើយ គេឲ្យខ្ញុំសម្រាកនៅក្នុងភូមិ នៅក្នុងសហករណ៍គេឲ្យខ្ញុំ

មើលគោៗ ហើយក៏ប្រើពុះអុស ពុះអ៊ីចឹងទៅ។ ខ្ញុំក៏ដើរៗទៅមើលគោ ដេញគោក៏ប្អូនថ្លៃមួយទៀត ប្អូនថ្លៃ ខាងប្រពន្ធបង្កើតនឹងក៏វាឡើងបេះដូងៗ ពេលនោះ វាឃើញខ្ញុំក៏បោះដូងឲ្យខ្ញុំមួយ ថា "បង" គ្រាន់តែបងហ្នឹង បោះឲ្យមកៗស្រាប់តែ វាចុះដល់ក្រោមមានគេដឹកដៃទៅទៀត។ ដឹកដៃទៅ ខ្ញុំអត់ដឹងថា ទៅណាទេ ដល់ខ្ញុំមកដល់សហករណ៍វិញបានមើលឃើញទៅ គេចងស្លាបសេកពីក្រោយអូសទាញទៅទាំងថ្ងៃត្រង់។ ហើយបានកូនខ្ញុំបាទ យំតាម ទៅប្រាប់មកដល់ប្រាប់ខ្ញុំហើយ ខ្ញុំថា ចុះមាកូនឯងទៅណា? ខ្ញុំសួរថា "អាប្អូ ទៅណាអាប្អូ? កូនឯងម៉េចក៏យំអ៊ីចឹង?" ថា "ពូប្អូ ពូនោះចាប់ចងអូសដៃយកទៅហើយ"។ បានកូនខ្ញុំរត់ទៅប្រាប់ប្រពន្ធ អាប្អូ នោះ ក៏ប្រពន្ធ ប្អូ នោះស្ទុះៗទៅឃើញ ក៏ស្រែកយំអង្វរសុំគេមកទាំងកូនខ្ញុំទាំងអីហ្នឹងថា "កុំឲ្យយំ អញយកតែខ្មាំងទេ អ្ហែងចង់រួមដៃជាមួយនឹងខ្មាំងឬអី?" ហើយពេលនោះក៏ម្តាយក្មេកនោះបោះភួយឲ្យមក ឲ្យយកទៅឲ្យ ក៏អ្នកបណ្តើរប្អូនថ្លៃខ្ញុំនោះ ទាញភួយបោះចោលវិញ ហើយច្រានឲ្យដួលមកក្រោយមក ហើយក៏គេនាំយកទៅ ទៅបាត់ទៅ មិនដឹងទៅទីកន្លែងណា។

[១៤:២០:១៨]

**ស៖** អរគុណ។ តើអ្វីដែលគេនាំគាត់ទៅហ្នឹង គឺពាក់ព័ន្ធនឹងការបោះដូងមួយហ្នឹង ឬក៏ពាក់ព័ន្ធនឹងរឿងអីផ្សេងទៀត?

**ឆ៖** បាទ រឿងហ្នឹង ខ្ញុំដឹងពាក់ព័ន្ធពីរឿងបោះដូងឲ្យខ្ញុំមួយហ្នឹងតែម្តង ពីព្រោះអី អ្នកមូលដ្ឋាននៅហ្នឹងគេថា "អ្វីក៏ដោយជារបស់រួមទាំងអស់ មិនឲ្យហូបឯកជនទេ"។ បើប៉ានបោះឲ្យខ្ញុំមួយហ្នឹងគឺចោទគាត់ហ្នឹងជាខ្មាំងតែម្តង។

**ស៖** បាទ អរគុណ។ ចុះនៅពេលមួយទៀត ដែលលោកអ៊ំត្រូវបានគេចោទថា មានការខុសសីលធម៌ហ្នឹង តើមានមូលហេតុអីទេ?

**ឆ៖** បាទ ពេលនោះខ្ញុំមកចេញពីភូមិ គេឲ្យទៅកងភ្ជួរទៀត។ កងភ្ជួរហ្នឹងភ្ជួរជាស្រែស្ទូងធម្មតាទេ។ ហើយដល់ហើយពីដាក់ភ្ជួររាស់មក ក៏យកគោទៅចង ចងហើយក៏ខ្ញុំបានចេញពីភូមិមុន។ ចេញពីភូមិមក ម្តាយក្មេកនោះបានប្រាប់ថា "កូនឯងទៅជួបប្អូន ហើយប្រាប់មកមើលម៉ែផង ព្រោះម៉ែឈឺនៅឯផ្ទះ" ហើយក៏ខ្ញុំចងគោហើយ ខ្ញុំចាំបណ្តាំម្តាយប្រាប់ហ្នឹង ក៏ចៃដន្យជួបប្អូនមែន ទៅតាមផ្លូវរទេះហ្នឹងគាត់ដើររកបន្លែ។ ហើយក៏ខ្ញុំប្រាប់ ប្រាប់ថា "មីអូន ម៉ែឲ្យអូនឯងទៅមើលគាត់ឈឺផង នៅផ្ទះ" គ្រាន់តែប៉ុណ្ណឹង មេកងភ្ជួរខ្ញុំទាញដៃខ្ញុំទៅ ដកពូថៅ បណ្តើរហើយបណ្តើរអូសខ្ញុំចូលព្រៃ មកសួរសម្តុតខ្ញុំថា "អ្នកឯងនិយាយហ្នឹងខុសសីលធម៌"។ ខ្ញុំអង្វរគេ អង្វរហើយអង្វរទៀត គេមិនចង់ព្រមអង្វរ អង្វរទាល់

តែគេយល់ព្រមហ្នឹង អង្វរយូរមែនទែន។ បានគេព្រម ថា “ថ្ងៃក្រោយ ឈប់ធ្វើអ៊ីចឹង” “ខ្ញុំបាទ ឈប់ធ្វើអ៊ីចឹងទៀតហើយ” ឆ្លើយប្រាប់តបទៅគេវិញថា “ខ្ញុំស្បថហើយ ខ្ញុំលែងហ៊ានធ្វើអ៊ីចឹងទៀតហើយ។ បើថ្ងៃក្រោយឃើញខ្ញុំធ្វើអ៊ីចឹងទៀត យកខ្ញុំទៅណា យកចុះ”។

[១៤:២២:៥៦]

**ស៖** ចុះមានរឿងមួយទៀត ដែលថានៅទំនប់អូរសារាយ តើពេលនោះ គឺមានឪពុកក្មេកបានស្លាប់។ ចុះបើឪពុកក្មេកបានស្លាប់ហ្នឹង តើមានព្រឹត្តិការណ៍អីកើតឡើង ដែលលោកអ៊ំបានកត់សម្គាល់?

**ឆ៖** បាទ ពេលពីហើយពីភ្ជួរមក គេនឹងយកខ្ញុំមកលើកទំនប់ លើកទំនប់មកដល់អូរសារាយបានជួបនឹងបងស្រី បងថ្លៃ។ លើកជាមួយគ្នាហ្នឹង បានរយៈពេលប្រហែលជា២ថ្ងៃ គេឲ្យដំណឹងមកដល់បងថ្លៃខ្ញុំ គាត់ជាមេក្រុមៗក្នុងកងលើកទំនប់ហ្នឹង។ គេឲ្យដំណឹងថា “អឺ! ឪពុកក្មេកនោះឈឺ ឲ្យសុំគេទៅមើលទៅ បានទេ ព្រោះឯងជាមេកង មេក្រុងស្រាប់”។ ខ្ញុំក៏ឮនៅជិតនោះ ខ្ញុំគ្រាន់មើលមុខបង ពីព្រោះខ្ញុំជាអ្នកថ្មី ហើយគាត់មូលដ្ឋាន ក៏គាត់សុំ សុំគេ គេមិនឲ្យទៅ ព្រោះថា “មិត្តឯងទៅហ្នឹង គាត់ហ្នឹងជាអីបើជាគឺខ្ញុំឲ្យទៅ”។ លុះគាត់សុំគេមិនបានទៅហើយ ក៏គាត់ទ្រាំអត់មិនទៅ។ ដល់ស្អែកឡើងគេឲ្យដំណឹងថាស្លាប់។ ស្លាប់ហើយក៏គាត់រត់មកឱបខ្ញុំម្តងទៀត ហើយខ្ញុំក៏យំជាមួយនឹងបងម្តងទៀត។ អាណិតឪពុកក្មេកផង អាណិតបងថ្លៃផង ស្លាប់គ្មានបានទៅ ហើយគាត់មេគេ គេថា “បើស្លាប់ទៅហើយ អ្នកឯងទៅប្រស់គាត់រស់ក៏អី” ថាតែប៉ុណ្ណឹង គាត់ឱបខ្ញុំយំទាំងបងទាំងប្អូន។ ហើយប៉ុណ្ណឹង ក៏គាត់អង្គុយឱបខ្ញុំនៅពីរនាក់ហ្នឹង គេគ្រប់គ្នាគេឈរមើលនៅជុំវិញខ្ញុំហ្នឹង ពីរនាក់បងប្អូន។

[១៤:២៥:០៧]

**ស៖** បាទ អរគុណ។ តើលោកអ៊ំមានអ្វីដែលជាចុងក្រោយ ហើយថ្លែងពីការឈឺចាប់ ចំណុចដែលពាក់ព័ន្ធដូចជា អម្បាញ់មិញអ៊ំបានលើកឡើង គឺការឈឺចាប់ពាក់ព័ន្ធនឹងបាត់ប្អូនថ្លៃពីររូប ហើយនិងការដែលមិនបានទៅជួបជាចុងក្រោយនៃឪពុកក្មេក? តើលោកអ៊ំអាចលើកឡើងថា តើអាកម្រិតនៃការឈឺចាប់ ការបាត់បង់នូវសម័យនោះ វាឈានទៅដល់កម្រិតណា?

**ឆ៖** ខ្ញុំបាទអន់ចិត្ត និងឈឺចិត្តដោយសារមូលហេតុអ្វីដែលយកប្អូនថ្លៃទៅហើយ មិនប្រាប់មូលហេតុ មានកំហុសរឿងអ្វី។ យកទៅហើយ អត់មានប្រាប់កំហុសថា អ្នកឯងមានទោសអីៗ ឬក៏ផ្តល់ដំណឹងថា អញយកប្អូនមិត្តឯងទៅហើយ ក៏មិនឮសម្តីមួយម៉ាត់។ ហើយរឿងបេះដូងហ្នឹងមួយទៀត ក៏មិនប្រាប់កំហុសគ្នាថា អ្នកឯងកុំហូបឯកជន គឺរបស់នេះសុទ្ធតែជារបស់រួម គឺមិនប្រាប់កំហុសអ្វីទាំង

អស់។ រួចមកដល់ជាឪពុកក្មេកមួយរូបដែលគាត់ចិញ្ចឹមបីបាច់ថែរក្សាខ្ញុំ និងឲ្យកូនគាត់មកធ្វើជាគ្រួសារខ្ញុំម្នាក់ហ្នឹង គាត់ថ្នាក់ថ្នមបងថ្លៃខ្ញុំហ្នឹងក៏គាត់ស្រឡាញ់ខ្ញុំ រឿងអីទាំងបងទាំងប្អូន ក៏គាត់មិនឲ្យទៅមើលឬក៏ទៅជួបមុខចុងក្រោយបង្អស់ហ្នឹង។ ខ្ញុំតូចចិត្តណាស់សព្វថ្ងៃ ខ្ញុំឈឺចិត្តណាស់ តែបើខ្ញុំបាននិយាយអ៊ីចឹងហើយ មើលឃើញនូវតែរឿងថ្មីៗនៅនឹងមុខ។

**ស៖** អរគុណ។ រឿងដែលលោកអ៊ំបានលើកឡើងអំពីការបេះដូងនេះ តើវាអាចជារឿងមួយពាក់ព័ន្ធទៅនឹងការ -- គេមានផ្តល់អាហារបានគ្រប់គ្រាន់ដែលធ្វើឲ្យយើងហ្នឹងមានការឃ្លាន។ តើរបបអាហារនៅក្នុងសម័យនោះ គេកម្រិតយ៉ាងណាដែរនៅពេលដែលលោកអ៊ំទៅធ្វើការងារនៅក្នុងកងចល័តទាំងនោះ?

[១៤:២៧:៤៦]

**ឆ៖** បាទ ពេលទៅធ្វើកងចល័ត ឬកន្លែងទីនានាក៏ហូបអាហារមិនបានគ្រប់គ្រាន់ដែរ ហើយកម្លាំងពលកម្មក៏ឲ្យខំប្រឹង ឲ្យធ្វើស្រែកុំឲ្យសល់ដីមួយចំអាម។ ហើយស្រូវធ្វើបានគ្រប់គ្រាន់នៅតែហូបមិនគ្រប់គ្រាន់ ពេលមកហូបម្តងៗតាំងដើរមកក្រវែលជុំវិញតុខ្លួនខ្ញុំដែលហូបរួមគ្នាប៉ុន្មាននាក់ហ្នឹង។ សួរថា ហូបឆ្អែតទេ បើឆ្លើយថា មិនឆ្អែត ក៏មិនបាន។ ហើយសួរឆ្ងាញ់ទេ ហើយខ្ញុំថាមិនឆ្ងាញ់ក៏មិនបានសុទ្ធតែមានរឿងយកទៅសម្លាប់ចោលទាំងអស់។

**ស៖** បាទ អរគុណ។ ចុះលក្ខខណ្ឌកំហិតនៃការធ្វើការងារហ្នឹង តើគេកំហិតយ៉ាងដូចម្តេច?

**ឆ៖** បាទ កំហិតធ្វើការងារគឺធ្វើពីព្រលឹមចេញទៅចាំតែស្នូរជួងដែលគេវ៉ៃទៅៗការដ្ឋាន បើគេឲ្យទៅការដ្ឋានណា ត្រូវទៅការដ្ឋានហ្នឹង។ ដល់គេវ៉ៃជួរឲ្យសម្រាកទើបសម្រាកបាន គេវ៉ៃជួងឲ្យចូលទើបចូលបាន។ ហើយដល់ពេលយប់ហូបអាហារហើយ សម្រាកបន្តិចមិនបានទេឲ្យមកជីករណ្តៅដាំចេក ដាំដូង រហូតដល់ម៉ោង១០យប់ទើបឲ្យសម្រាក។ ពេលនោះ ដល់ពេលសម្រាកហើយក៏នៅដេកផ្ទះក៏មិនបានសុខដែរនៅតាមដាននៅក្រោមផ្ទះហ្នឹង។ ពេលនោះ ខ្ញុំបានឮម្តាយក្មេកប្រាប់ថា កូនឯងកុំមាត់កុំកអីឲ្យសោះដេក ហើយដាំដើមគ កុំមាត់។ ពេលនោះ ខ្ញុំក៏មានគំនិតមួយនឹកឃើញថា ចេះតែលបស្តាប់ពេក ដល់ពេលកូនដេកនៅជាមួយហ្នឹង គេឲ្យពេលថ្ងៃ១០ គេប្រជុំម្តងឲ្យជួបនឹងគ្រួសារនិងកូន ក៏ខ្ញុំមានគំនិតមួយដាក់កន្ទោរទឹកនោមនៅបៀតកន្លែងគេចាំលបមើល ឃើញកន្លែងណា ខ្ញុំជះពីលើក្បាលកន្លែងហ្នឹង ហើយខ្ញុំទះខ្លួនខ្ញុំ ហើយខ្ញុំថា កូនអាចង្រៃនេះដេកអាក្រក់ណាស់ ធាក់កន្ទោរទឹកនោមកំពប់អស់ តែប៉ុណ្ណឹង។

[១៤:២៩:៥៦]

**ស៖** អរគុណ។ នៅពេលដែលរៀបបែកនៅឆ្នាំ១៩៧៨ហ្នឹង តើលោកអ៊ុំបានជួបនូវព្រឹត្តិការណ៍អីទេ ចុងក្រោយហ្នឹង?

**ឆ៖** បាទ ពេលចុងក្រោយហ្នឹង ខ្ញុំគេយកមកឲ្យដាំដំណាំជាមួយតាៗបានរយៈប៉ុន្មានថ្ងៃ ក៏គេបបួលទៅប្រជុំនៅចម្ការសៀង។ ប្រជុំនៅចម្ការសៀងប្រជុំម្ដងនោះ គេមិនទាន់រៀបរាប់ថាអ្វីទេ គ្រាន់តែគេថាមានគម្រោងថា យើងប្រជុំលើកក្រោយ យើងនឹងបានសប្បាយទាំងអស់គ្នា។ យើងយកទាំងអ្នកឈឺទាំងអស់ហ្នឹង អ្នកដើរមិនរួចក៏សែងយកមកដែរ អូសរទេះយកមកដែរ ហើយអ្នកនិយាយនោះ គឺគណៈស្រុកគេ។ គេថា លើកក្រោយក៏គេមិនកំណត់ថ្ងៃទេ គាត់ថា លើកក្រោយនឹងសប្បាយទាំងអស់គ្នានៅចម្ការសៀងហ្នឹង។ ដល់តែ៣ថ្ងៃក្រោយ ៣ថ្ងៃ ៤ថ្ងៃក្រោយមក បានគេដឹងដំណឹងថា អ្នកមូលដ្ឋានគេដឹងថា ធ្វើនំបញ្ចុកដើម្បីយកសម្លាប់ចោលទៅវិញ និងដាក់ថ្នាំបំពុលអ៊ីចឹង។

**ស៖** ចុះកូនៗរបស់លោកអ៊ុំនោះ សម័យនោះគេឲ្យទៅធ្វើអីដែរ?

**ឆ៖** បាទកូនខ្ញុំមានមួយជាកងកុមារ នៅកងកុមារ ខាងកុមារសែងអង្កាមដាក់ស្រែ។ គ្រាន់តែសែងអង្កាមដាក់ស្រែដើរហួសស្រែបន្តិច ក៏អាប្រធានកងកុមារហ្នឹងវាស្រែកថា អ្អែងទៅសែងយកឲ្យខ្លាំងធ្វើអី ដាក់អីនេះមិនដាក់ ហើយចាប់គ្នាវ៉ៃទាត់ៗ ហើយខ្ញុំឃើញអ៊ីចឹងមិនដឹងជាជួយយ៉ាងម៉េច ពីព្រោះខ្ញុំដើរនៅបៀតហ្នឹង ខ្ញុំអ្នកមើលគោ ដែលខ្ញុំគេឲ្យសម្រាក ពីព្រោះអីខាងខ្ញុំគេឲ្យម្ដងទៅនេះម្ដងទៅនោះ ម្ដងមកខាងតាៗ ម្ដងខាងចល័ត ម្ដងខាងភ្ជួរអ៊ីចឹងទៅ ស្រេចតែគេប្រើ។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកអ៊ុំ ហើយចុងក្រោយលោកអ៊ុំអាចសំណូមពរទៅខាងលោកប្រធានអង្គជំនុំជម្រះបាន ប្រសិនបើលោកអ៊ុំមាន។ លោកប្រធានខ្ញុំអស់សួរហើយ។

លោកអ៊ុំអម្បាញ់មិញ ខ្ញុំបានជម្រាបលោកអ៊ុំថា ប្រសិនលោកអ៊ុំមានសំណួរអីអាចសំណូមពរទៅខាងលោកប្រធានបាន។ ប្រសិនបើអត់ទេ ក៏អត់អីដែរបាទ។ អរគុណលោកអ៊ុំ។

[១៤:៣៣:៣៧]

**លោក បេង បឿន៖**

បាទ ខ្ញុំអត់មានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អ៊ីចឹងអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំមិនមានសំណួរច្រើនទេ ហើយសំណួរខ្ញុំភាគច្រើន គឺជាការសុំបំភ្លឺតែប៉ុណ្ណោះ។ នៅក្នុងសំណុំរឿង យើងមានទម្រង់បែបបទពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកដែលមានលេខ E3/4719។ អ្វីដែលដែលខ្ញុំមិនបានស្តាប់ឮនោះនៅថ្ងៃនេះ គឺឈ្មោះជនរងគ្រោះនៅក្នុងគ្រួសាររបស់លោក។ តើលោកអាចរៀបរាប់ឈ្មោះបានទេ ពីព្រោះថាតាមរយៈការបកប្រែនុំង ពេលខ្លះខ្ញុំឮបងប្អូនថ្លៃប្រុស ឬក៏បងប្អូនថ្លៃស្រី។ អ៊ីចឹងវាមិនសូវច្បាស់ទេ អ៊ីចឹងសូមលោកបញ្ជាក់ម្តងទៀត។ លោកដំបូងឡើងនិយាយអំពីបងថ្លៃម្នាក់ នៅពេលដែលលោកកំពុងតែ<ច្រូត>ស្រូវប្រាំង<។ គេចាប់បងប្អូនថ្លៃលោកម្នាក់នោះ>ពីព្រោះគេដឹងថា គាត់ចេះបើកឡាន។ អ៊ីចឹងតើលោកអាចប្រាប់ឈ្មោះបានទេ ថាតើបង<ឬប្អូន>ថ្លៃ<នោះ>ឈ្មោះអីដែរ?

[១៤:៣៥:០៩]

**លោក បេង បឿន៖**

**ឆ៖** បាទ ថានៅស្រែប្រាំងនោះថាចេះបើកឡាន ចេះអ្វីៗទាំងអស់គឺប្អូនថ្លៃរបស់ខ្ញុំឈ្មោះ វុធ , ប្រុស។

**ស៖** អំមិញខ្ញុំស្តាប់ឮទៅថា វុធ អ៊ីចឹងទេលោក វុធ?

**ឆ៖** បាទ ឈ្មោះ វុធ។

**ស៖** ចុះម្នាក់ដែលថាគេចាប់ខ្លួនដោយសារឡើងបេះដូងហ្នឹងឈ្មោះអីដែរ?

**ឆ៖** បាទ នោះឈ្មោះ បួ ក៏ប្រុសដែរ ជាប្អូនថ្លៃដែរ។

**ស៖** <លោកមាន>បង<>ថ្លៃស្រី<ឈ្មោះ> នី ហ្នឹងតើត្រឹមត្រូវទេ<?> ហើយគាត់ក៏ត្រូវបានគេចាប់ខ្លួនដែរមែនទេ?

**ឆ៖** គាត់មិនមែនឈ្មោះ នី ទេបាទ ហ្នឹងៗជាបងថ្លៃស្រីឈ្មោះៗបងវាភ្លេចឈ្មោះបងថ្លៃហ្នឹងឈ្មោះ បងណន។

**ស៖** សូមអរគុណ។ <មុននេះបន្តិច> លោកនិយាយអំពីជីវភាពរស់នៅឃុំញ៉ែងញ៉ង ហើយនៅក្នុងទម្រង់បែបបទព័ត៍មានអំពីជនរងគ្រោះនោះ លោកនិយាយថាខ្មែរក្រហមបានបំបែកមនុស្សដាក់តាមជនជាតិ <>ចិនដាក់ដោយចិន <>យួនដាក់ទៅជាមួយពួកយួន។ ចុះខ្លួនលោកផ្ទាល់នោះ លោកគេដាក់ឲ្យលោករស់នៅជាមួយនឹងអ្នកថ្មី ឬក៏គេលាយឡំជាមួយនឹងប្រជាជនមូលដ្ឋាន?

**ឆ៖** បាទ ពេលនោះគេដាក់ខ្ញុំ--

[១៤:៣៧:១៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប ដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំសូមធ្វើការបញ្ជាក់តបទៅនឹងសេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។ តាមខ្ញុំចាំសម្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់អំពីការដាក់ជនជាតិចម្រុះនៅក្នុងភូមិមួយជាមួយគ្នា មិនមែនដាក់ដោយឡែកពីគ្នាទេ ដោយគាត់និយាយអំពីជនជាតិចាម -- សូមទោសជនជាតិចិន ជនជាតិយួនអីក្នុងភូមិជាមួយគ្នាទាំងអស់ ដាក់ចម្រុះគ្នា មិនមែនបំបែកគ្នាមួយក្រុមៗទេ។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយស៍ ដេស្នាឯល៖**

**ស៖** លោកប្រធាន អ៊ីចឹងមានតែដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ ដែលគាត់អាចបំភ្លឺបាន ក៏ប៉ុន្តែក្នុងឯកសារដែលយើងមានគឺ E3/4719 នៅទំព័រ<ទី២>សង្ខេបជាភាសាបារាំងនោះគឺទំព័រ<លេខ> 00898351។ ប្រហែលជាខុស ឬក៏យ៉ាងម៉េច ក៏ប៉ុន្តែក្នុងនោះដាក់ថា "ខ្មែរក្រហមបំបែកមនុស្សដាក់តាមជនជាតិ"។ អ៊ីចឹងតើយ៉ាងម៉េចដែរលោកអាចឆ្លើយបានទេ គេដាក់បំបែកតាមជនជាតិ ឬក៏គេដាក់<ឲ្យនៅ>ចម្រុះតែម្ដង?

[១៤:៣៨:៤៥]

**លោក បេង បឿន៖**

**ឆ៖** បាទ ពេលនោះខ្ញុំមកដល់ដំបូងគេដាក់នៅរួមគ្នាមែន ហើយដល់តែក្រោយមកគេចាប់បំបែកភូមិចិននៅដោយចិន ភូមិខ្មែរនៅដោយខ្មែរ ហើយខ្ញុំនៅជាមួយភូមិចិន និងភូមិវៀតណាម តែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ <បើតាមលោកដឹង>តើមានបែងចែកប្រជាជន<ខ្មែរតាម>ប្រភេទ<> ប្រជាជនថ្មី ប្រជាជនចាស់<ដែរឬ>ទេ?

**ឆ៖** បាទ ពេលនោះគេបែងចែកហើយ គេដកឪពុកម្ដាយខ្ញុំទៅនៅខាងមូលដ្ឋានទៅ ហើយខ្ញុំក៏នៅខាងភូមិថ្មី គេហៅថាភូមិថ្មីហ្នឹង ជាប់ភូមិត្រពាំងរំពាក់ ហ្នឹងជាមួយនឹងភូមិចិន យួនហ្នឹង ហើយខ្មែរខាងខ្មែរគេៗនៅខ្មែរដោយឡែកទៅ។

**ស៖** លោកអាចជម្រាបបានទេថា <នរណា>ជាអ្នកដឹកនាំក្រុមប្រជាជន<ថ្មី> ក្រុមប្រជាជនចិន ក្រុមវៀតណាម<?> <តើពួកគេដឹកនាំក្រុមរបស់គេរៀងៗខ្លួន>? <ឬ>តើជា<>មានប្រជាជនថ្មីគេអ្នកដឹកនាំ<? សុំទោស ខ្ញុំចង់សំដៅប្រជាជនចាស់ទេ។ អ៊ីចឹងតើ> ក្រុមចិន <និង>ក្រុមវៀតណាម <មានអ្នកដឹកនាំរបស់គេផ្ទាល់ ឬប្រជាជនចាស់ជាអ្នកដឹកនាំក្រុមទាំងពីរ>ហ្នឹង?

[១៤:៤០:៣៨]

**ឆ៖** ពេលនោះ គេបែងចែកអ៊ីចឹងហើយគេមិនយកយើងអ្នកថ្មីទេ គេយកសុទ្ធតែអ្នកមូលដ្ឋាន ហើយមនុស្សដែលខ្ញុំមិនស្គាល់ យកមកគ្រប់គ្រងទៅលើភូមិនីមួយៗហ្នឹង។

**ស៖** នៅក្នុងពេលដែលលោកនៅស្រុកត្រាំកក់ ឃុំញ៉ែងញ៉ង គឺនៅពេលដែលលោកធ្វើការនៅក្នុងកងចល័ត តើលោកអាចរៀបរាប់បានទេ ថាតើលក្ខខណ្ឌការងារហ្នឹងវាល្អទៅៗ ឬក៏កាន់តែអាក្រក់ទៅៗ?

**ឆ៖** បាទ ការងារក្នុងកងចល័តបើខ្ញុំមើលទៅវាមិនល្អទេ គឺការងារសុទ្ធតែធ្ងន់។ ហើយកងចល័តដែលទៅខាងស្រែប្រាំងក៏សុទ្ធតែប្ដូរស្លាប់ប្ដូររស់ ហើយកងចល័តខ្ញុំមួយទៀត ខាងជីកទំនប់នៅទួលក្រួស ក៏យ៉ាប់។ ហើយសុទ្ធតែរែកឡើងកម្ពស់ ៦ម៉ែត្រ ហើយឱ្យស្រែកហ៊ោសប្បាយនៅពេលដែលគេថាប្រតិភូគេមកម្ដងៗ។ កន្លែងណាក៏សុទ្ធតែយ៉ាប់ទាំងអស់ អត់មានកន្លែងណាស្រួលទេ។

**ស៖** សំណួរចុងក្រោយលោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងទម្រង់បែបបទព័ត៌មានរបស់លោកបានសរសេរថា៖ “នៅញ៉ែងញ៉ង ខ្មែរក្រហមបានប្រាប់ថា គេបញ្ជូនយួនទៅយួនវិញដោយដូរជាមួយខ្មែរនៅទីនោះ”។ តើលោកដឹងអ្វីខ្លះអំពីការដោះដូរគ្នាហ្នឹង? ហើយការដោះដូរគ្នាហ្នឹងកើតឡើងនៅពេលណាដែរ?

[១៤:៤២:២៩]

**ឆ៖** ខ្ញុំនៅចាំឆ្នាំមិនបានទេ។ គ្រាន់តែខ្ញុំនៅផ្ទះជិតនឹងវៀតណាមម្នាក់ទាំងប្ដីទាំងប្រពន្ធហ្នឹង នៅ

---

ជិតគ្នា។ ហើយក៏ពេលនោះ គេថា អង្គការនឹងបញ្ជូនបងប្អូនវៀតណាមទៅស្រុកវិញ មិនឮថា ផ្លាស់ប្តូរទេ។ ក៏ដល់ពេលដែលគាត់រៀបចេញពីផ្ទះទៅ ក៏គាត់ប្រាប់ខ្ញុំថា គាត់និយាយប៉ែឡាំៗ គាត់ថា "បងអា ខ្ញុំវិលទៅស្រុកវិញហើយ គេដោះដូរខ្ញុំឲ្យខ្ញុំទៅវិញហើយព្រឹកហ្នឹង"។ ហើយក៏ខ្ញុំបែកពីគាត់ទៅ គាត់ក៏លាគ្នាទៅបាត់ទៅ ទាំងប្តីទាំងប្រពន្ធហ្នឹង ទុកចោលផ្ទះហ្នឹងឲ្យអ្នកក្រោយៗនៅទៀត។

**ស៖** បើអ៊ីចឹងលោកដឹងទេថា វៀតណាមទាំងអស់ហ្នឹងគេបញ្ជូនទៅហ្នឹង<បានទៅដល់ប្រទេសវៀតណាម ឬលោកមិនបានដឹងពីដំណឹងនេះ>ទេ?

**ឆ៖** បាទ ការងារដែលគេបញ្ជូនទៅហ្នឹង គេមិនឲ្យប្រជាជនសូម្បីតែអ្នកមូលដ្ឋានក៏គេមិនឲ្យដឹងដែរ គេដឹងតែអ្នកណានាំទៅ គឺអ្នកហ្នឹងអាចដឹងរឿងនោះ។ ហើយខ្ញុំអ្នក១៧ ខ្ញុំមិនអាចដឹងបានណា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងដែលគាត់អង្គុយថ្លែងរៀបរាប់ទុក្ខសោកវេទនានេះនៅវេលាម៉ោងបីខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:00]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅ

ក្រុមមេធាវីការពារក្ដី។ ដំបូង សូមប្រគល់ទៅមេធាវីការពារក្ដីលោក នួន ជា។

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់លោក។ សំណួរដំបូងរបស់ខ្ញុំ គឺទាក់ទងទៅនឹងប្អូនថ្លៃប្រុសរបស់លោក ដែលបានឡើងបេះដូង ហើយក្រោយមកគឺថា លោកបាននិយាយថា ត្រូវបានគេចាប់ខ្លួន ដោយសារតែព្យាយាមលួចបេះផ្លែដូង។ តើមាន<គេ>ប្រាប់លោកថា នេះគឺជា<មូល>ហេតុដែលនាំឱ្យគេចាប់ខ្លួនប្អូនថ្លៃរបស់លោកហ្នឹងដែរឬទេ?

**លោក បេង បឿន៖**

**ឆ៖** បាទ ពេលនោះ មានគេខ្សឹបប្រាប់ បានខ្ញុំដឹងរឿងថាគេចាប់ ហើយទទួលខ្ញុំដើរមកតាមក្រោមនោះក៏ពេលនោះ ក៏ឃើញដល់កន្លែងសហករណ៍គេហ្នឹងបានឃើញ ចេញផុតសហករណ៍ទៅហើយ ខ្ញុំមើលឃើញតាមពីក្រោយ។ ហើយបានដល់កូនខ្ញុំហ្នឹងមករក ស្រែករកខ្ញុំថា "ប៉ា! គេចាប់ពូឬទៅហើយ" បានខ្ញុំថា "កូនឯង ទៅប្រាប់មីង"។ ដល់មីងប្រពន្ធ ឬ ហ្នឹងមកយំអង្វរសុំគេ ក៏គេថា យំសោកអី អញចាប់តែខ្លាំងទេ។ ពេលនោះក៏គេច្រានប្អូន និងប្រពន្ធហ្នឹងដួលមកក្រោយមក ហើយក៏គេនាំយកទៅ។

[១៥:០១:០៦]

**ស៖** <អ្វីដែលលោករៀបរាប់មកនេះខ្ញុំមិនប្រាកដថាខ្ញុំយល់បានទាំងអស់នោះទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ សំណួររបស់ខ្ញុំគឺ តើមាននរណា ប្រធានកង ប្រធានឃុំ ឬអាជ្ញាធរមានសមត្ថកិច្ចណាប្រាប់លោកពីមូលហេតុដែលគេចាប់ប្អូនថ្លៃប្រុសរបស់លោក>?

**ឆ៖** ពេលនោះ គឺគ្មានអ្នកអំណាចណាទេ គឺអ្នកភូមិហ្នឹងខ្លួនឯង អ្នកឃ្វាលគោជាមួយគ្នាដែលគេជាអ្នកមូលដ្ឋាន កូនគេអ្នកមូលដ្ឋាននៅនឹងទេ ក៏ប្រាប់ខ្ញុំនោះ។

**ស៖** តើ<>គេមានប្រាប់ថា<>គេបានដឹងអំពីហេតុផលនៃការចាប់ខ្លួននេះ<ដោយរបៀបណា>ដែរទេ?

**ឆ៖** ពួកគេអាចដឹង ពីព្រោះអី គេជាអ្នកមូលដ្ឋាន គេអាចដឹងរហូតដល់កូន ដល់ចៅគេ ឱ្យតែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចាប់យកទៅគឺសុទ្ធតែយកទៅសម្លាប់ចោល ក៏ប៉ុន្តែមិនដឹងជាសម្លាប់ចោលទៅកន្លែងណា។ បានជាគេលួចប្រាប់ខ្ញុំ ខ្សឹបៗប្រាប់ខ្ញុំថា គេយកប្អូនឯងទៅហើយ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា ហេតុអ្វីបានជាប្រជាជន<ចាស់ ឬ>កូន<ប្រជាជនចាស់នោះ>មានសិទ្ធិដឹងអំពីហេតុផលនៃការចាប់ខ្លួនប្អូនថ្លៃប្រុសរបស់លោកនេះបានទេ?

[១៥:០៣:០៦]

**ឆ៖** បាទការគេដឹង តាមរយៈម៉ែឪគេ គេលួចខ្សឹបប្រាប់កូនចៅគេទៅ។ ដូច្នេះខ្ញុំ ហើយនិងកូនគេអ្នកមូលដ្ឋានក៏ខ្ញុំធ្វើអត្តចរិតស្លូតបូត ដូច្នេះគេទុកចិត្តខ្ញុំ គេក៏ប្រាប់ខ្ញុំ តាមរយៈការលាក់កំបាំងដែរ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើអាចនិយាយបានទេ ថា<>លោក<គ្រាន់តែ>និយាយស្មានៗអំពីការចាប់ខ្លួនប្អូនថ្លៃប្រុសរបស់លោក <តាមពិតទៅ>លោកមិនបានដឹង<មូល>ហេតុ<ដែលគេចាប់ខ្លួនប្អូនថ្លៃលោកទេ មែនទេ>?

**ឆ៖** ខ្ញុំមិនបាននិយាយស្មានទេ គឺខ្ញុំឃើញពីភ្នែកពិតតែម្ដង ពីចុះពីដូងមក គេដើរបានមកដល់សហករណ៍ ខ្ញុំក៏ដើរតាមដល់ពីក្រោយ ហើយក៏ពេលនោះ ក៏ឃើញកូនរត់មកតាម ប្រាប់ថា គេចាប់ ពូប្អូទៅបានខ្ញុំមើលឃើញទៅ។ ហេតុនេះហើយ បានខ្ញុំថាឃើញជាក់ស្ដែងនឹងភ្នែកខ្ញុំ។

**ស៖** ខ្ញុំមិនបាននិយាយជំទាស់អំពីការដែលលោកបានឃើញចាប់ខ្លួននោះទេ <តែខ្ញុំសួរថាតើលោកដឹង>ពីមូលហេតុនៃការចាប់ខ្លួន<នោះដែរឬទេ>។ បើខ្ញុំយល់មិនច្រឡំទេ លោកថា<អ្នកមូលដ្ឋានដែលជាម្ដាយឪពុករបស់ក្មេងម្នាក់បានដឹង>ពីមូលហេតុនៃការចាប់ខ្លួន<នោះ>។ ខ្ញុំសួរ<អ៊ីចេះវិញលោកដឹងទេ តើឪពុកម្ដាយក្មេងដែលប្រាប់លោកនោះ>បានដឹងអំពីមូលហេតុនៃការចាប់ខ្លួនប្អូនថ្លៃប្រុសរបស់លោកនេះ ដោយរបៀបណាដែរ?

[១៥:០៤:៥២]

**ឆ៖** គេដឹង ពីព្រោះអីគេបណ្ដើរកាត់មុខសហករណ៍នោះ គេអាចគេឃើញទាំងអស់គ្នា អ្នកនៅសហករណ៍ហ្នឹង ទាំងក្មេងទាំងចាស់ គេអាចឃើញ។ ហើយខ្ញុំក៏ដើរតាមក្រោយមក ក៏ឃើញជាមួយគ្នាក៏អ្នកទាំងអស់គ្នាចង្អុលប្រាប់។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីប្អូនថ្លៃរបស់លោកម្នាក់ទៀត<។ បើតាមខ្ញុំស្ដាប់យល់ថា>ប្អូនថ្លៃម្នាក់ទៀតហ្នឹង<ត្រូវគេចាប់ដោយសារគាត់>និយាយថា <គាត់>ចេះបើកឡាន <>ចេះបើកយន្តហោះ ធ្លាប់ចេះធ្វើអ្វីៗទាំងអស់។ ទាក់ទងទៅនឹងប្អូនថ្លៃប្រុសមួយនេះ តើលោកមានអាជ្ញាធរណាម្នាក់

ប្រាប់លោកដោយផ្ទាល់ថា ប្អូនថ្លៃលោកម្នាក់នេះត្រូវបានចាប់ខ្លួនដោយសារហេតុផលអីទេ?

**ឆ៖** រឿងនេះ ខ្ញុំអត់បានដឹងទេ ក៏ប៉ុន្តែខ្ញុំអាចយល់ច្បាស់ថា លើកមុនៗមកសុទ្ធតែប្រើពីកងចល័តហ្នឹងមកឲ្យមកដឹកគោ មកបាត់ៗទាំងអស់។ ហើយអ្នកភូមិ ពេលដែលខ្ញុំចូលដល់ភូមិហើយក៏មិនដែលឃើញ។ ដល់ពេលខ្ញុំត្រូវឡើងកងចល័តទៅជាមួយនឹងប្អូនថ្លៃធ្វើស្រែប្រាំងនោះ ក៏ពេលនោះបាត់ខ្លួនដោយមិនដឹងខ្លួន ព្រោះខ្ញុំដឹងថា តែបាត់ខ្លួនពីនុំងមកមិនដែលឃើញរស់ត្រឡប់មកភូមិស្រុកវិញទេ។ ដូច្នេះខ្ញុំសង្ស័យថា យកប្អូនខ្ញុំទៅសម្លាប់ចោល។

**សៈ** លោកដើមបណ្តឹងរដ្ឋប្បវេណី ចំណុចនេះក៏ហាក់បីដូចជាការនិយាយស្មានទៀតហើយ។ សំណួរខ្ញុំសួរថា តើ<ត្រឹម>ត្រូវទេ បើសិនជាខ្ញុំនិយាយថា សក្ខីកម្មដែលលោកបានឆ្លើយនេះគឺថា លោកមិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួនប្អូនថ្លៃប្រុសរបស់លោកម្នាក់នេះទេ?

**ឆ៖** ការនិយាយនេះគឺខ្ញុំស្មានក៏មិនខុសដែរ ពិតជាមិនខុស ពីព្រោះអីកាលណាចេញពីការដ្ឋានស្រែប្រាំងនោះ គឺត្រូវតែបាត់ខ្លួនរហូតមក រៀងរហូត។ ពេលដែលខ្ញុំសម្គាល់ឃើញគឺ ១០ទៅទាំង១០ហើយ បាត់ទាំង១០ហើយ។

**សៈ** ប្រហែលជាខ្ញុំសួរសំណួរខ្ញុំមិនច្បាស់ហើយ<មើលទៅ។> ខ្ញុំ<មិនបាន>សួរទៅលោកថា <>មានអ្វីអាចនឹងកើតឡើងក្រោយមកនោះ ទៅលើប្អូនថ្លៃប្រុសរបស់លោក<ទេ សំណួររបស់ខ្ញុំ>ថា តើលោកមានការដឹងពិតប្រាកដណាមួយអំពីមូលហេតុនៃការចាប់ខ្លួន<របស់ពួកគេ ឬក៏លោកគ្រាន់តែ> និយាយស្មានៗ<តែប៉ុណ្ណោះ>?

[១៥:០៨:១៦]

**ឆ៖** ពេលដែលខ្ញុំនិយាយប្រាប់លោកគឺខ្ញុំដឹងថា ប្អូនខ្ញុំគេប្រាប់ថា ពីមុនមកឲ្យតែអ្នកណាចេះដឹងជាងពួកអស់គេទាំងហ្នឹង គេនឹងយកទៅ ដូចថាកសាង តែកសាងគឺបាត់ខ្លួន បាត់ខ្លួនជារៀងរហូត។ ដូច្នេះពេលនេះប្អូនខ្ញុំវាចេះដឹងទាំងអស់ វាអួតខ្លួនថាចេះដឹងទាំងអស់ សូម្បីតែអ្នកណាឈឺខ្លួន ឈឺប្រាណក៏វាចេះធ្វើដើម្បីយកចិត្តគេ។ ដល់ចុងក្រោយគឺ បាត់ខ្លួនរហូត ពីព្រោះអីវាអួតអាង ថាខ្លួនវាចេះច្រើន។ ដូច្នេះខ្ញុំដឹងថា កាលណាអួតអាងច្រើនគឺបាត់ខ្លួនរៀងរហូតទាល់ឥឡូវ។

**សៈ** តើលោកពិតជាបានឃើញផ្ទាល់ភ្នែកដែរ ឬអត់នូវអ្វីដែលកើតឡើងចំពោះប្អូនថ្លៃប្រុសទាំងពីរនាក់ ឬក៏គ្រាន់តែ<>គេនាំខ្លួនចេញទៅបាត់នៅថ្ងៃណាមួយនោះ ហើយ<លោក>មិន<>ឃើញ<ពួកគេ>មកវិញ? តើបើខ្ញុំនិយាយអ៊ីចឹងបានទេ?

**ឆ៖** កាលណាគេនាំទៅហើយ មិនដែលឃើញមកវិញ គឺតែងតែស្លាប់ទាំងអស់ហើយ ពីព្រោះអីខ្ញុំមានអ្នកគេអាណិតស្រឡាញ់ខ្ញុំ គេខ្សឹបប្រាប់ អ្នកណាគេមិនបានជួបខ្ញុំក៏គេមិនបានខ្សឹបប្រាប់ទេ។ ពេលណាគេជួបខ្ញុំទៅ គេលួចខ្សឹបប្រាប់ ហើយក៏ការណ៍ហ្នឹងជាការណ៍លាក់ការសម្ងាត់របស់គេ ហើយក៏ជួយរក្សាសុខឲ្យគេដែរ។

[១៥:១០:០៦]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី លោកគួរព្យាយាម<>យល់<អ្វីដែលខ្ញុំនិយាយ។ ខ្ញុំដឹងថាវាពិបាក> តើលោកមានបានឃើញផ្ទាល់ភ្នែក <>លោកទេនូវអ្វីដែលបានកើតឡើងទៅលើប្អូនថ្លៃប្រុសរបស់លោកទាំងពីរនាក់?

**ឆ៖** ប្អូនថ្លៃប្រុសទាំងពីរនាក់ ខ្ញុំឃើញច្បាស់តែមួយទេដែលឡើងបេះដូង តែចំណែកថាស្រែប្រាំងខ្ញុំមិនបានឃើញទេ គ្រាន់តែដឹងថាបាត់ខ្លួនក្នុងពេលនោះ។ នោះខ្ញុំសង្ស័យថា នឹងទៅសម្លាប់ជាមិនខាន ពីព្រោះអីរឿងរាល់មក ឲ្យតែចេញពីការដ្ឋានត្រូវតែបាត់ខ្លួន ឬក៏គេហៅចំពោះមុខថា ទៅដឹកគោៗឡើងមកដឹកគោ គឺបាត់ទាំងអស់។ បានខ្ញុំសន្និដ្ឋានថា មិនខុស។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នៅលើកៅដែលលោកកំពុងតែអង្គុយនេះ--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបន្តសំណួរទៀតទៅ សំណួរគាត់ឆ្លើយសមល្មមអាចស្តាប់យល់ហើយ គឺគាត់បង្ហាញច្បាស់លាស់ថា គាត់ -- មើល១! ខាងបកប្រែភាសា។

*(មានបញ្ហាខាងការបកប្រែ)*

លោកមេធាវីបន្តសំណួរថ្មី បញ្ហាថ្មីទៀតទៅ បញ្ហានេះ អង្គជំនុំជម្រះស្តាប់យល់ហើយ គឺគាត់បញ្ជាក់ច្បាស់លាស់ហើយ គឺគាត់ដឹងពីរឿងការបាត់ខ្លួន ប្អូនថ្លៃរបស់គាត់។ រឿងមូលហេតុហ្នឹង គាត់មិនដឹងទេ គាត់ថា គាត់សន្និដ្ឋាន។ ដូច្នេះច្បាស់លាស់ហើយ ហើយលោកសួរដូចជាចង់១០ដងទៅហើយ។ ចង់អូសពេលវេលា ឬក៏យ៉ាងម៉េច? មានប្រយោជន៍អីក្នុងការអូសពេលវេលានេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំៗមិនមែនអូសពេលវេលាទេ លោកប្រធាន។ ខ្ញុំសូមបន្តទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ចម្លើយដែលលោកបានឆ្លើយមុនពេលឈប់សម្រាកនេះ លោកគឺនិយាយ<ថា មាន>ការ

បែងចែកប្រជាជនទៅតាម<>ជាតិពន្ធរបស់ខ្លួន<។ លោកបានិយាយថា ចិនត្រូវគេចាត់ឲ្យនៅជាមួយពួកចិនម៉ុំទៅ>។ តើលោកអាចពន្យល់ឲ្យបានលម្អិតបន្តិចទេ ថាតើគេបែងចែកប្រជាជនដោយរបៀបណា<? តើ>វាកើតឡើងដោយរបៀបណា?

[១៥:១៣:២៧]

**លោក បេង បឿន៖**

**ឆ៖** ពេលគេបែងចែក មុនដំបូងគេឲ្យយើងជួបជុំនៅក្នុងគ្រួសារ ហើយរយៈក្រោយមកបានគេបែងចែកភូមិចិន និង ខ្មែរ។ អ្នកថ្មីនៅដោយអ្នកថ្មី អ្នកចាស់នៅដោយអ្នកចាស់។ ពួកចិន យួន គេដាក់ជាមួយគ្នា ហើយខ្ញុំគេដាក់ជាមួយនឹងភូមិចិន យួន។

**ស៖** <>លោកអាចនិយាយប្រាប់បានទេថា តើកម្មាភិបាលខ្មែរក្រហម<ចាត់ចែងដូចម្តេចដែរ? តើពួកគេ>មានបានប្រកាសថា ជនជាតិចិនទាំងអស់ត្រូវប្រមូលដាក់ម៉ុំ? តើប្រជាជនគេមានអត្តសញ្ញាណប័ណ្ណបញ្ជាក់ថា គេជាជនជាតិចិន ឬក៏យ៉ាងណានោះទេ? តើលោកពន្យល់ឲ្យបានលម្អិតបន្តិចបានទេ<ថាការបែបចែកប្រជាជននោះធ្វើឡើងដោយរបៀបណាដែរ>?

**ឆ៖** ពេលនោះ គេសម្គាល់ទៅលើអ្នកថ្មី អ្នកថ្មីមកគេដឹងភិនភាគមើលទៅឃើញជារបៀបចិនឲ្យតែសាច់ស គេស្តាប់សម្តីសំដៅនិយាយទៅគេដឹកថាចិន អាចគេដាក់មកភូមិចិនមក ហើយនិងវៀតណាម ដឹងតែនិយាយប៉ែឡាំៗគេមើលសាច់សម្បុរគេដឹងថា វៀតណាម។ ដូចជារូបខ្ញុំអ៊ីចឹងកូនកាត់ចិនគេដាក់ខាងចិនមក។

**ស៖** គឺនេះជាលើកទី១ហើយ ដែលខ្ញុំឮភស្តុតាងបែបនេះ លោកដើមបណ្តឹងរដ្ឋប្បវេណី។ តើ<>កម្មាភិបាល<កំណត់ថា>លោក<ជាប់សែ>ចិន<ដោយរបៀបណា>? <លោកក៏បានរៀបរាប់ថា> តើដោយសារតែ<>លោក<មានសម្បុរសជាដើម។ តើមានអ្វីទៀតដែល>កម្មភិបាលនោះអាចចាត់ទុកលោកថាមាន<ជាប់សែចិន>?

[១៥:១៥:៤០]

**ឆ៖** ពីព្រោះខ្ញុំរូបខ្ញុំ និងគ្រួសារខ្ញុំប្រពន្ធខ្ញុំជាកូនកាត់ចិន គាត់ជាកូនកាត់ចិនកាជីវ គាត់និយាយមិនសូវច្បាស់ប៉ុន្មានទេ បានជាគេដឹងថាខ្ញុំចិន។ ដូច្នេះ គេយកប្រមូលមកដាក់កន្លែងចិន និងយួនទៅ។

**ស៖** ខ្ញុំនៅតែ<មិនយល់>លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនៅតែចង់ដឹងថាតើ<គេដឹងថា>លោក<> ឬក៏ប្រពន្ធរបស់លោក<មានសំនៀង>កាត់ចិន<ដែលក្រោយមកទៀតគេចាត់ឲ្យទៅនៅ

ជាមួយក្រុមចិន ដោយរបៀបណា>? លោកពន្យល់ឲ្យលម្អិតបន្តិចបានទេ?

**ឆ៖** ខ្ញុំអាចជម្រាបលោកបានថា ព្រោះម្ដាយគាត់ជាអ្នកមូលដ្ឋាន ប្រពន្ធម្ដាយ -- ម្ដាយក្មេកខ្ញុំ ហ្នឹងឪពុកក្មេកខ្ញុំជាអ្នកមូលដ្ឋាន គឺគាត់កាត់ចិន គាត់ធ្វើតែគុយទាវដូរទេ ហើយគាត់និយាយមិនសូវច្បាស់ឪពុកនោះ។ ដូច្នេះគេដឹងថាខ្ញុំហ្នឹងកូនចិនទៅហើយ ពីព្រោះខ្សែខ្ញុំដូចលោកចៅក្រមគាត់សួរមកជីតាខ្ញុំ ទ្រី – ទ្រី បេង ឪពុកខ្ញុំ។ អ៊ីចឹងបានគេយកខ្សែតាមហ្នឹង គេដឹងថាអ៊ីចឹង ទ្រី បេង, ទ្រី បឿន ហ្នឹង បេង បឿន ហ្នឹងជាឪពុក។ បានខ្ញុំ គេចាប់ខ្ញុំយកមកដាក់ខាងភូមិចិន និងយួនទៅ។

**ប្រធានអង្គជំនុំ៖**

សូមតាំងសំណួរឲ្យពាក់ព័ន្ធជាមួយនឹងស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្ម វាសួរឆ្ងាយពេកហើយ លោកមេធាវី។ សូមមេធាវីបន្តសំណួរទៅមុខ ហើយសូមសួរឲ្យមានសំណួរពាក់ព័ន្ធ សំណួរនេះដូចស្ដាប់ទៅមិនទំនងមិនពាក់ព័ន្ធអ្វីសោះ ទៅនឹងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១៥:១៨:១៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ លោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរបញ្ជាក់បន្ថែម។ ដំបូងខ្ញុំចង់សួរបញ្ជាក់ថា ខេត្តកំណើតរបស់លោកនៅខេត្តតាកែវ ឬក៏កំពង់ស្ពឺ? លោកអាចបញ្ជាក់បានទេ?

**លោក បេង បឿន៖**

**ឆ៖** ខេត្តកំណើតរបស់ខ្ញុំនៅខេត្តកំពង់ស្ពឺ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំឃើញឯកសារមួយជាទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់លោកដែលមានលេខសម្គាល់ E3/4719 នៅក្នុងចំណុចទី៣បានបញ្ជាក់ថាទីកន្លែងកំណើតរបស់

លោកនៅភូមិព្រៃក្ដី ឃុំស្គុះ ស្រុកសំរោងទង ខេត្តតាកែវ។ អានេះ មានការភ័ន្តច្រឡំយ៉ាងម៉េចដែរ លោកអាចពន្យល់បានទេ?

**ឆ៖** បាទ ស្រុកកំណើតរបស់ខ្ញុំគឺភូមិព្រៃក្ដី ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មិនមែនខេត្តតាកែវទេ។

[១៥:២០:០៦]

**ស៖** បាទ អ៊ីចឹងមានន័យថា ព័ត៌មានអំពីខេត្តកំណើតរបស់លោក នៅក្នុងឯកសារ E3/4719 នេះគឺខុសទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញនេះ ខ្ញុំបានឮលោកឆ្លើយទាក់ទងទៅនឹងឈ្មោះ ណម លោកបញ្ជាក់ថា ជាប្អូនថ្លៃ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ប្អូនថ្លៃខ្ញុំមិនមែនឈ្មោះ ណម ទេ គឺឈ្មោះ វុធ និង ប៊ូ។

**ស៖** បាទ សូមអរគុណ។ ចុះឈ្មោះ ណម នេះលោក ត្រូវជាអ្វីដែរ?

**ឆ៖** ណម ហ្នឹងជាប្រធានឈ្លបភូមិសម្រាប់យកមនុស្ស យកមកប្រើឲ្យជីករណ្ដៅដាំដូង ដាំចេកនៅពេលយប់ ហើយនិងបញ្ឆោតមនុស្សយកទៅរែកដូង រែកមាន់ តែពេលយប់ហ្នឹង ហើយមិនដែលឃើញត្រឡប់មកវិញទេ ឈ្មោះ ណម ហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា លោករៀបការម្ដងទៀតនៅពេលណា ពីព្រោះលោកបានជម្រាបអង្គជំនុំជម្រះថា លោកបានរៀបការពីរដង បាទ?

**ឆ៖** ការរៀបការ គ្រួសារ ខ្ញុំមិនបានចាំច្បាស់ទេ គ្រាន់តែខ្ញុំដឹងថា ឆ្នាំខ្ញុំអាយុ២២។ ហើយក្រោយមកគ្រួសារខ្ញុំខូចទៅ ខ្ញុំរៀបការក្រោយនៅពេលឆ្នាំ៨៤។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា ឈ្មោះ វុធ និងឈ្មោះ ប៊ូ ដែលលោកបានហៅថាជាប្អូនថ្លៃរបស់លោកនេះ ជាប្អូនថ្លៃរបស់ប្រពន្ធមុន ឬក៏ប្រពន្ធក្រោយរបស់លោក?

[១៥:២២:៥៥]

**ឆ៖** បាទ ឈ្មោះ វុធ និង ប៊ូ ពីរនាក់នោះគឺជាប្អូនថ្លៃរបស់ប្រពន្ធមុន។ ប្អូនថ្លៃខ្ញុំហ្នឹងប្រពន្ធមុន។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំអាចហៅថាឈ្មោះ ប៊ូ និងឈ្មោះ វុធ នេះជាអតីតប្អូនថ្លៃរបស់លោកអ៊ីចឹងបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ លោកអាចហៅបាន។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់បន្ថែមថាឈ្មោះ ឫ និង វុធ ហ្នឹងគឺជាអតីតប្អូនថ្លៃប្រុសរបស់លោកទាំងពីរ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ជាប្អូនថ្លៃប្រុសរបស់ខ្ញុំទាំងពីរមែន។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចម្លើយរបស់លោក នៅពេលដែលលោកបញ្ជាក់ថាលោកទៅដល់ភូមិត្រាំកក់ លោកអាចបញ្ជាក់បានទេថា "ត្រាំកក់" នេះសំដៅទៅលើភូមិ ឃុំ ឬក៏ស្រុក?

**ឆ៖** ខ្ញុំទៅត្រាំកក់សំដៅទៅភូមិឈ្មោះ ភូមិថ្នកែវ។

**ស៖** បើអ៊ីចឹងពេលដែលលោកមានប្រសាសន៍ថា ភូមិត្រាំកក់ហ្នឹងគឺមិនមែនភូមិត្រាំកក់ទេ គឺភូមិថ្នកែវ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ភូមិត្រាំកក់ គេនៅជាប់នឹងថ្នល់ តែភូមិថ្នកែវ គឺនៅខាងត្បូងថ្នល់។ ដូច្នេះ ខ្ញុំចេញពីភូមិត្រាំកក់ទៅ ទៅនៅខាង -- ចេញពី ធ្វើដំណើរដែលបំបែកហ្នឹងមក ក៏ឆ្លងភូមិត្រាំកក់ហ្នឹងទេ ទៅដល់ថ្នកែវ។

**ស៖** បាទ ខ្ញុំសូមបញ្ជាក់បន្ថែម ភូមិថ្នកែវហ្នឹងឬ ដែលជាកន្លែងដែលលោកមានប្រសាសន៍ថាមានការបំបែកជនជាតិចិន និងយួន ពីខ្មែរ?

**ឆ៖** បាទ ភូមិថ្នកែវហ្នឹងហើយ ដែលកន្លែងគេបំបែកយួន និងខ្មែរ។

[១៥:២៥:៥៤]

**ស៖** តាមការបញ្ជាក់របស់លោកមុនអំមិញ នៅពេលដែលលោកមេធាវី កូប៉េ សួរបញ្ជាក់ទៅលើជនជាតិចិន គឺសំដៅទៅលើខ្មែរដែលមានសន្តាន ឬក៏ដូនតាខ្សែស្រឡាយជាចិន តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ រឿងហ្នឹង វាអ៊ីចឹងមែនហើយ ឲ្យតែមានជាប់ខ្សែស្រឡាយជាចិន គឺដាក់ខាងភូមិចិន និងភូមិយួន ដូច្នេះមែន។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងចិន ហើយដែលលោកនិយាយថា ភូមិចិន ភូមិយួន ទាំងអស់ហ្នឹង គឺនៅចម្រុះគ្នា ពីភូមិខ្មែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គេបែងចែកឲ្យនៅដាច់ពីគ្នា ពីភូមិខ្មែរ ព្រោះចិនហើយយួនហ្នឹងគេសុទ្ធតែអ្នកថ្មីទាំងអស់។ អ៊ីចឹងហើយគេឲ្យនៅដាច់ពីគ្នា។

**ស៖** បាទ សូមអរគុណ។ ចុះសម្រាប់ខ្មែរជាអ្នកថ្មី តើនៅខាងណា នៅខាងភូមិខ្មែរ ឬមួយនៅ

ខាងភូមិចិន យួន ដែលលោកហៅថា អ្នកថ្មីចិនយួននោះ?

[១៥:២៧:៤៤]

**ប្រធានអង្គជំនុំ៖**

សំណួរហ្នឹង ពាក់ព័ន្ធជាមួយនឹងអង្គហេតុនៃការព្យសនកម្ម និងទុក្ខសោកវេទនាយ៉ាងម៉េចទៅ លោកមេធាវីអាចពន្យល់បានទេ?

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ដោយសារដើមបណ្ដឹងរដ្ឋប្បវេណី គាត់មានទំនាក់ទំនងផ្ទាល់ថាគាត់រស់នៅក្នុងភូមិចិន និងយួន ហើយប្រហែលជាមានទំនាក់ទំនងទាក់ទងនឹងការដែលការប្រព្រឹត្តផ្សេងពីគ្នា ខុសពីគ្នាពីអ្នកចាស់ ហើយនិងអ្នកថ្មី។ ដូច្នេះ ខ្ញុំចង់សួរបញ្ជាក់ទៅលើការបែងចែកនេះ ថាតើវាមានបញ្ហាការប្រព្រឹត្តខុសគ្នាដែរឬទេបាទ?

**ប្រធានអង្គជំនុំ៖**

គួរតែផ្ដោតសំណួរទៅ ពាក់ព័ន្ធជាមួយនឹងទុក្ខសោកវេទនា និងព្យសនកម្ម ដែលគាត់ ជាមូលហេតុដែលគាត់ប្ដឹងទាមទារ -- ប្ដឹងសូមចូលខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលយើងហៅគាត់មកស្ដាប់នេះ។

លោក កូប៉េ រួចហើយ អង្គុយចុះ មិនអនុញ្ញាតឲ្យទៀតទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន ខ្ញុំគិតថាប្រហែលជា-->

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អត់អាចអនុញ្ញាតទេ!

[១៥:២៩:២០]

**លោក គង់ សំអុន៖**

លោកប្រធានអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយនឹងសំណួរទេ អម្បាញ់មិញ?

**ប្រធានអង្គជំនុំ៖**

អត់អនុញ្ញាតទេ។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយនឹងសំណួរនេះទេ។

**លោក គង់ សំអុន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ សូមអរគុណ។ អស់សំណួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណលោក បេង បឿន ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកអះអាងថា លោកបានទទួលរងនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ។ ហើយលោកអាចវិលត្រឡប់ទៅកាន់ទីលំនៅដ្ឋាន ឬក៏គោលណាដែលលោកមានបំណងចង់ទៅវិញបានហើយ។ សូមលោកធ្វើដំណើរវិលត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយបុគ្គលិកអង្គការ ធី.ភី.អូ អង្គុយទីកន្លែងនោះដដែលចុះ រង់ចាំអង្គជំនុំជម្រះធ្វើការ -- សវនាការស្តាប់សេចក្តីថ្លែងការរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-883 បន្ត។ អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[១៥:៣០:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការកត់សម្គាល់មួយពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់លោកប្រធានដែលមិនអនុញ្ញាតឱ្យខ្ញុំសួរទៅដើមបណ្តឹងរដ្ឋប្បវេណី<រូបនេះ>។ យើងពិនិត្យមើលទៅលើសាលក្រមក្នុងសំណុំរឿង ០០២/០១ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបាន<យោង>បួនដង <ជា>ភស្តុតាងនៅក្នុងសាលក្រម។ ទី១ គឺការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់<។ ដូច្នេះ>មិនមែនដោយសារយើងសួរដើម្បីអូសបន្លាយពេលវេលានោះទេ <យើងខ្ញុំធ្វើរបៀបនេះព្រោះតែគ្មានអ្វីប្រសើរជាងនេះទេ>។ <ចម្លើយ>ដើមបណ្តឹងរដ្ឋប្បវេណី<រូបនេះត្រូវបានប្រើប្រាស់ជាដូចចម្លើយរបស់សាក្សី>--

**ប្រធានអង្គជំនុំ៖**

មានការប្តូរមែនទេ? បាទ សូមអញ្ជើញចាកចេញចុះ! បាទៗ។

អញ្ជើញ! លោកនិយាយយ៉ាងម៉េចទៅនេះ? ទិតៀនយើង ឬក៏យ៉ាងម៉េចលោក វ៉ិចទ័រ កូប៉េ យើងហាមមិនឱ្យលោកសួរដើមបណ្តឹងរដ្ឋប្បវេណីណាមួយ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ នេះគឺអ្វីដែលខ្ញុំកំពុងតែរិះគន់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

កាត់ថាម៉េចឥឡូវហ្នឹង? យើងមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ។ ដាច់ខាតយើងមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ។ យើងមិនបានរំលោភសិទ្ធិក្នុងការ -- លោកក្នុងការស្តាប់សួរនាំដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីណាមួយឡើយ។ ពេលវេលាលោកយើងបានបែងចែករួចរាល់អស់ហើយ មិនមែនមកលើកលោកធ្វើអ្វីទៅតាមទំនើងចិត្តនោះទេ។

[១៥:៣២:៥៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** ខ្ញុំឈ្មោះ យ៉ែម ខុន្នី។

**ស៖** លោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំអត់ចងចាំផង។ ខ្ញុំអត់អក្សរ។

**ស៖** លោកស្រីអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកស្រីរង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាក្រហមសិន ជាឱកាសមួយល្អ ពេលលោកស្រីស្តាប់សំណួរ លោកស្រីយកសំណួរទៅគិតបន្តិចសិន ដើម្បីឲ្យច្បាស់លាស់ថាសំណួរហ្នឹងលោកស្រីឆ្លើយយ៉ាងម៉េច ស្របពេលដែលលោកស្រីគិតឃើញហើយ លោកស្រីនឹងអាចឃើញនូវក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមនេះ សឹមលោកស្រីឆ្លើយ។ លោកស្រីអាយុប៉ុន្មាន?

[១៥:៣៤:០២]

**ឆ៖** ៣៨ឆ្នាំ។

**ស៖** តើលោកស្រីរស់នៅសព្វថ្ងៃ រស់នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃខ្ញុំស្រុកកំណើតកើតជានៅឯកម្ពុជាក្រោម។

**ស៖** លោកស្រីប្រកបមុខរបរធ្វើអី? សូមអញ្ជើញឆ្លើយ!

**ឆ៖** ខ្ញុំធ្វើស្រែ។

**ស៖** ឪពុករបស់លោកស្រីឈ្មោះអី?

**ឆ៖** ឈ្មោះ យ៉ាន់។

**ស៖** ចុះម្ដាយរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឈ្មោះៗ រិត។

**ស៖** លោកស្រីមានគ្រួសារទេ ហើយគាត់ឈ្មោះអី?

**ឆ៖** គ្រួសារមានឈ្មោះ សេត ឥឡូវបាត់បង់ជីវិតទៅហើយ។

**ស៖** លោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** កូនប្រាំមួយនាក់។

[១៥:៣៥:៣៩]

**ប្រធានអង្គជំនុំ៖**

នៅក្នុងសវនាការនេះ អង្គ -- ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកស្រីដើម្បីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រី ដូចជាការខូចខាតផ្នែកខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់អំពីបទឧក្រិដ្ឋ និងបានកើតឡើងមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះដែលនាំឲ្យលោកស្រីប្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ ដែលពាក់ព័ន្ធជាមួយនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ផ្ទាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ហើយតាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្ដល់ជូនវេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សាកសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះអំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលកើតមានចំពោះគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមអញ្ជើញ!

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរលោកស្រី យ៉ែម ខុន្នី។

[១៥:៣៧:០៦]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** មុននឹងខ្ញុំដាក់សំណួរទៅលោកស្រី ខ្ញុំចង់សួរបញ្ជាក់លោកស្រីបន្តិចទាក់ទងនឹងអាយុៗរបស់លោកស្រី។ បើតាមលោកប្រធានបានសួរលោកស្រីពីខាងលើ ថាលោកស្រីមានអាយុ៣៨ឆ្នាំ។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថាតើ លោកស្រីកើតនៅក្នុងឆ្នាំណា?

**លោកស្រី យ៉ែម ខុន្នី៖**

**ឆ៖** ខ្ញុំអត់ចងចាំផង ខ្ញុំអត់ចេះអក្សរ។

**ស៖** បាទ អ៊ីចឹងតើលោកស្រីចាំបានទេនៅពេលដែលនៅក្នុងរបបខ្មែរក្រហម គេហៅថាកម្ពុជាប្រជាធិបតេយ្យនោះ តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ១៤ឆ្នាំ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងសំណួរបន្ត ខ្ញុំចង់សួរលោកស្រីថានៅក្នុងឆ្នាំ -- នៅក្នុងថ្ងៃនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាថ្ងៃរំដោះ តើលោកស្រីនៅកន្លែងណា?

**ឆ៖** ខ្ញុំនៅព្រៃខាប។

**ស៖** នៅព្រៃខាបហ្នឹងនៅក្នុងខេត្តអីដែរលោកស្រី?

**ឆ៖** ខ្ញុំអត់ស្គាល់ផងខេត្ត ស្គាល់គេហៅថាព្រៃខាបអ៊ីចឹង ហៅនឹងគេទៅ។

**ស៖** បាទ មូលហេតុអីបានជាលោកស្រីទៅដល់ព្រៃខាបហ្នឹង?

[១៥:៣៩:០៨]

**ឆ៖** ខ្ញុំឡើងមកពីក្រោមមក គេបញ្ជូនមកហ្នឹង។

**ស៖** លោកស្រីដឹងទេថា មូលហេតុអីបានជាលោកស្រីត្រូវបានគេបញ្ជូនមកពីក្រោម? ពីក្រោមហ្នឹងលោកស្រីមានន័យថា មកពីខ្មែរកម្ពុជាក្រោម ឬៗក៏មានន័យយ៉ាងម៉េច?

**ឆ៖** មកពីកម្ពុជាក្រោម ខ្មែរកម្ពុជាក្រោមគេបញ្ជូនមក។

**ស៖** តើលោកស្រីមានដឹងថាមូលហេតុអី បានជាគេបញ្ជូនលោកស្រីមកពីខ្មែរកម្ពុជាក្រោមមកដល់ភូមិខាបហ្នឹង?

**ឆ៖** ម្ដាយខ្ញុំបបួលខ្ញុំថា៖ “តោះ! កូនចៅទៅស្រុកលើ អីនុំងសម្បូរហូបណាស់” គេនិយាយ។ ដល់ហើយ ម៉ែខ្ញុំហ្នឹងក៏បបួលខ្ញុំមក ពួកខ្ញុំហ្នឹងក៏មកតាមគាត់មក អ៊ីចឹងរហូតមកតាមផ្លូវភ្នំដិនអ៊ីចឹង។

ដល់ហើយមកជាប់នៅភ្នំដិនហ្នឹង គេដាក់ឡានឡើងមកអ៊ីចឹងរហូតមក គេបញ្ជូនមកនៅព្រៃខាបហ្នឹងម្ដង។

**ស៖** តើលោកស្រីអាចជម្រាបបានទេថា នៅពេលដែលលោកស្រីនៅព្រៃខាបហ្នឹង តើលោកស្រីត្រូវបានគេឲ្យធ្វើការងារអីខ្លះនៅក្នុងព្រៃខាបហ្នឹង?

**ឆ៖** គេឲ្យ មុនដំបូងគេឲ្យរើសអាចម៍គោ រែកអាចម៍គោអ៊ីចឹងអស់ពីចិត្ត គេឲ្យទៅកាប់ទន្រ្ទានខែត្រអ៊ីចឹងទៅ។ ដល់ហើយកាប់ទន្រ្ទានខេត្តចិញ្ច្រាំហើយអីហើយ ឲ្យរែកដាក់ទៅស្រែៗ ហើយអីហើយសព្វគ្រប់ ស្រែនោះវាមានដំបូកៗ ហើយគេឲ្យទៅកាប់ដំបូកហ្នឹងទៀត។ កាប់គ្នាហ្នឹង១០នាក់ រែកហ្នឹងដាក់ គេមិនឲ្យដាក់លាយគ្នាទៀត គេឲ្យដាក់តាមជួរ។ ឲ្យមើលៗ ម្នាក់បានប៉ុន្មានអម្រែកៗ។ ហើយពួកខ្ញុំហ្នឹងក៏ពឹតខំ ឲ្យកាប់ឲ្យហើយ គេថាដាក់កំណត់៣ថ្ងៃឲ្យហើយ។ ដល់ហើយពួកខ្ញុំខំទៅ ចេះតែខំ ដល់ពេលរែកហើយអីហើយ ម៉ោងពីរ ពីរដណ្ដប់ គេគោះជួងទៅ គេឲ្យសម្រាកទៅហូបបាយ។

[១៥:៤១:៣២]

**ស៖** បាទ ទាក់ទងទៅនឹងការរស់នៅ តើការរស់នៅរបស់លោកស្រីនៅក្នុងព្រៃខាបហ្នឹង តើមានអាហារ ក៏ដូចជាជីវភាពយ៉ាងម៉េចដែរលោកស្រី?

**ឆ៖** អាហារនោះ គេបបរ មុនដំបូងគេបបរសឲ្យហូប។ ដល់ស្អែកឡើងបបរដំឡូង។ បបរដំឡូងដល់ថ្ងៃទី៣ទៀត គេបបរពោត។ បបរពោតហើយគេស្ងួព្រលិតឲ្យហូបអ៊ីចឹងទៅ។ ព្រលឹតហ្នឹងស្ងួទៅ ក្នុងមួយខ្ទះហ្នឹងទឹក ចំណិតពីរបី ដួសយកមកចែកគ្នានៅលើតុហ្នឹងអង្គុយជួរអ៊ីចឹងឲ្យហូបទៅ។

**ស៖** តើម្ហូបដែលលោកស្រីបានហូបនោះ តើវាជាការគ្រប់គ្រាន់សម្រាប់លោកស្រីនៅក្នុងពេលនោះដែរឬទេ?

**ឆ៖** បើឆ្លើយថា មិនគ្រប់គ្រាន់ក៏គេធ្វើបាបដែរ ដល់តែឆ្លើយថា គ្រប់គ្រាន់។ ចុះឆ្ងាញ់ទេ? ថាឆ្ងាញ់។ ប៉ុន្តែតាមពិតទៅ អត់ឆ្ងាញ់ទេ ប៉ុនឆ្លើយអ៊ីចឹងទៅថា ឲ្យវារស់មួយជីវិតៗទៅ។

[១៥:៤២:៥៤]

**ស៖** នៅពេលដែល នៅក្នុងពេលនោះ នៅពេលដែលលោកស្រីស្ថិតនៅក្នុងអាយុ១៤ឆ្នាំ តើលោកស្រីរស់នៅជាមួយក្រុមគ្រួសាររបស់លោកស្រី ឬក៏លោកស្រីរស់នៅបែកពីក្រុមគ្រួសារ?

**ឆ៖** មុនដំបូងនៅជាមួយគ្រួសារ មួយពោះមួយ មួយយាយអ៊ីចឹងទៅ។ ដល់ខ្ញុំនេះទៅ គេបំបែកតាមកង ៗទៅនៅតាមកងទៅ។ ហើយឪពុកម្ដាយខ្ញុំហ្នឹង នៅតាមប្អូនខ្ញុំហ្នឹងទៅ ហើយខ្ញុំទៅធ្វើការទៅ

បងខ្ញុំទៅធ្វើការដែរទៅ។

**ស៖** បាទ ទាក់ទងទៅនឹងទំនាក់ទំនងរវាងលោកស្រី ជាមួយនឹងក្រុមគ្រួសារ តើការទំនាក់ទំនងរបស់លោកស្រីជាមួយក្រុមគ្រួសារមានលក្ខណៈយ៉ាងដូចម្ដេចដែរ?

**ឆ៖** ដល់ខ្ញុំបែកពីគាត់អ៊ីចឹងទៅសុំគេមកលេង។ សុំមកលេងអ៊ីចឹងគេថា មិនទាន់ធ្វើការឲ្យគេហើយផងទៅសុំទៅលេង ទើបមក។ ហើយខ្ញុំពួកថ្មី ខ្ញុំមិនដឹងអី ចេះតែសុំគេមកនឹកម៉ែឪ ចេះនឹកប្អូន នឹកយាយ យាយគាត់ចាស់ចេះតែសុំៗ ដល់សុំគេថា “ឥឡូវចង់សុំទៅអី?” ដល់ខ្ញុំថា “ខ្ញុំសុំទៅមួយកំណាត់ថ្ងៃទៅ”។ គេថា “បើសុំមួយកំណាត់ថ្ងៃ នោះបង្គីនៅមួយសម្រាប់ យកទៅកាប់ដីដំបូកទៅ”។ គេថាអ៊ីចឹងឲ្យខ្ញុំ។

**ស៖** នៅពេលដែលលោកសុំគេទៅលេងក្រុមគ្រួសារ តើគេអនុញ្ញាតឲ្យលោកស្រីទៅបានទៅជួបក្រុមគ្រួសារទេ នៅពេលនោះ?

**ឆ៖** អត់បាន បើគេមិនឲ្យទៅផង មិនបានជួប ហើយដល់ហើយខ្ញុំនឹកឃើញយំ ចុះទើបមកហើយ បែកម្ដាយ បែកប្អូន បែកបង បែកយាយ។ ដល់ហើយខ្ញុំយំអ៊ីចឹង គេថា “បើយំបានទៅ ចេះតែយំទៅ” គេថាឲ្យខ្ញុំអ៊ីចឹង។

[១៥:៤៥:១៦]

**ស៖** បាទ អ៊ីចឹងនៅពេលនោះ តើលោកស្រីរហូតដល់ថ្ងៃរំដោះនោះ តើលោកបានជួបក្រុមគ្រួសារលោកស្រីទេ?

**ឆ៖** ដល់ថ្ងៃនុ៎ងអត់បានទេ។ ដល់ហើយខ្ញុំសុំគេរកមើលៗ ជួបអ៊ុំខ្ញុំ ថា “អ៊ុំ! ឪពុកម្ដាយខ្ញុំនៅឯណា?” គាត់ថា “ទៅមើលនៅភូមិទៅ”។ ដល់ហើយខ្ញុំមកមើលភូមិអ៊ីចឹង អត់ឃើញៗអ៊ីចឹង គេបញ្ជូនមកស្រែរនោងៗអ៊ីចឹង ក៏ខ្ញុំមកដើរតាមមកតាមម្ដាយខ្ញុំហ្នឹង ហើយនិងពោះមួយខ្ញុំ មកតាមស្រែរនោងហ្នឹង រហូតដល់ខ្ញុំរកឃើញ។

**ស៖** បាទ នៅពេលលោកស្រីរកគាត់ឃើញ តើនៅពេលនោះលោកស្រីបានជួបគាត់ ហើយនិងបាននៅជាមួយគាត់ដែរឬទេ នៅពេលនោះ?

**ឆ៖** បាននៅប្រហែល១អាទិត្យ ដល់ហើយគេបំបែកកង។ បំបែកកងទៅទៀត ខ្ញុំហ្នឹងទៅពីខាងកើតស្រែរនោងហ្នឹង គេធ្វើសហករណ៍ឲ្យនៅហ្នឹង រោងសហករណ៍ ធ្វើរោងឲ្យដេក រោងវែងអ៊ីចឹងគេដាក់រានពីរជួរ ឲ្យកុមារាដេកមួយជួរ ឲ្យកុមារីដេកមួយជួរ។ ដល់អ៊ីចឹង ពេលរលឹកពីដេក គេគោះជួង

01086675



ហើយ បបួលគ្នាយកបង្គីម្នាក់មួយសម្រាប់ៗហ្នឹង ចាប់ដើររើសអាចម៍គោរើសអីទៀតហើយ។ ដល់ហើយគេឲ្យចាក់ឲ្យត្រង់ជួរៗ ចាំមើលអ្នកណាបានប៉ុន្មានៗ។ បបួលគ្នាចេះតែប្រឹងហើយ ចេះតែដើរប៉ុន្តែ១០នាក់ហ្នឹងរើសបានហ្នឹង មិនឲ្យយកទៅចាក់ទេម្នាក់ហ្នឹង គេឲ្យចាំមូលគ្នា យកទៅចាក់តាមជួរ។

[១៥:៤៧:២១]

**ស៖** តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេហៅថា របបខ្មែរក្រហមហ្នឹង តើលោកស្រីមានបានបាត់បង់ក្រុមគ្រួសារ ឬក៏សាច់ញាតិរបស់លោកស្រីនៅពេលនោះដែរឬទេ?

**ឆ៖** បាត់បង់គ្រួសារ ម្ដាយខ្ញុំ យាយខ្ញុំ ប្អូនខ្ញុំហ្នឹង ទាំងអស់គ្នាប្រាំមួយនាក់ គេហៅប្រជុំ។ គេមុនដំបូង គេទៅសួរខ្ញុំដល់កន្លែងសហករណ៍ហ្នឹង កន្លែងកុមារហ្នឹង កងកុមារហ្នឹង គេថា “អានី! អានីឯងចង់ទៅស្រុកទេ?” ខ្ញុំថា “អ្ហែ! ខ្ញុំមិនទៅទេ។ នៅនឹងក៏ដូចទៅស្រុក ស្រុកក៏ដូចនៅហ្នឹង។” ខ្ញុំនឹកឃើញថាអ៊ីចឹង ដល់ហើយខ្ញុំចាប់អារម្មណ៍មួយ ចាប់អារម្មណ៍ថា តិចម្ដាយខ្ញុំហ្នឹងឆ្លើយថា ទៅស្រុកទៅ។ ក៏ខ្ញុំហ្នឹងសុំគេមកៗថា “មិត្តងៀច អ្ហែ! ខ្ញុំសុំទៅមើលម្ដាយបន្តិចមើល” កុហកវាថា ម្ដាយឈឺ។ គេថា “ចុះបើម្ដាយឈឺ មើលគាត់ជាទេ។ បើថាមើលជា ទៅមើលទៅ”។ ដល់អ៊ីចឹងក៏ខ្ញុំលួចមក។ លួចមកអ៊ីចឹងឃើញម្ដាយខ្ញុំ ពួកគេនៅកំពុងតែប្រជុំ គេថា ដល់ហ្នឹងអ៊ីហ្នឹងគាត់ឃ្វាលគោ ព្រោះគាត់មូលដ្ឋានចាស់ គាត់ថា “គេកំពុងតែប្រជុំ កុមារីឯងទៅណា?” ខ្ញុំថា “ខ្ញុំទៅលេងផ្ទះម្ដាយខ្ញុំ”។ គេថា “កុំចូល! តិចមានគ្រោះថ្នាក់”។ ខ្ញុំថា “គ្រោះថ្នាក់អីទៅ?” គាត់ថា “កុំទៅ ដើរម្នាក់ឯងតិចគេថាគិញ។ “អី! គិញស្អីទៅបើខ្ញុំមិនស្គាល់គិញ មិនស្គាល់អី” ក៏គេថា “ត្រឡប់កន្លែងកុមារឯងនៅត្រង់ណា ទៅត្រង់ហ្នឹងវិញទៅ”។ ក៏ខ្ញុំដើរទៅ ខ្ញុំដើរទៅវិញទៅ។ ទៅចាប់បង្គីហ្នឹង រែកជាមួយគេជាមួយឯងអ៊ីចឹងទៀត ចេះតែភ័យ កោតក្រែង ភិតភ័យ ចេះតែខ្លាចតែគេធ្វើបាប ចេះតែខំធ្វើហើយ។

[១៥:៤៩:២៦]

ដល់ធ្វើអ៊ីចឹងៗ ដល់តែពេលបាយ គេគោះជួងទៀតហើយ គោះជួងអ៊ីចឹងមកហូប។ ខ្ញុំនឹកឃើញថា បែបបានបបរស ឬមួយបបរអីហូបទៀតហើយ។ ទៅមកៗៗ បបរព្រលឹតដដែល។ ហើយលែងតែមានប្រែមានអីទៅ អត់ប្រែ ខ្ញុំតូចចិត្ត។ ស្រាប់តែអត់ប្រែអត់អី ហូបបបរព្រលឹត ស្រាប់តែគេដើរសួរទៀតហើយ “ឆ្ងាញ់ទេ?” មូលគ្នាឆ្លើយថា ឆ្ងាញ់ បើមិនឆ្ងាញ់មិនកើត។ ដល់អ៊ីចឹងខ្ញុំក៏ហូបហើយអីហើយ ខ្ញុំលួចៗទៅផ្ទះម្ដាយខ្ញុំ។ ទៅអ៊ីចឹងអ៊ីខ្ញុំឈ្មោះៗ អ៊ីលឹម គាត់ថា “អ្វែងមកធ្វើអី ការងារមិនខំធ្វើម្ដាយអ្វែងគេប្រមូលទៅស្រុកហើយ គេទៅប្រជុំហ្នឹងគេឲ្យលើកអ្នកណាចង់ទៅស្រុក លើកដៃឡើងលើ”

។ ដល់ហើយម្ដាយខ្ញុំហ្នឹងគាត់ពួកថ្មី គាត់អត់ដឹង គាត់លើកឡើងលើទៅ ដល់ហើយអ្នកលើកឡើងហ្នឹង គេឲ្យឈរមួយជួរៗ។ ដល់អ៊ីខ្ញុំហ្នឹង ខ្ញុំសួរថា "ចុះអ៊ីឯងមិនទៅតាមម៉ែខ្ញុំទេ?" គាត់ថា "អញមិនទៅតាមទេ នៅហ្នឹងក៏ស្រុកហ្នឹងក៏ដូចស្រុកនេះដែរ"។ ដល់ហើយគេដាក់ឡានទៅមិនយកទៅឯណា បាត់បង់ជីវិតអស់រលីង គ្មានសល់ ពោះមួយ *(ឮមិនច្បាស់)* នៅសល់តែងតែខ្ញុំម្នាក់រាល់ថ្ងៃ។ ទោះបីឈឺថ្កាត់ក៏មិនដឹងមានឪពុកម្ដាយ មានបងប្អូនអីឯណាមករក្សា នៅដេកលើរានទៅកន្លែងសហករណ៍ហ្នឹង។ គេឆ្លើយថាខ្ញុំហ្នឹងឈឺពុត ដល់ហើយខ្ញុំមិនឈឺពុតទេ ប៉ុន្តែខ្ញុំចាប់អារម្មណ៍ នឹកសោកស្ដាយបងប្អូនខ្ញុំពោះមួយខ្ញុំ ម៉ែខ្ញុំ យាយខ្ញុំ។ ដល់ហើយសព្វថ្ងៃនេះឥឡូវនៅតែម្នាក់ឯង ពោះមួយបាត់បង់ជីវិតអស់ ហើយអ៊ីចឹងអ៊ីខ្ញុំហ្នឹងក៏គាត់ស្ដី គាត់ហាមប្រាប់ថា "ក្មួយឯងទៅធ្វើការទៅ បើពុកម្ដាយទៅស្រុកហើយ ពោះមួយទៅស្រុកហើយ ចេះតែធ្វើ គេឲ្យធ្វើអីចេះតែធ្វើទៅ ហើយកុំស្រែកនិយាយ បើពេលដេកចេះតែដេកទៅ ពេលហូបចេះតែហូបទៅ។ កុំនៅតវ៉ា ពេលចេញធ្វើការចេះតែធ្វើទៅ"។ ក៏ខ្ញុំយកចិត្តទុកដាក់តាមអ៊ីខ្ញុំហ្នឹង បានខ្ញុំរស់បាននៅសព្វថ្ងៃហ្នឹង។

[១៥:៥២:២៥]

**ស៖** បាទ ខ្ញុំសូមសួរសំណួរបន្តទៀត។ លោកស្រីអាចជម្រាបបានទេ ទាក់ទងទៅនឹងក្រុមគ្រួសារដូចជា លោកស្រីបានលើកឡើងពីម្ដាយ ក៏ដូចជាបងប្អូនប្រុសស្រីហ្នឹង តើលោកស្រីអាចប្រាប់ឈ្មោះពួកគាត់បានទេ ថាគាត់ឈ្មោះអីលោកស្រី?

**ឆ៖** ឪខ្ញុំឈ្មោះ យ៉ាន់ ម៉ែខ្ញុំឈ្មោះ រិត។ បងស្រីខ្ញុំ យាយខ្ញុំឈ្មោះ យស, បងស្រីខ្ញុំឈ្មោះ ហ៊ុន, ប្អូនខ្ញុំឈ្មោះ រុន, ប្អូនមួយទៀតឈ្មោះ សួន, ប្អូនមួយទៀតឈ្មោះ ស៊ូ ដល់ហើយឈ្មោះ យិត។ យកទៅបាត់អស់រលីង គ្មានសល់ ខ្ញុំហ្នឹងក៏នៅម្នាក់ឯង ខ្ញុំចាប់អារម្មណ៍គេទៅសួរខ្ញុំដល់កន្លែងធ្វើការ នៅកន្លែងកងហ្នឹង។ ចាប់អារម្មណ៍គេថា "មិត្តនី ចង់ទៅស្រុកអត់ទេ?" ខ្ញុំហ្នឹងក៏មានចាប់អារម្មណ៍ដូចជាបុណ្យជួយ ថា "ខ្ញុំមិនទៅទេៗ នៅកន្លែងណាដូចកន្លែងណា"។ ខ្ញុំថាអ៊ីចឹង។

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកស្រី។ ខ្ញុំអស់សំណួរសួរលោកស្រីហើយ ប៉ុន្តែបើសិនខ្ញុំចង់ជម្រាបប្រាប់លោកស្រីថា បើសិនថាលោកស្រីមានសំណូមពរ ឬក៏មានអីៗអាចលោកស្រីសួរសូមសំណូមពរទៅប្រធានក្រុមប្រឹក្សា ឬដូចជាក្រុមប្រឹក្សាចំពោះការដែលលោកស្រីមានសំណូមពរទាក់ទងទៅនឹងបញ្ហារបស់លោក។ បាទលោកប្រធានខ្ញុំអស់សំណួរហើយលោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៥៤:៤៤]

**លោកស្រី យ៉ែម ខុន្នី៖**

ដល់ហើយខ្ញុំនឹកឃើញ មិននឹកឃើញអីទេ ខ្ញុំនឹកតែឈឺចិត្ត ដល់និយាយទៅនឹកឃើញនៅតែនឹងមុខ នឹកឃើញសោកស្តាយពោះមួយ បងប្អូន។ នៅ បើនៅជិតគ្នារក្សា មើលឃើញនូវមុខមាត់ ដល់ពោះមួយខ្ញុំទៅបាត់បង់អស់ទៅ គ្មានអ្នកណាទីពឹង ទោះបីឈឺថ្កាត់ ដល់ហើយខ្ញុំហ្នឹងមកលេងផ្ទះអ៊ុំខ្ញុំហ្នឹង។ ខ្ញុំហ្នឹងក៏ដែរពឹសដែរ ចុះហូបមិនឆ្អែត ខ្ញុំហ្នឹងក៏ទៅចូលបេះគ្រប់ ក៏ប៉ុន្តែមិនហ៊ានបេះធំទេ បេះប៉ុនមេជើងស្រាប់អត់ថាស្ងាត់ ស្រាប់អត់ស្ងាត់ឃើញពូនុំងចេញពីព្រៃមកស្រាប់តែវ៉ៃខ្ញុំៗខ្ញុំបាក់នេះ ស្នាមនេះ មិនទាន់បាត់ទេ។ ដល់ហើយខ្ញុំថា ពូអើយកុំធ្វើអំពើចិត្តអាក្រក់ពេក កូនពូឯងក៏តែហូបមិនឆ្អែតក៏ដូចតែគ្នាហ្នឹង។ ដល់ហើយគាត់ឈរៗគាំងធ្វើអ៊ីចឹង ដល់ហើយគាត់ថា ចុះអីឥឡូវទៅអីណា? ខ្ញុំថា ខ្ញុំទៅលេងផ្ទះអ៊ុំខ្ញុំ។ ដល់ហើយគាត់ថា គ្រប់ហ្នឹងបោះចោលទៅៗក្នុងព្រៃទៅ ហើយដើរទៅ ក៏គាត់មានចិត្តថា ឱ្យខ្ញុំអ៊ីចឹងទៅ ក៏ខ្ញុំបោះចោលទៅ ក៏ខ្ញុំទៅៗជួបអ៊ុំ ក៏អ៊ុំគាត់ថា "តាំងមកទៀតហើយអ្វែង មិនទាន់នេះផងអ្វែងប្រយ័ត្នគេហៅសួរថា ចង់ទៅស្រុកហ្នឹង អ្វែងចង់ទៅទៀតហើយ"។ ដល់ហើយខ្ញុំថា "គេសួរខ្ញុំហើយៗឥឡូវខ្ញុំនឹកអ៊ុំឯងពេក បានតែខ្ញុំមកលេង បើបាត់ម៉ែ បាត់បងប្អូនហើយ នៅសល់តែអ៊ុំឯងមិនឱ្យខ្ញុំមកលេង" ខ្ញុំថាអ៊ីចឹង។

[១៥:៥៦:៣៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកស្រីមានសំណួរចង់សួរ ឬក៏មានការឈឺចាប់អ្វីទៀតទេ?

**លោកស្រី យ៉ែម ខុន្នី៖**

ខ្ញុំឈឺចាប់ តែបាត់ខាងឪពុកម្តាយហ្នឹង ហើយនិងពោះមួយ ឱ្យខ្ញុំនៅកំសត់ម្នាក់ឯង មើលទៅគេគេមានពោះមួយ ដល់មកខ្ញុំគ្មានពោះមួយ។ មើលទៅកំសត់ខំប្រឹងធ្វើការអត់ឃ្លានអីចេះតែទ្រាំៗរហូតដល់តែបែកៗអាពត ហ្នឹងបានខ្ញុំមករកអ៊ុំខ្ញុំហ្នឹង ដល់ហើយអ៊ុំខ្ញុំហ្នឹងចេះតែនាំដើរចុះទៅរហូតដល់ស្រុកៗហ្នឹង។ ទៅដល់អ៊ុំ ចេះតែដើរដេកៗអ៊ីចឹងទម្រាំទៅដល់ព្រំប្រទល់ហ្នឹង ដល់ហើយអ៊ុំខ្ញុំថា "ក្មួយហើយនៅត្រឹមហ្នឹងចុះ នៅជាមួយអ៊ុំ"។ នៅឃុំសោម ស្រុកគីរីវង់ហ្នឹង ភូមិព្រាល ខ្ញុំនៅសព្វថ្ងៃហ្នឹងនៅជាមួយអ៊ុំ។ ដល់នៅជាមួយអ៊ុំអ៊ីចឹង ខ្លួនឯងគ្មានឪពុកម្តាយ កោតក្រែងគេ ទៅច្រូតស្បូវហើយក្រងលក់យកមកឱ្យអ៊ុំទិញអង្ករ ខ្លាចអ៊ុំថា ម៉េចមួយម៉េចពីរ ទម្រើសខ្លួន។ ដល់អ៊ីចឹងទៅលីអុសលីអ៊ីចឹងយកទៅលក់ ចងបាច់

ហើយយកទៅលក់ឯភ្នំជិន បានប៉ុន្មានឲ្យអ៊ីទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី០៣ ខែមេសា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយសវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ខុន្នី ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-293, 2-TCCP-256 និង 2-TCCP-984 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោកស្រី យ៉ែម ខុន្នី ដំណើរការសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់របស់លោកស្រីអំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់លោកស្រីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកចូលរួមនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ និងសូមអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកទៅ ម៉ោងប្រាំបួនព្រឹក ហើយអង្គជំនុំជម្រះក៏សូមអរគុណចំពោះលោកស្រីបុគ្គលិកអង្គការ ធី.ភី.អូ ហើយអង្គជំនុំជម្រះក៏អញ្ជើញលោកស្រីមកចូលរួម និងអង្គុយក្បែរជួយពង្រឹងស្មារតីដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃស្អែកទៀត។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅវេលាម៉ោង១៦:០០ នាទី)*